ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក( IBL )នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត

# THE IMPLEMEMTATION ON INQUIRY-BASED ENGLISH LANGUAGE TEACHING AND LEARNING FOR UPPER SECONDARY SCHOOL STUDENTS IN KAMPOT PROVINCE


ដោយ/**By**

**ហាង សំអុល**/ HANG SAMOL


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧**

Accepted in Partial Fulfillment of Requirement for Master’s Degree of Educational Administration (MEA), Batch 7

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា: ២០១៩-២០២០**

**Academic Year: 2019-2020**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក( IBL )នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត

THE IMPLEMEMTATION ON INQUIRY-BASED ENGLISH LANGUAGE TEACHING AND LEARNING FOR UPPER SECONDARY SCHOOL STUDENTS IN KAMPOT PROVINCE


ដោយ/**By**

**ហង្ស សំអុល**/ HANG SAMOL


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧**

Accepted in Partial Fulfillment of Requirement for Master’s Degree of Educational Administration (MEA), Batch 7

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា: ២០១៩-២០២០**


**សាស្ត្រាចារ្យដឹកនាំបង្គោល៖ បណ្ឌិត នួន វីរ៉ា**

**សាស្ត្រាចារ្យដឹកនាំរង ៖ លោក ចាប រតនា**

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមអះអាងនិងបញ្ជាក់ជូនសាធារណជនឱ្យបានជ្រាបថា និក្ខេបបទសិក្សាស្រាវជ្រាវដែលមានចំណងជើងថា«**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក**( IBL )**នៅក្រម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត**» សម្រាប់បំពេញលក្ខខណ្ឌដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ( National Institute of Education )គឺជាស្នាដៃពិតប្រាកដរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់មាននរណាម្នាក់ បានសិក្សាស្រាវជ្រាវនិងប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនេះ ឬនៅសាកលវិទ្យាល័យណាមួយ ឬវិទ្យាស្ថានថ្នាក់ស្មើ ឬខ្ពស់ជាងណាមួយឡើយ។ ខ្ញុំបាទសូមបញ្ជាក់ជូនផងដែរថា ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារត្រង់ណាមួយ ឬការចុះបញ្ជីឯកសារយោងណាមួយដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឡើយ។

ខ្ញុំបាទសូមធានាអះអាងថា និក្ខេបបទស្រាវជ្រាវលើប្រធានបទខាងលើនេះ ពិតជាស្នាដៃផ្ទាល់របស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខាបេក្ខជន**

**ហង្ស សំអុល**

# សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

**បណ្ឌិត នូវ វីរ៉ា** សាស្ត្រាចារ្យដឹកនាំបង្គោល និង**លោក ចាប រតនា** សាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

**លោក ហេង សំអុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវលើប្រធានបទ៖ «**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក**(IBL)**នៅក្រម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

| | |
|---|---|
| **បណ្ឌិត នូវ វីរ៉ា** | **លោក ចាប រតនា** |
| នាយករង | អនុប្រធានដេប៉ាតឺម៉ង់ គ្រប់គ្រង និងផែនការ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៥៧០៤/៧ **អយក.**[illegible]

(**ការសម្គាល់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ុប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលផ្តល់កិច្ចគាំទ្រ ព្រមទាំងឱកាសដល់រូបខ្ញុំបាទបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណារ៉ា** នាយកវិទ្យាស្ថានជាតិអប់រំ លោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន ចែករំលែកបទពិសោធន៍ដល់ខ្ញុំបាទ ក៏ដូចជាមិត្តភក្តិទាំងអស់គ្នា។ សូមថ្លែងអំណរគុណដល់លោក **តាក ហាប់** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត គណៈគ្រប់គ្រងសាលារៀន លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងសាលាគោលដៅ ដែលបានចូលរួមសហការក្នុងការប្រមូលទិន្នន័យតាមកម្រងសំនួរនៅខេត្តកំពត ធ្វើឱ្យការសិក្សាស្រាវជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលាគួរជាទីមោទនភាព។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ ចំពោះលោកបណ្ឌិត **នួន ទីរ៉ា** ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម និងចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍នានា ជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទរបស់ខ្ញុំបាទទទួលបានជោគជ័យ និងឆ្លើយតបគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទក៏សូមអរគុណដល់លោកសាស្ត្រាចារ្យ **ចាប រតនា** ជាគ្រូដឹកនាំរង ដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង និងចែករំលែកបទពិសោធន៍ជាច្រើន ដល់រូបខ្ញុំបាទ រហូតដល់សម្រេចបានលទ្ធផលល្អប្រសើរ។

សូមគោរពថ្លែងអំណរគុណជាអនេកប្បការ ចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **ឈាង សទ្ធាត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃនិងមមាញឹក មកផ្តល់ជាផែនទីគំនិត និងក្របខណ្ឌបច្ចេកទេសក្នុងការសរសេរនិក្ខេបបទឱ្យទទួលបានលទ្ធផលល្អប្រសើរ ព្រមទាំងការលើកទឹកចិត្តនានា ដែលមិនអាចបំភ្លេចបាន ។

ខ្ញុំបាទសូមថ្លែងនូវការដឹងគុណ និងសេចក្តីស្រឡាញ់អស់ពីបេះដូងចំពោះ ក្រុមគ្រួសារ លោកពុក និងអ្នកម្តាយ ពូមីង បងប្អូន ដែលបានផ្តល់ការគាំទ្រជានិច្ច តែងតែលើកទឹកចិត្តរហូតមក និងផ្តល់ឱកាសឱ្យរូបខ្ញុំបាទបានបន្តការសិក្សារហូតដល់ចប់សព្វគ្រប់តាមក្តីប្រាថ្នា។

**សូមអរគុណ**!

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..................................................... i

សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ ..................................................... ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ..................... iii

សេចក្តីថ្លែងអំណរគុណ ..................................................... iv

មាតិកា ..................................................... v

បញ្ជីតារាង ..................................................... ix

បញ្ជីរូបភាព ..................................................... x

បញ្ជីអក្សរកាត់ ..................................................... xi

មូលន័យសង្ខេប ..................................................... xii

**ជំពូកទី១ ៖ សេចក្តីផ្តើម** ..................................................... 1

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ..................................................... 2

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..................................................... 4

១.៣. គោលបំណងនៃការស្រាវជ្រាវ ..................................................... 6

១.៤. សំណួរស្រាវជ្រាវ ..................................................... 7

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ..................................................... 7

១.៦. ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ ..................................................... 8

១.៦.១. វិសាលភាពនៃការស្រាវជ្រាវ ....................................................................... 8

១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ ......................................................................... 8

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................................................. 9

**ជំពូកទី២ ៖ រំលឹកទ្រឹស្ដី** ......................................................................................... 12

២.១. និយមន័យ ...................................................................................................... 12

២.២. ទ្រឹស្ដី និងបញ្ញត្តិនៃវិធីសាស្ត្របង្រៀនតាមបែបរិះរក ........................................ 13

២.៣. លក្ខណៈពិសេសនៃវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ............ 18

២.៤. ដំហាន ឬដំណាក់កាលនៃវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ............ 22

២.៥. តួនាទីរបស់គ្រូបង្រៀនក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក.30

២.៦. តួនាទីរបស់សិស្សក្នុងដំណើរការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក.................35

២.៧. កម្រិតនៃការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ....................................35

២.៨. សារៈប្រយោជន៍នៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ..........36

**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ** ............................................................................... 39

៣.១. គម្រោងវិភាគ ..................................................................................................... 39

៣.២. ការប្រមូលទិន្នន័យ ............................................................................................. 39

៣.៣. ឧបករណ៍ស្រាវជ្រាវ ............................................................................................ 41

៣.៣.១. កម្រិតចង្អុលបង្ហាញ ............................................................................ 41

៣.៣.២. កម្រងសំណួរ ....................................................................................42

៣.៣.២.១.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាទុតិយភូមិ ...........................43

៣.៣.២.២. កម្រងសំណួរសម្រាប់គ្រូបង្រៀន ....................................................................44

៣.៣.២.៣. កម្រងសំណួរសម្រាប់សិស្ស ...........................................................................47

៣.៤. ការជ្រើសរើសភាគសំណាក....................................................................................48

៣.៥. ការវិភាគទិន្នន័យ ..................................................................................................49

**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា**...........................................................52

៤.១. លទ្ធផលនៃការវិភាគទិន្នន័យ...................................................................................53

៤.២. ស្ថានភាពនៅក្នុងការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាម បែបរិះរក(IBL) របស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិសម្រាប់គ្រូបង្រៀន.......................................53

៤.២.១.ការឆ្លើយតបរបស់គ្រូបង្រៀនភាសាអង់គ្លេសទៅលើស្ថានភាពនៃការអនុវត្តវិធីសាស្រ្តបង្រៀនតាមបែបរិះរក(Inquiry Based Learning) ......................................................53

៤.២.២. ការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលា ទៅលើស្ថានភាពនៃការអនុវត្តវិធីសាស្រ្តបង្រៀនតាមបែបរិះរក(IBL)របស់លោកគ្រូ អ្នកគ្រូភាសាបង្រៀនអង់គ្លេស ..........................58

៤.២.៣. ការឆ្លើយតបរបស់សិស្សក្នុងការអនុវត្តវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសតាមបែបរិះរករបស់គ្រូ នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត ......................................................62

៤.៣. ការពិភាក្សាពីស្ថានភាពការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL)នៅមធ្យមសិក្សាទុតិយភូមិ .........................................................................................63

៤.៤. ការពិភាក្សាពីបញ្ហាប្រឈមរបស់គ្រូបង្រៀន ក្នុងការអនុវត្តវិធីសាស្រ្តបង្រៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេស ........................................................................................70

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ....... 78
៥.១. សេចក្តីសន្និដ្ឋាន ....... 78
៥.២. សំណូមពរ ....... 79
ក. ក្រសួងអប់រំ យុវជន និងកីឡា ....... 79
ខ. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត / ក្រុង ....... 80
គ. គណៈគ្រប់គ្រងសាលា ....... 80
ឃ. ចំពោះគ្រូបង្រៀនភាសាអង់គ្លេស ....... 80
ង. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត ....... 80
**ឯកសារយោង** ....... 83
**ឧបសម្ព័ន្ធ** ....... 88

# បញ្ជីតារាង


| តារាង | បរិយាយ | ទំព័រ |
|---|---|---|
| ៣.១ | ចំនួនភាគសំណាក ប្រមូលទិន្នន័យតាមវិទ្យាល័យនានាក្នុងខេត្តកំពត | 49 |
| ៤.១ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនស្តីពីការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេស | 53 |
| ៤.២ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនស្តីពីដំណើរការបង្រៀនភាសាអង់គ្លេសតាមបែបរិះរក | 54 |
| ៤.៣ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនស្តីពីទំនាក់ទំនងរវាងគ្រូ សិស្សក្នុងការបង្រៀនភាសាអង់គ្លេស | 55 |
| ៤.៤ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនស្តីពីការប្រើប្រាស់សម្ភារឧបទេស | 56 |
| ៤.៥ | ទិន្នន័យឆ្លើយតបសរុបពីគ្រូបង្រៀនស្តីពីស្ថានភាពការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក | 57 |
| ៤.៦ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្តីពីការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សារបស់គ្រូភាសាអង់គ្លេស | 58 |
| ៤.៧ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្តីពីការពិនិត្យតាមដានការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសបែបរិះរករបស់គ្រូ | 59 |
| ៤.៨ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្តីពីការពិនិត្យតាមដានទៅលើការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនភាសាអង់គ្លេសតាមបែបរិះរក | 60 |
| ៤.៩ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្តីពីការពិនិត្យតាមដានលទ្ធផលសិក្សារបស់សិស្ស | 61 |
| ៤.១០ | ទិន្នន័យឆ្លើយតបពីសិស្សលើការបង្រៀនភាសាអង់គ្លេសតាមបែបរិះរករបស់គ្រូ | 62 |
| ៤.១១ | ទិន្នន័យឆ្លើយតបពីសិស្សលើសកម្មភាពសិស្សរៀនភាសាអង់គ្លេសនៅក្នុងថ្នាក់ | 63 |
| ៤.១២ | ទិន្នន័យឆ្លើយតបសរុបពី គណៈគ្រប់គ្រង គ្រូ និងសិស្ស | 64 |
| ៤.១៣ | ទិន្នន័យឆ្លើយតបទៅលើបញ្ហាប្រឈមក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសបែបរិះរក | 71 |

# បញ្ជីរូបភាព


| រូបភាព | បរិយាយ | ទំព័រ |
|---|---|---|
| ២.១ | What is an Inquiry-Based Learning | 17 |
| ២.២ | The Cycle of Inquiry- Based Learning | 23 |
| ២.៣ | Phase of Inquiry-Based Learning | 24 |
| ២.៤ | Reflecting on the process | 27 |
| ២.៥ | Teacher's roles of Inquiry-Based learning and teaching | 34 |

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ESP | : | Education Strategic Plan |
| IBL | : | Inquiry-Based Learning |
| MoEYS | : | Ministry of Education, Youth and Sport |
| NIE | : | National Institute of Education |
| NGO | : | None Government Organization |
| NEP | : | NGO Education Partnership |
| OECD | : | Organization for Economic Corporation Development |
| PTTC | : | Provincial Teacher Training College |
| RGC | : | Royal Government of Cambodia |
| RTTC | : | Regional Teacher Training Center |

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL) នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត**" មានគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពទូទៅនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL) និងស្វែងរកពីបញ្ហាប្រឈម ទាំងឡាយដែលរារាំងដល់ការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក របស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស។

វិធីសាស្ត្រស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរធ្វើឡើងនៅមធ្យមសិក្សាទុតិយភូមិចំនួន៥ ដែលមានសំណាកសរុបចំនួន១២២នាក់ បែងចែកចេញជាៈ គណៈគ្រប់គ្រងចំនួន ១៤នាក់ គ្រូបង្រៀនចំនួន ១៨នាក់ និងសិស្សចំនួន ៩០នាក់។ ការវិភាគទិន្នន័យសិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ និងមធ្យមភាគនៃសូចនាករតាមផ្នែកនីមួយៗ ព្រមទាំងមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវឃើញថា មធ្យមភាគពិន្ទុសរុប៣.៧៧ ចង្អុលបង្ហាញថាគ្រូបង្រៀនបានអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរកក្នុងកម្រិតល្អ ឆ្លើយតបទៅនឹងកម្មវិធីសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ ការអនុវត្តដំណើរការបង្រៀន តាមកម្មវិធីសិក្សាពិតជាមានសារៈសំខាន់ណាស់ នៅមធ្យមសិក្សាទុតិយភូមិ សំដៅលើការកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមថ្នាក់រៀននីមួយៗ ទៅលើមុខវិជ្ជាភាសាអង់គ្លេស។ ឥរិយាបថជាវិជ្ជមានក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក ក៏តម្រូវឱ្យគ្រូបង្រៀនផ្តោតការយកចិត្តទុកដាក់ទៅលើដំណើរការសិក្សារបស់សិស្សជាប្រចាំផងដែរ ព្រោះដំណើរការបង្រៀនអាចទទួលបានលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមាន អាស្រ័យលើការចូលរួមពីដំណើរការសិក្សារបស់សិស្សគ្រប់រូប។ តាមលទ្ធផលនៃការសិក្សាផងដែរក៏បានបង្ហាញថា បញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត ស្ថិតនៅកម្រិតមធ្យម (ពិន្ទុមធ្យមភាគសរុប=៣.៣២) មានន័យថាបញ្ហាប្រឈមដែលគ្រូបង្រៀនកំពុងជួបប្រទះមិនធ្ងន់ធ្ងរណាស់ណាទេ។ ទន្ទឹមនឹងនោះការសិក្សាស្រាវជ្រាវក៏បានបង្ហាញពីបញ្ហាប្រឈមមួយចំនួន ទាក់ទងទៅនឹងកង្វះសៀវភៅសិក្សាគោល ការយល់ដឹងរបស់គ្រូទៅលើវិធីសាស្ត្របង្រៀនIBL នៅមានកម្រិត និងសម្ភារឧបទេសពុំទាន់គ្រប់គ្រាន់ឆ្លើយតបខ្លឹមសារមេរៀនជាដើម។ បញ្ហាប្រឈមដែលបានលើកឡើង គឺពិតជារាំងស្ទះដល់ដំណើរបង្រៀន និងរៀនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងលទ្ធផលក្នុងការសិក្សារបស់សិស្សទៀតផង។

ការពិនិត្យតាមដានជាប្រចាំក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងដំណើរការបង្រៀនរបស់គ្រូ គឺជាយន្តការដើម្បីពង្រឹងការធានាគុណភាព ឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងរដ្ឋាភិបាល ក្នុងវិស័យអប់រំ លើសមត្ថភាព ចំណេះដឹង និងជំនាញទាំងគ្រូ ទាំងសិស្ស ដែលជាកម្លាំងពលកម្មបម្រើដល់វិស័យសេដ្ឋកិច្ច ក៏ដូចជាសង្គមជាតិផងដែរ។

ជារួមស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះករបស់គ្រូទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត បានបង្ហាញថា ស្ថិតនៅក្នុងកម្រិតល្អ ដែលបង្កលទ្ធភាពប្រសើរឡើងនៃការសិក្សារបស់សិស្ស ការអនុវត្តបានតាមគន្លងអាជីពគ្រូបង្រៀន ការបន្តអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំ និងប្រសិទ្ធភាពខ្ពស់នៃការគ្រប់គ្រងនិងដឹកនាំសាលារៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត។ គណៈគ្រប់គ្រងសាលារៀន និងភាគីពាក់ព័ន្ធគួរមានកញ្ចប់ និងយន្តការបំប៉នសមត្ថភាពគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់អ្នកសិក្សា វិធីសាស្ត្របង្រៀនបែបសតវត្សទី២១ កម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញ និងការធានាបាននូវគុណភាពអប់រំនៅកម្ពុជា។

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការរៀន គឺជាដំណើរការអន្តរកម្មរវាងគ្រូ និងសិស្សក្នុងពេលរៀន និងបង្រៀនមុខវិជ្ជាណាមួយ។ ការរៀន និងបង្រៀនអាចធ្វើទៅបានល្អ ព្រមទាំងទទួលបានជោគជ័យទៅដល់គោលដៅនៃវត្ថុបំណងមេរៀន គឺពឹងផ្អែកលើបំណិនប្រសប់ក្នុងការចេះប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់លោកគ្រូ អ្នកគ្រូ។ ចំណុចសំខាន់នៃការអនុត្តវិធីសាស្ត្របង្រៀន គឺដើម្បីជម្រុញលើកទឹកចិត្ត និងបំណងប្រាថ្នារបស់សិស្សឱ្យមានចិត្តចង់រៀនសូត្រទៅលើមុខវិជ្ជាដែលពួកគេកំពុងរៀន។ មិនតែប៉ុណ្ណោះ វិធីសាស្ត្របង្រៀន អាចជួយឱ្យគ្រូបង្រៀន បង្កើតបរិយាកាស ក្នុងការរៀនសូត្ររបស់សិស្ស ទទួលបានប្រសិទ្ធភាព និងសមស្របទៅនឹងការអភិវឌ្ឍសមត្ថភាពរបស់សិស្សថែមទៀតផង។ វិធីសាស្ត្របង្រៀនក៏អាចជួយឱ្យសិស្ស និងគ្រូចូលរួមក្នុងដំណើរការរៀនសូត្រក្នុងនាមជាអ្នករួមការងារ និងបែបសហការ (Jack Byrd, 2008)។

បើយើងក្រឡេកមកមើលកំណែទម្រង់ទី៤ ក្នុងវិស័យអប់រំក្នុងចំណោមកំណែទម្រង់ទាំង១៥ចំនុចនេះវិញ យើងឃើញថាក៏មានការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនផងដែរ។ ដើម្បីចូលរួមលើកកម្ពស់សមត្ថភាព ទាំងចំណេះដឹងឯកទេស លើវិធីសាស្ត្របង្រៀន និងសីលធម៌វិជ្ជាជីវៈ ស្របតាមគោលការណ៍អប់រំសតវត្សទី២១ ក្នុងយុគសម័យឌីជីថល នៃបដិវត្តន៍ឧស្សាហកម្ម៤.០(RGC, 2018)។ យោងទៅតាម **ក្រសួងអប់រំ យុវជន និង កីឡា (២០១៥)** ក្រសួងបានបញ្ជ្រាប និងពង្រឹងបន្ថែមនូវវិធីសាស្ត្របង្រៀន និងរៀនថ្មីៗជាច្រើន ដែលក្នុងនោះ មានវិធីសាស្ត្របង្រៀនតាមបែបរិះរក (IBL) វិធីសាស្ត្របែបដោះស្រាយបញ្ហា (Problem Solving Method) វិធីសាស្ត្រតាមបែបផែនទីគំនិត(Concept Map) វិធីសាស្ត្រតាមបែបតុក្កតាគំនិត (Concept Cartoon) វិធីវិទ្យាសាស្ត្រ(Scientific Method) វិធីបង្រៀន និងរៀនបែបសហការ (Cooperative Learning) 5E(1. Engage 2. Explore 3. Explain 4. Elaborate/Extend 5. Evaluate) និងវិធីសាស្ត្រផ្សេងៗទៀត សម្រាប់បង្រៀនសិស្សឱ្យក្លាយទៅជាអ្នកសិក្សាក្នុងយុគសម័យ

ឌីជីថល(Digital)នាសតវត្សទី២១នេះ ។ ជាក់ស្តែងដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់គុណវុឌ្ឍិ និងអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនលើវិធីសាស្ត្របង្រៀនថ្មីៗ ជាពិសេសវិធីសាស្ត្របង្រៀន តាមបែបរិះរក ទៅលើមុខវិជ្ជាភាសាអង់គ្លេសជូនដល់លោកគ្រូ អ្នកគ្រូនៅប្រទេសកម្ពុជា ក្រសួងបានបើកសិក្ខាសាលា និងវគ្គបំប៉នដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ (NIE) ស្តីពី **"វិធីសាស្ត្របង្រៀនតាមបែបរិះរក"** កាលពីថ្ងៃទី ១៣ដល់ ១៥ ខែកុម្ភៈ ឆ្នាំ ២០២០ នៅខេត្តតាកែវ។

ជាការពិតវិធីសាស្ត្របង្រៀន ក៏ជាសមាសធាតុមួយដ៏សំខាន់ដើម្បីអនុវត្តគោលដៅនៃការអប់រំ នៅក្នុងដំណើរការបង្រៀន និងរៀនជាពិសេសគឺថ្នាក់ភាសាអង់គ្លេស (Natsir, 2014)។ ដើម្បីឱ្យការបង្រៀន និងរៀនភាសាអង់គ្លេស ក៏ដូចជាមុខវិជ្ជាដទៃទៀត ទទួលបានជោគជ័យ និងសម្រេចបាននូវវត្ថុបំណងមេរៀន ទាមទារឱ្យគ្រូមានគុណវុឌ្ឍិគ្រប់គ្រាន់គួបផ្សំមានវិធីសាស្ត្រច្បាស់លាស់ដែលមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងបរិបទជាក់ស្តែងក្នុងថ្នាក់រៀន សម្រាប់បង្រៀនសិស្ស។ ម្យ៉ាងទៀតដើម្បីឱ្យការបង្រៀន និងរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព គឺផ្តើមចេញពីគ្រូបង្រៀនចេះប្រើប្រាស់នូវវិធីសាស្ត្របង្រៀនផ្សេងៗដែលក្នុងនោះក៏រួមមានវិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL)ផងដែរនោះ ប្រកបដោយភាពច្នៃប្រឌិត និងភាពវៃឆ្លាតព្រមទាំងបំណិនប្រសប់។ ការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាពថែមទៀតនោះ ទាមទារឱ្យគ្រូបង្រៀន មានគុណសម្បទាជាគ្រូពូកែ ពោលគឺមានចំណេះដឹងលើមុខវិជ្ជាឯកទេស គួបផ្សំនឹងបំណិននៃការប្រើប្រាស់វិធីបង្រៀនច្រើនបែបច្រើនយ៉ាងស្របទៅនឹងតម្រូវការ និងបរិបទជាក់ស្តែង ព្រមទាំងមានចរិយាប្រកបដោយការទទួលខុសត្រូវ និងជាគំរូល្អសម្រាប់សិស្សានុសិស្ស។ គ្រូបង្រៀនក៏ទាមទារឱ្យស្ទាត់ជំនាញ ក្នុងការផ្តល់ឱកាសឱ្យសិស្សចូលរួមសកម្មភាពនៅក្នុងថ្នាក់ ព្រមទាំងយល់យ៉ាងច្បាស់លាស់អំពីវិធី ទម្លាប់ តម្រូវការរៀនសូត្ររបស់សិស្ស **(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)**។

ភាសាអង់គ្លេស គឺជាភាសាមួយក្នុងចំណោមភាសាបរទេសដទៃទៀត ក្រៅពីភាសាជាតិ ដែលត្រូវបានមនុស្សទូទៅនៅជុំវិញសកលលោកទទួលស្គាល់ និងប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងគោល

បំណាងផ្សេងៗគ្នា នាពេលបច្ចុប្បន្ន។ ទន្ទឹមនឹងការរីកចម្រើននៃការប្រើប្រាស់ភាសាអង់គ្លេសនេះ ក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល និងជាអ្នកទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលប្រជាជនរបស់ខ្លួន បានកំពុងនឹងបន្តការយកចិត្តទុកដាក់ទៅលើវិស័យអប់រំយ៉ាងខ្លាំង។ លោកគ្រូអ្នកគ្រូគឺធនធាននៃចំណេះដឹងដែលមិនចេះរីងស្ងួត សម្រាប់ការអប់រំ។ ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាល និងបំប៉នដល់លោកគ្រូ អ្នកគ្រូ លើវិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីការអប់រំយុវជន និងមនុស្សជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សី និងជាពិសេស ជាសសរទ្រូងដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ឱ្យរីកចម្រើនដូចប្រទេសនានានៅលើសកលលោក។

គ្រប់វិធីសាស្ត្របង្រៀនទាំងអស់ ដែលប្រើប្រាស់នៅក្នុងថ្នាក់រៀន គឺក្នុងគោលបំណងបណ្តុះបណ្តាលសិស្សឱ្យមានសមត្ថភាពទៅលើជំនាញមូលដ្ឋានឱ្យបានស្ទាត់តាំងពីវ័យកុមារ។ លើសពីនេះទៀត គ្រូបង្រៀនត្រូវបណ្តុះសិស្សឱ្យមានជំនាញក្នុងការគិត ត្រិះរិះពិចារណា រិះរក និងចេះស្វ័យសិក្សាដោយខ្លួនឯង ជាពិសេសគ្រូបង្រៀនត្រូវបង្រៀនសិស្សឱ្យចេះធ្វើសំយោគ វិនិច្ឆ័យ និងចេះវាយតម្លៃ ទៅលើកិច្ចការបស់ខ្លួន ប្រកបដោយភាពវៃឆ្លាត និងការបង្កើតថ្មី។ មិនតែប៉ុណ្ណោះ គ្រូធ្វើឱ្យសិស្សមានគោលគំនិតទទួលខុសត្រូវ ក្នុងការរៀនសូត្រ ចេះពិចារណារកសារៈសំខាន់ ក្នុងការរៀនសូត្ររបស់ខ្លួន ចេះតម្រង់ខ្លួនទៅរកទិសដៅមួយពិតប្រាកដ ចេះសម្រេចចិត្តដ៏ត្រឹមត្រូវដើម្បីស្វែងរកភាពជោគជ័យក្នុងការសិក្សារបស់ខ្លួន ដែលជាទិសដៅអប់រំមួយដ៏ធំធេង របស់ប្រទេសជាតិនាពេលអនាគត (ក្លាយទៅជាប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ (**ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨**)។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារបញ្ញត្តិនៃវិធីសាស្ត្របង្រៀនតាមបែបរិះរក ដែលទើបនឹងបានបញ្ជ្រាបទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅតាម សាលាបណ្តុះបណ្តាលគរុកោសល្យ និងវិក្រិតការខេត្ត (PTTC) នៅឆ្នាំ

២០១០ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូភូមិភាគ( RTTC) នៅឆ្នាំ ២០១១ (MoEYS, 2013) ហើយម្យ៉ាងទៀត វិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL) ជាវិធីសាស្ត្របង្រៀនថ្មីនាសតវត្សទី២១ នេះហើយការអនុវត្ត និងបញ្ញាបទៀតសោត ហាក់ដូចជាពុំទាន់បានទូលំទូលាយ នៅតាមសាលានៅតាមទីជនបទក្នុងកម្រិតវិទ្យាល័យមួយចំនួននៅឡើយ ទន្ទឹមនឹងនោះ ការសិក្សាស្រាវជ្រាវទៅលើស្ថានភាពអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) នេះអ្នកសិក្សាស្រាវជ្រាវពុំទាន់បានឃើញមានការសិក្សាស្រាវជ្រាវណាមួយ លើប្រធានបទនេះនៅឡើយទេ ទើបអ្នកស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះឡើង។ មួយផ្នែកទៀត តាមការសិក្សាស្រាវជ្រាវជាច្រើនទាក់ទងនឹងវិធីសាស្ត្របង្រៀន បានបង្ហាញថា មានការខ្វះចន្លោះ ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន នៅកម្រិតមធ្យមសិក្សាដោយគ្រូបង្រៀនភាគច្រើន បានយកចិត្តទុកដាក់តែទៅលើខ្លឹមសារមេរៀន មិនសូវឱ្យសិស្សអនុវត្ត និងប្រើប្រាស់សម្ភារឧបទេសឱ្យបានច្រើននោះទេ (Va sopheak, 2019)។ លើសពីនេះទៀត តាមរយៈលទ្ធផលអធិការកិច្ច បានបង្ហាញថាសាលាមធ្យមសិក្សាទុតិយភូមិមួយចំនួន មានបញ្ហាប្រឈមជាច្រើនពាក់ព័ន្ធនឹងការអនុវត្តវិធីសាស្ត្របង្រៀននេះផងដែរ (**ក្រសួងអប់រំ យុវជន និងកីឡា,២០១៩**)។ ការសិក្សាទាំងអស់នេះ បានបង្ហាញថា សមត្ថភាពគ្រូបង្រៀនលើការអនុវត្តវិធីសាស្ត្របង្រៀនផ្សេងៗ ជាពិសេសវិធីសាស្ត្របង្រៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេស ក៏ដូចជាមុខវិជ្ជាដទៃទៀត នៅមានបញ្ហាប្រឈមជាច្រើន ដោយសារតែកង្វះខាតលើការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូ ព្រមទាំងខ្វះឆន្ទៈក្នុងការអនុវត្ត និងនៅតែប្រើប្រាស់វិធីសាស្ត្របុរាណក្នុងការបង្រៀនសិស្ស ចំពោះគ្រូបង្រៀនមួយចំនួន (MoEYS, 2013)។ ដូចគ្នានេះដែរ តាមការសិក្សាស្រាវជ្រាវរបស់ Crawford (2016) បានបង្ហាញថា គ្រូបង្រៀនមិនបានប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL)ទេ ដោយសារតែចំណេះដឹង និងជំនាញនៃការអនុវត្ត IBLរបស់គ្រូនៅខ្វះខាត ខ្វះសម្ភារឧបទេសដែលឆ្លើយតបទៅនឹងខ្លឹមសារមេរៀន ដូច្នេះគ្រូភាគច្រើនចូលចិត្តប្រើប្រាស់គោលវិធីគ្រូ មជ្ឈមណ្ឌលជាជាងការប្រើប្រាស់វិធីសាស្ត្រ IBL។ លោកគ្រូ អ្នកគ្រូមិនបានអនុវត្តវិធីសាស្ត្រ IBL ពីព្រោះពួកគេមានការខ្វះខាតចំណេះដឹង បទពិសោធន៍ មិន

មានការយល់ដឹងស៊ីជម្រៅទៅលើការប្រើប្រាស់IBL និងសមត្ថភាពនៅមានកម្រិតនៅក្នុងការរិះរក (Blanchard, 2009)។ គ្រូមួយចំនួននៅតែមិនទាន់ដឹងច្បាស់ពីរបៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបរិះរកឱ្យមានប្រសិទ្ធភាពនៅឡើយទេ។ មួយវិញទៀត វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកគឺជាប្រធានបទយ៉ាងសំខាន់សម្រាប់ការសិក្សាស្រាវជ្រាវផ្នែកអប់រំ និងជាទីចាប់រម្មណ៍របស់អ្នកស្រាវជ្រាវទូទៅ ជាពិសេសអ្នកស្រាវជ្រាវក្នុងវិស័យអប់រំ ក្នុងការបង្រៀន និងរៀន។ រឿងដែលសំខាន់ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក នៅកម្រិតមធ្យមសិក្សាទុតិយភូមិ បានកម្រិតណា ដើម្បីទុកជាបទពិសោធន៍ និងចែកចាយដល់អ្នកជំនាន់ក្រោយ ទន្ទឹមនឹងនោះក៏ស្វែងរកបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ដែលលោកគ្រូ អ្នកគ្រូ កំពុងជួបប្រទះ ទុកជាសំណូមពរសម្រាប់ស្នើដល់ក្រសួង គ្រិះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងអង្គភាពពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយ និងចាត់វិធានការណ៍ឱ្យមានប្រសិទ្ធភាព ដើម្បីធានាបាននូវគុណភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនឱ្យស្របទៅនឹងបរិបទនៃប្រព័ន្ធអប់រំនៅកម្ពុជានាពេលបច្ចុប្បន្ន។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវ នេះមានពីរសំខាន់ៗគឺៈ

១. សិក្សាពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក(IBL) ទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

២.សិក្សាពីបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវបានលើកយកសំណួរដូចខាងក្រោម៖

១.តើការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក(IBL)របស់លោកគ្រូ អ្នកគ្រូទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិមានស្ថានភាពដូចម្តេច?

២.តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL) នៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសកំពុងជួបប្រទះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ជួយឱ្យអ្នកសិក្សាស្រាវជ្រាវផ្សេងៗ និងជំនាន់ក្រោយៗទៀត ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពពាក់ព័ន្ធ ជាពិសេសអ្នកចូលចិត្តសិក្សាស្រាវជ្រាវផ្នែកវិធីសាស្ត្របង្រៀនថ្មីៗ ដែលក្នុងនោះក៏មានវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរកផងដែរ អាចដឹងពីស្ថានភាពទូទៅរបស់លោកគ្រូ អ្នកគ្រូចំពោះការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL) ទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ មិនតែប៉ុណ្ណោះ អាចឱ្យយើងរកឃើញពីបញ្ហាប្រឈមនៃការរៀន និងបង្រៀនភាសាអង់គ្លេសដោយអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL)នៅមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពតផងដែរ។ ទន្ទឹមនឹងនោះ បន្ទាប់ពីអ្នកសិក្សាស្រាវជ្រាវបានធ្វើការស្វែងយល់ពីស្ថានភាពទូទៅនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក និងបញ្ហាប្រឈមរួចមក អ្នកសិក្សាស្រាវជ្រាវសង្ឃឹមថា អាចជាតម្រុយសម្រាប់អ្នកស្រាវជ្រាវក្រោយៗធ្វើការពង្រីកវិសាលភាពក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ឬ ប្រធានបទស្រដៀងនេះ ព្រមទាំងជារបកគំហើញថ្មីមួយសម្រាប់បង្ហាញឱ្យឃើញពីចំនុចសកម្មដែលលោកគ្រូ អ្នកគ្រូភាសា

អង់គ្លេសអនុវត្តបានទៅលើវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក និងចំណុចអសកម្ម ឬ ចំណុចខ្វះខាតដែលលោកគ្រូ អ្នកគ្រូត្រូវកែលម្អចំពោះការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL)នេះឱ្យបានល្អប្រសើរឡើង។

## ១.៦. ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១. វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការសិក្សាស្រាវជ្រាវ គឺគ្របដណ្តប់តែលើសាលាវិទ្យាល័យមួយចំនួនក្នុងខេត្តកំពត ដែលផ្តោតទៅលើអថេរចំនួន៣ ប៉ុណ្ណោះគឺ៖ ទី១: លោកគ្រូ អ្នកគ្រូបង្រៀនដែលកំពុងបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២។ ទី២: នាយក/នាយករង នាយិកា/ នាយិការង។ ទី៣: សិស្សដែលកំពុងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២)ស្ថិតនៅក្នុងខេត្តកំពត។ ការសិក្សាស្រាវជ្រាវនេះផងដែរ ក៏សិក្សាទៅលើស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកដែលលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស កំពុងប្រើប្រាស់តែប៉ុណ្ណោះ។ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការសម្ភាសន៍ជាមួយលោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេស ព្រមទាំងសុំឱ្យមានការបំពេញកម្រងសំណួរ។ ចំណែកគណៈគ្រប់គ្រងសាលា និងសិស្សានុសិស្សដែលស្ថិតនៅតាមសាលាគោលដៅ អ្នកសិក្សាស្រាវជ្រាវ បានសុំឱ្យជួយបំពេញកម្រងសំណួរ ដែលអ្នកសិក្សាស្រាវជ្រាវបានរៀបចំ ទាក់ទងទៅនឹងប្រធានបទ “**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក**” ។

### ១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានកំណត់ជ្រើសរើសយកតែសាលាគោលដៅចំនួន០៥សាលាវិទ្យាល័យ ហើយស្ថិតនៅក្នុងស្រុក៤ ក្នុងចំណោមស្រុក៧ ក្រុង១ក្នុងខេត្តកំពត ក្នុងនោះរួមមាន សាលានៅទីរួមខេត្ត(ក្រុងកំពត)ចំនួន១សាលា សាលាវិទ្យាល័យនៅជាយក្រុង ដែលស្ថិតនៅស្រុកទឹកឈូចំនួន១សាលា សាលា

វិទ្យាល័យដែលនៅជនបទ ក្នុងស្រុកកំពង់ត្រាចចំនួន ២សាលា និងសាលាដែលស្ថិតនៅស្រុកបន្ទាយមាស ចំនួន១សាលា។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

និក្ខេបបទសិក្សាស្រាវជ្រាវនេះ ត្រូវបានចែកជា៥ ជំពូកដូចខាងក្រោម៖

### ជំពូកទី១៖ សេចក្តីផ្តើម

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ បានបង្ហាញពីសារតានៃការសិក្សាស្រាវជ្រាវ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ និងចុងក្រោយ គឺរចនាសម្ព័ន្ធនៃការស្រាវជ្រាវ

### ជំពូកទី២៖ រំលឹកទ្រឹស្តី

អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្តីពាក់ព័ន្ធទៅនឹងប្រធានបទ និងលទ្ធផលអ្នកសិក្សាស្រាវជ្រាវមុនៗ ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងប្រធានបទនេះ ហើយជាពិសេសជាទ្រឹស្តីទាំងឡាយណាដែលបកស្រាយពីវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក មិនតែប៉ុណ្ណោះព្រមទាំងមានការលើកយក សេចក្តីពន្យល់បន្ថែម របស់អ្នកសិក្សាស្រាវជ្រាវលើទ្រឹស្តីទាំងអស់នោះ ដើម្បីឱ្យកាន់តែច្បាស់ និងពិស្តារដោយមានឯកាសារយោងសម្រាប់ពិគ្រោះយោបល់ត្រឹមត្រូវ។

### ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនិងធ្វើការបង្ហាញពីគម្រោងវិភាគ វិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យ ឧបករណ៍សម្រាប់ស្រាវជ្រាវ វិធីសាស្ត្រក្នុងការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។

### ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ និង ការពិភាក្សា

អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការលើកឡើងពីលក្ខណៈជាក់ស្តែងនៃលទ្ធផលដែលអ្នកសិក្សាស្រាវជ្រាវបានធ្វើការសិក្សា។ រាល់លទ្ធផលទាំងអស់ គឺទទួលបានតាមរយៈ ឯកសារស្រាវជ្រាវនានា តាមរយៈការសម្ភាសន៍ និងចម្លើយក្នុងកម្រងសំណួរដែលត្រូវបានបំពេញដោយភាគសំណាក ដើម្បីធ្វើការសិក្សាពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) ដែលលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសបានសម្រេចចិត្តជ្រើសរើសមកប្រើប្រាស់ក្នុង ដំណើរការបង្រៀន និងរៀនរបស់ខ្លួន។ ទន្ទឹមនឹងនោះ អ្នកសិក្សាស្រាវជ្រាវ ផងដែរក៏សិក្សារកនូវបញ្ហាប្រឈម ចំពោះការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) ដែលលោកគ្រូអ្នកគ្រូភាសាអង់គ្លេសកំពុងជួបប្រទះ។

## ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការសំណូមពរ

នៅក្នុងជំពូកនេះគឺជាជំពូកចុងក្រោយនៃការសិក្សាស្រាវជ្រាវ ដូចនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋាន ទៅលើគ្រប់ចំណុចដែលបានវិភាគខាងលើ និងលើកជាសំណូមពរលើចំណុចដែលត្រូវពង្រឹង និងកែលម្អទាក់ទងទៅនឹងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) សម្រាប់លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសយកមកប្រើប្រាស់ឱ្យបានសមស្រប មិនតែប៉ុណ្ណោះ នឹងធ្វើការសំណូមពរដល់ ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងស្ថាប័នពាក់ព័ន្ធជួយជម្រុញការផ្សព្វផ្សាយ បញ្ជ្រាប បំប៉ន បណ្តុះបណ្តាល នូវវិធីសាស្ត្របង្រៀនថ្មីៗ ជាពិសេសវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) ឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីធានាបាននូវគុណភាពអប់រំ ឱ្យឆ្លើយតបទៅនឹងការអប់រំនាសតវត្សទី២១នេះ។ លើសពីនេះទៀត អ្នកសិក្សាស្រាវជ្រាវក៏នឹងធ្វើការសំណូមពរដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងចង់សិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ឬប្រធានបទដែលប្រហាក់ប្រហែលប្រធានបទនេះ សូមពង្រីកវិសាលភាពក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានកាន់តែពិស្តារនិងច្បាស់លាស់ជាក់លាក់ជាងនេះ មិនតែប៉ុណ្ណោះ អ្នកសិក្សាស្រាវជ្រាវបានលើជាប្រធានបទសម្រាប់ឱ្យអ្នកសិក្សាក្រោយៗទៀត ដើម្បីធ្វើការសិក្សាបន្ត។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១. និយមន័យ

តើពាក្យ វិធីសាស្ត្រ និង រិះរក មានន័យដូចម្តេច? "វិធីសាស្ត្រ" និង "រិះរក" មានអត្ថន័យដូចខាងក្រោម៖

យោងទៅតាមឯកសាររបស់ **វិទ្យាស្ថានជាតិអប់រំ(២០១៩)** បានឱ្យនិយមន័យលើពាក្យ " វិធីសាស្ត្រ" ថា៖

- **វិធីសាស្ត្រ**(Method): គឺជា ល្បិច ឬ មធ្យោបាយធ្វើឱ្យការងាររបស់គ្រូបង្រៀន និងសិស្សក្រោមការដឹងនាំរបស់គ្រូ ហើយសិស្សទទួលបាននូវចំណេះដឹង(ចំណេះសម្បទា) ចំណេះធ្វើ ឬ បំណិនប្រសប់(បំណិនសម្បទា) ចរិយាសម្បទា និងចេះរស់នៅជាមួយគ្នា ព្រមទាំងពង្រីកសតិបញ្ញា ស្មារតីរបស់សិស្ស សំដៅទៅលើការប្រតិបត្តិ នូវគ្រាប់ភារកិច្ចនៃការបង្រៀន។

- **វិធីសាស្ត្រ** (Method): ជាសកម្មភាពគ្រោងទុក និងអនុវត្តន៍ដោយគ្រូ និងសិស្សនៅក្នុងថ្នាក់រៀន ដែលនាំឱ្យសម្រេចវត្ថុបំណងមេរៀន ។

- **វិធីសាស្ត្រ** (Method): សំដៅលើទម្រង់ដែលត្រូវបានរៀបចំតាមប្រព័ន្ធ និងលំដាប់លំដោយត្រឹមត្រូវ។ វាមានជំហានអនុវត្ត មានគោលបំណង ដើម្បីសម្រេចបាននូវគោលបំណងពិសេសណាមួយនៃការបង្រៀន។

- **វិធីសាស្ត្រ** (Method) បង្កើននូវលទ្ធផលសិក្សាឱ្យបានច្រើន។ វិធីសាស្ត្រដឹកនាំ និងណែនាំគ្រូបង្រៀនលើសកម្មភាពនៅក្នុងថ្នាក់រៀន និងទំនាក់ទំនងដល់ការចូលរួមរៀបចំសម្ភារឧបទេសផងដែរ។

ចំណែកឯពាក្យ "**រិះរក**"(Inquiry)វិញតាមរយៈឯកសាររបស់ **នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ** (2011) បានបង្ហាញថា៖

" **រិះរក**" សំដៅលើវិធីមួយក្នុងគោលវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ដែលផ្តោតទៅលើការអប់រំវិទ្យាសាស្ត្រ ។

"**រិះរក**" មានន័យថាការរកចំណេះដឹងតាមរយៈសំណួរ

រីឯឯកសាររបស់ **វិទ្យាស្ថានជាតិអប់រំ (២០១៨)** នេះវិញបានលើឡើងថាៈ

"**ការរិះរក**" ជាសិល្បៈ និងជាវិទ្យាសាស្ត្រក្នុងការសួរសំណួរស្តីពីពិភពធម្មជាតិ និងស្វែងរកចម្លើយនៃសំណួរទាំងនោះ។

"**ការរិះរក**" គឺជាការសង្កេត ពិចារណា វាស់វែងយ៉ាងម៉ត់ចត់ ការបង្កើតសម្មតិកម្ម ការបកស្រាយ និងការសំយោគជាទ្រឹស្តីរួម។

"**ការរិះរក**" គឺជាការសួរសំណួរ ដែលសិស្សអាចល្បងឆ្លើយបាន និងអាចនាំទៅដល់ការធ្វើតេស្ត ឬបកស្រាយភស្តុតាងប្រកបដោយអត្ថន័យ។

"**ការរិះរក**" ជាអ្វីអ្នកស្រាវជ្រាវតែងតែអនុវត្តន៍ ហើយវាជាវិធីសាស្ត្រផ្លូវការ និងជាប្រព័ន្ធក្នុងការប្រមូលព័ត៌មានសំខាន់ៗ ដែលត្រូវបានគេហៅថា ចំណេះដឹង។

ជារួម " វិធិសាស្ត្របែបរិះរក" មានន័យថាជា មធ្យោបាយធ្វើឱ្យការងារបង្រៀន និងរៀនរបស់គ្រូបង្រៀន និងសិស្សទទួលបាននូវ ចំណេះសម្បទា បំណិនសម្បទា ចរិយាសម្បទា និងចេះធ្វើការជាមួយគ្នា ព្រមទាំងពង្រីកសតិបញ្ញា ស្មារតីរបស់សិស្សតាមរយៈការសង្កេត ពិចារណា វាស់វែងយ៉ាងម៉ត់ចត់ ការបង្កើតសម្មតិកម្ម ការបកស្រាយ និងការសំយោគដែលត្រឹមត្រូវអាចទទួលយកបាន។

## ២.២. ទ្រឹស្តី និងបញ្ញត្តិនៃវិធីសាស្ត្របង្រៀនតាមបែបរិះរក

តើអ្វីទៅជាវិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL)( Definition of term Inquiry-Based Learning )? IBL គឺជាវិធីសាស្ត្របង្រៀនមួយដែលធ្វើឱ្យអ្នករៀន មានវិធីសាស្ត្រ ឬទិចនិច ព្រមទាំងមានការអនុវត្តដែលស្រដៀងគ្នាទៅនឹងវិជ្ជាជីវៈរបស់អ្នកវិទ្យាសាស្ត្រដើម្បីទទួលបាន និងកសាងចំណេះដឹង(Keselman, 2003)។

IBL គឺជាគរុកោសល្យដែលជម្រុញឱ្យសិស្សទទួលបានបទពិសោធន៍ នៃដំណើរការបង្កើតចំណេះដឹង និងកំណត់ពីគន្លឹះសំខាន់ៗដើម្បីជម្រុញការរៀនតាមរយៈការរិះរក(ផ្លាស់ប្តូរការរៀនដឹកនាំដោយខ្លួនឯងនិងវិធីសាស្ត្រសកម្មក្នុងការរៀនសូត្រ) (Spronen, 2008)។

IBL គឺជាវិធីសាស្ត្របង្រៀនមួយ ដែលមានគោលដៅផ្តោតលើជំនាញនៃការរិះរករបស់សិស្សតាមរយៈការប្រើប្រាស់ចំណេះដឹងដើម្បីដោះស្រាយបញ្ហាដោយប្រើវិធីវិទ្យាសាស្ត្រ (MoEYS, 2011)។

តាមលោក Levy,P., Little, S., Mckinney, P., Nibbs,A. and Wood, J., (2010) បានបង្ហាញថា **វិធីបង្រៀនតាមបែបរិះរក** (IBL) សំដៅទៅលើចង្កោមនៃវិធីសាស្ត្រគរុកោសល្យ ដែលបង្កលក្ខណៈឱ្យសិស្សរៀនក្នុងចរិកសកម្មតាមរយៈសកម្មភាពរៀនដោយរុករក និងស្រាវជ្រាវចំនេះដឹងដោយខ្លួនពួកគេផ្ទាល់។ "**វិធីបង្រៀនតាមបែបរិះរក**" គឺថាគ្រប់យ៉ាងផ្តើមចេញពីការចោទសួរ។ សិស្សអាចសួរសំណួរផ្សេងៗភ្លាមៗដោយចិត្តចង់ចេះ ចង់ដឹងរបស់គេដោយខ្លួនឯង ឬ អាចឱ្យគេជួយឱ្យចេះឆ្ងល់ និងសួរអំពីប្រធានបទអ្វីមួយ។ សិស្សអាចធ្វើការស្រាវជ្រាវដើម្បីស្វែងរកចម្លើយ សម្រាប់សំណួររបស់គេ ឬ គេអាចចូលរួមសកម្មភាពមួយចំនួន ដើម្បីជួយគេស្វែងរកចម្លើយ ឬគេអាចធ្វើការជាមួយមិត្តគេក៏បាន។ "**វិធីបង្រៀនតាមបែបរិះរក**" គឺជាការបង្រៀនដែលលើកទឹកចិត្តសិស្សឱ្យធ្វើការជាមួយគ្នា ដើម្បីផ្តល់ចម្លើយទៅនឹងសំណួររបស់ពួកគេជាជាងការបង្រៀនដោយផ្ទាល់ពីគ្រូ និងធ្វើអ្វីៗតាមតែគ្រូ។ ការងាររបស់គ្រូក្នុងការបង្រៀន និងរៀនតាមវិធីរិះរក គឺមិនមែនផ្តល់ចំណេះដឹងទៅឱ្យសិស្សនោះទេ ប៉ុន្តែគ្រូវជួយសិស្សឱ្យរកបាននូវចំណេះដឹងណាមួយដោយខ្លួនគេផ្ទាល់ (**នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ**, 2011)។ លើសពីនេះទៅទៀត "**វិធីបង្រៀនតាមបែបរិះរក**" ក៏តម្រូវឱ្យសិស្សចេះសង្កេត និងវិភាគពីបាតុភូត វិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម ដើម្បីបង្កើតសំណួរ ធ្វើពិសោធន៍ ឬធ្វើការស្រាវជ្រាវដើម្បីឆ្លើយទៅនឹងសំណួររបស់ពួកគេ និងទាញចេញនូវសេចក្តីសន្និដ្ឋានសមស្របមួយតាមរយៈលទ្ធផលនៃការធ្វើពិសោធន៍ ឬការសិក្សាស្រាវជ្រាវនោះ។ ទន្ទឹមនឹងនោះ ការបង្រៀន និងរៀនតាមបែបរិះរក គ្រូបង្រៀនអាចទទួលបានផងដែរ នូវបទពិសោធន៍អំពីការសិក្សាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល បើ

ទោះបីវិធីសាស្ត្រនៃការបង្រៀន និងរៀនតាមបែបរិះរកនេះវាទាមទារឱ្យគ្រូបង្រៀនត្រូវមានចំណេះដឹងខ្ពស់ខាងវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ព្រមទាំងមានជំនាញក្នុងការបង្រៀន ខ្ពស់ជាងវិធីសាស្ត្រធម្មតាក្ដី។ "**វិធីបង្រៀនតាមបែបរិះរក**" ជាវិធីសាស្ត្របង្រៀនមួយដែលស្ថិតនៅក្នុងគោលវិធីសិស្សមជ្ឈមណ្ឌលដែលផ្ដោតលើការអប់រំវិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ។ "**វិធីបង្រៀនតាមបែបរិះរក**" គឺជាយុទ្ធវិធីបង្រៀនមួយដែលគាំទ្រគោលវិធីសិស្សមជ្ឈមណ្ឌល។ យុទ្ធវិធីនេះអនុវត្តតាមទ្រឹស្ដីកសាងចំណេះដឹង( Constructivist Theory ) ដែលគ្រូត្រូវជួយសិស្សក្នុងការកសាងចំណេះដឹងដោយខ្លួនឯង។ ទន្ទឹមនឹងនោះ គ្រូជាអ្នកសម្របសម្រួលដំណើរការសិក្សារបស់សិស្ស រីឯសិស្សត្រូវបានលើកទឹកចិត្តឱ្យរៀនបង្កើតខ្លឹមសារសំខាន់ស្របតាមគោលបំណងមេរៀន។ តាមវិធីនេះ គ្រូត្រូវអត់ធ្មត់ និងជឿជាក់ថាសិស្សអាចធ្វើបានដោយខ្លួនឯង ដោយប្រើចំណេះដឹង មូលដ្ឋានរបស់ពួកគេ (**ក្រសួងអប់រំយុវជន និងកីឡា, ២០១៨**)។

តាមរយៈឯកសាររបស់ NIE (2020) **បានលើកឡើងថា៖ "វិធីបង្រៀនតាមបែបរិះរក**" មានន័យថា វាគឺជាទ្រឹស្ដីកសាងចំនេះដឹង ដែលសិស្សានុសិស្សត្រូវតែមានភាពម្ចាស់ការនៃការរៀនរបស់ពួកគេ។ ការរៀន និងបង្រៀនចាប់ផ្ដើមពីការរុករក និងការសួរសំណួរ ហើយនាំឱ្យមានការអង្កេតទៅលើសំណួរ, បញ្ហា និងគំនិត។ មួយវិញទៀត វិធីបង្រៀនតាមបែបរិះរក គឺជាការសួរសំណួរ ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការបង្កើតដំណោះស្រាយ ការធ្វើការសម្រេចចិត្ត ការធ្វើការសន្និដ្ឋានដ៏ត្រឹមត្រូវ និងចុងក្រោយធ្វើសកម្មភាព។ "**ការបង្រៀន និងរៀនតាមបែបរិះរក**" គឺការរៀនសូត្រដែលផ្អែកលើការសាកសួរទាក់ទងទៅនឹងអ្នកសិក្សាក្នុងការជ្រើសរើស ការឆ្ងល់ ការប៉ាន់ស្មាន ការសាកសួរសំនួរ ការប្រមូលព័ត៌មានបន្ថែម ការសង្កេត ការបង្កើតទំនាក់ទំនង ការរៀនបែបស៊ីជម្រៅ ការពិចារណាលើទស្សនៈផ្សេងទៀតដែលឆ្លុះបញ្ចាំងនិងធ្វើសកម្មភាពថ្មីដោយផ្អែកលើអ្វីដែលបានរៀន ។ " **ការបង្រៀន និងរៀនតាមបែបរិះរក**"គឺជាវិធីនៃការបង្រៀន និងការរៀនដែលភាគច្រើនត្រូវបានដឹកនាំដោយសិស្ស។ សិស្សធ្វើការស្រាវជ្រាវ ស្វែងរក ស៊ើបអង្កេត និងសិក្សាពីប្រធានបទដោយផ្អែកលើការចង់ដឹងចង់ឃើញរបស់ពួកគេ ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេអំពីពិភពលោកតាមរយៈការរៀន បែបរិះរក ។ " **ការបង្រៀន និងរៀន តាមវិធីសាស្ត្របែបរិះរក**" គឺជាវិធី

សាស្ត្រមូលដ្ឋានដើម្បីរៀនរិះរកដោយផ្អែកលើទ្រឹស្តីការរៀនកសាងចំណេះដឹង។ យុទ្ធសាស្ត្រនៃការរៀនកសាងចំណេះដឹងបានទាញយកប្រយោជន៍ពីការរៀនបែបរិះរក និងការដោះស្រាយបញ្ហាតាមរយៈការគិតបែបស៊ីជម្រៅ(Critical Thinking) និងការបង្កើតថ្មី(New Creation)។ យោងទៅតាម **Asselin; Branch; &Oberg (2003)** បានបង្ហាញថា សិស្សានុសិស្សដែលជាអ្នករិះរក ត្រូវបានលើកទឹកចិត្តឱ្យស្វែងរកគំនិត និងការយល់ដឹងថ្មីៗតាមរយៈរបកគំហើញ និងការរុករកផ្ទាល់ខ្លួនក៏ដូចជាអន្តរកម្មជាមួយវត្ថុ និងជាមួយមនុស្សដទៃទៀត។ ការរៀនសូត្រត្រូវបានពង្រឹងតាមរយៈអ្នកសួរសំណួរ(គ្រូបង្រៀន)ដើម្បីផ្តល់ឱកាសឱ្យសិស្សមានការចូលរួមសកម្មភាព និងស្ថានភាពដោយផ្សារភ្ជាប់ទៅនឹងជីវិតជាក់ស្តែង។

**តាមទ្រឹស្តីការបង្រៀន និងរៀនតាមបែបរិះរក គ្រូបង្រៀនគឺជាអ្នកបង្កអង្គហេតុដល់សិស្ស៖**

- អាចបង្កើតចំណេះដឹង និងការយល់ដឹងយ៉ាងសកម្មរបស់ពួកគេតាមរយៈការសាកសួរនិងការស្វែងរកព័ត៌មានរបស់ពួកគេ
- អភិវឌ្ឍន៍ការយល់ដឹងក៏ដូចជាការយល់ដឹងបែបស៊ីជម្រៅរបស់ពួកគេនៅពេលពួកគេទទួលបានព័ត៌មាន
- ផ្លាស់ប្តូរបទពិសោធន៍នូវចំណេះដឹងរបស់ពួកគេនៅពេលពួកគេមានភាពរីកចម្រើន
- ត្រូវការពេលវេលាដើម្បីឆ្លុះបញ្ចាំងពីព័ត៌មាន និងចំណេះដឹងថ្មីរបស់ពួកគេដែលបានរកឃើញ។




រូបភាព២.១: What is an Inquiry- Based Learning ?

## ២.៣. លក្ខណៈពិសេសនៃវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក

បើយោងទៅតាមគេហទំព័រ (The Intel Teach Essentials course) ការរៀន និងបង្រៀនតាមបែបរិះរកមានគំរូជាច្រើនទៀតសម្រាប់រៀន។ វាជាអាកប្បកិរិយាចំពោះជីវិតដែលសំដៅលើការជាប់ទាក់ទងក្នុងការប្រឈមមុខ និងការដោះស្រាយបញ្ហារបស់សិស្សព្រមទាំងស្វែងរកដំណោះស្រាយ និងយុទ្ធសាស្ត្រជាក់ស្តែង។ គំរូនេះតម្រូវឱ្យសិស្សគិតតាមលក្ខណៈជាប្រព័ន្ធដើម្បីឈានដល់ដំណោះស្រាយសមហេតុផលមួយ។ ការបង្រៀន និងរៀនតាមបែបរិះរកវាក៏ជាគោលវិធីសិស្សមជ្ឈមណ្ឌលផងដែរដែលទាមទារឱ្យសិស្សានុសិស្សមានការចូលរួមសហការគ្នាដើម្បីសម្រេចកិច្ចការ។ លក្ខណៈពិសេសសំខាន់ៗនៃវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL) មានដូចខាងក្រោម៖

- IBL ជំរុញការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណារបស់សិស្ស
- IBL អនុញ្ញាតឱ្យមានការចូលរួមយ៉ាងសកម្មរបស់សិស្សក្នុងការទទួលបានចំណេះដឹង
- IBL ជួយសម្រួលដល់ជំនាញដោះស្រាយបញ្ហាដល់សិស្ស
- IBL ណែនាំសិស្សឱ្យចេះបង្កើតនិងបង្ហាញគំនិតតាមរយៈប្រភេទនៃសំណួរ
- IBL អនុញ្ញាតឱ្យសិស្សមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ទំនាក់ទំនងទៅនឹងសហគមន៍ក្នុងតំបន់ក៏ដូចជាសហគមន៍ពិភពលោកក្នុងអត្ថន័យ និងមធ្យោបាយផ្សេងៗ។

នៅពេលគ្រូបង្រៀនភាសាអង់គ្លេសប្រើប្រាស់នូវវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក តួនាទីរបស់គ្រូត្រូវតែមានការផ្លាស់ប្តូរ។ លោកគ្រូ អ្នកគ្រូត្រូវតែផ្តោតទៅលើសកម្មភាពសិស្ស និងការប្រើប្រាស់សំណួរដើម្បីលើកទឹកចិត្តដល់ការស្រាវជ្រាវ ការសង្កេត ការស្វែងរកហេតុផល និងការចូលរួមរបស់សិស្ស។ លើសពីនេះទៅទៀត លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសត្រូវតែមានការណែនាំពី ឧបករណ៍ និងវិធីសាស្ត្រផ្សេងៗដោយយោងទៅតាមខ្លឹមសារមេរៀន ឬប្រធានបទ ហើយគ្រូក៏បានក្លាយទៅជាអ្នកសម្របសម្រួលដល់ការរៀនសូត្ររបស់សិស្ស។ គ្រូបង្រៀនត្រូវតែបង្រៀនយ៉ាងសកម្ម ដោយមានរៀបចំគម្រោង និងចេះដាក់បញ្ហាដល់សិស្សដើម្បីដំណើរការបង្រៀន និងរៀនតាមបែបរិះរក(IBL)។ ទន្ទឹមនឹងនោះ គ្រូបង្រៀន

គឺជាសមាជិកក្រុមនីមួយៗជានិច្ចដោយដើរជុំវិញថ្នាក់ ធ្វើអន្តរកម្មជាមួយសិស្ស និយាយជាមួយពួកគេសួរសំណួរពួកគេ និងផ្តល់យោបល់ដល់ពួកគេ ជំនួសដោយគ្រាន់តែអង្គុយនៅតុរបស់ខ្លួនតែមួយកន្លែងចាំតែមើលសកម្មភាពរបស់សិស្សនោះទេ។

តាមការពិតការបង្រៀន និងរៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក គឺគ្រូដើរតួជាអ្នកសម្របសម្រួលក្នុងដំណើរការបង្រៀន និងរៀន។ សិស្សត្រូវតែអនុវត្តយ៉ាងសកម្មក្នុងដំណើរការបង្រៀន និងរៀនដើម្បីធ្វើការស្វែងយល់អំពីសម្ភារៈដែលទាក់ទងទៅនឹងខ្លឹមសារមេរៀន (Endang Lestari Universitas Muhammadiyah Surakarta, 2016)។

តាមលោក Fauziati; Endang (2014) បានបញ្ជាក់ថាការស៊ើបអង្កេតមិនមែនគ្រាន់តែស្វែងរកចម្លើយត្រឹមត្រូវប៉ុណ្ណោះទេប៉ុន្តែផងដែរក៏ស្វែងរកដំណោះស្រាយសមស្របសម្រាប់សំណួរនិងបញ្ហាដែលបានដាក់។ បើតាមលោក Harlen (2013) បានអះអាងថាការអប់រំតាមបែបរិះរក គឺសំដៅទៅលើការស្វែងរក ការពន្យល់ និងព័ត៌មានតាមរយៈការសួរសំណួរ។ ការបង្រៀន និងរៀនតាមបែបរិះរក គឺជាសកម្មភាពបង្រៀន និងរៀនដោយមានការចូលរួមពីសិស្សក្នុងដំណើរការបង្រៀន និងរៀន។ សិស្សក៏ត្រូវស្នើឱ្យរកមើលបញ្ហាជុំវិញដែលពាក់ព័ន្ធហើយបង្កើតសម្មតិកម្ម បន្ទាប់មកធ្វើការដោះស្រាយបញ្ហា។ វាតំរូវអោយសិស្សចូលរួមយ៉ាងសកម្ម រីឯគ្រូវិញដើរតួជាអ្នកសម្របសម្រួល នៅក្នុងសកម្មភាពនៃដំណើរការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក គឺដើម្បីឱ្យសិស្សទទួលបាននូវសមត្ថភាពជាមូលដ្ឋានគ្រឹះតាមរយៈការធ្វើអន្តរកម្ម ការបំផុសគំនិត ការរីករាយក្នុងការប្រកួតប្រជែងក្នុងថ្នាក់ និងការលើកទឹកចិត្តសិស្សឱ្យក្លាយជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងគោលបំណងឱ្យពួកគេមានការច្នៃប្រឌិត ការបង្កើតថ្មី និងដឹកនាំខ្លួនឯងដោយផ្អែកទៅតាមទេពកោសល្យ ការចាប់អារម្មណ៍ និងការអភិវឌ្ឍកាយសម្បទា និងផ្លូវចិត្តរបស់ពួកគេ។

ការរៀន និងបង្រៀនតាមបែបរិះរក គឺជាការរៀនសូត្រដែលផ្អែកលើសកម្មភាពសម្របសាម្រួលក្នុងការជួយដល់សិស្សចំពោះការរៀនសូត្ររបស់ពួកគេតាមរយៈសកម្មភាពនៃការស្រាវជ្រាវនិងវិធីសាស្ត្រ

ស្រាវជ្រាវជាច្រើនទៀត (Jamie Peter Wood University Shuffield, UK, 2009)។ រាល់កិច្ចការ និងភារកិច្ចរបស់សិស្សត្រូវរួមបញ្ចូលនូវគម្រោងផ្សេងៗគ្នា ហើយត្រូវបានរៀបចំឡើងដើម្បីឱ្យសិស្សមានការចូលរួមក្នុងការឆ្លើយសំណួរ និងដោះស្រាយបញ្ហាក្នុងការសិក្សាប្រកបដោយវិជ្ជាជីវៈ និងមានន័យល្អតាមរយៈការអនុវត្តទៅលើការសិក្សាស្រាវជ្រាវនៃកិច្ចការនោះ (Brew; Kahn & O'Rourke, 2006)។ គ្រប់សកម្មភាពនានាត្រូវបានគាំទ្រ និងដឹកនាំដោយគ្រូដើម្បីឆ្ពោះទៅពង្រីកវិសាលភាពនៃការស្រាវជ្រាវដោយផ្អែកលើន័យរបស់សិស្ស កម្រិតសំណួរ ព្រមទាំងកម្រិតយល់ដឹង និងគោលបំណងរបស់សិស្ស។

នៅក្នុងវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកមានភាពជាប់ទាក់ទងគ្នានូវដំណាក់កាលសំខាន់ៗសម្រាប់ការអភិវឌ្ឍការរៀន និងបង្រៀន។ ការដឹកនាំផ្ទាល់នៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកគឺមានលក្ខណៈបែបសហការគ្នាដើម្បីធ្វើការរៀបចំគម្រោងពិភាក្សាគ្នាដោយផ្តោតទៅលើបញ្ហា តាមរយៈការសាកសួរសំណួរគន្លឹះ ដែលទាក់ទងទៅនឹងប្រធានបទ។ ករណីសិក្សាដែលសំខាន់នោះគឺ ការរៀន និងបង្រៀនតាមបែបរិះរកតម្រូវឱ្យសិស្សចេះដោះស្រាយបញ្ហាដោយខ្លួនឯងតាមរយៈការពិភាក្សាក្រុមដើម្បីគាំទ្រដល់ដំណើរការផ្សេងៗក្នុងការច្នៃប្រឌិតនៃដំណើរការរិះរក។ ជាឧទាហរណ៍៖ តម្រូវការរបស់សិស្ស គឺត្រូវការអនុវត្តនូវវិធីសាស្ត្រស្រាវជ្រាវឯករាជ្យ មានន័យថាសិស្សមានការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍក្នុងការប្រមូលព័ត៌មានប្រកបដោយសមត្ថភាពក្នុងការស្រាវជ្រាវស្វែងរកតម្លៃ និងចេះសំយោងព័ត៌មាន។ ដូចគ្នានេះដែរការប្រើប្រាស់ការងារបែបសហការគ្នាក្នុងសកម្មភាពស៊ើបសួរ រិះរក អាចមានន័យថាការសង្កត់ធ្ងន់ជាពិសេសទៅលើការរៀបចំសិស្សសម្រាប់ពួកគេ ធ្វើការជាក្រុម (Jamie Peter Wood University Shuffield, UK, 2009)។

❖ **លក្ខណៈពិសេសផ្សេងៗទៀត នៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក**

តាមរយៈឯកសាររបស់ **វិទ្យាស្ថានជាតិអប់រំ (២០២០)** បានលើកឡើងពីលក្ខណៈពិសេសនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) ដូចខាងក្រោម៖

- ការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកវាសង្កត់ធ្ងន់លើគំនិតច្នៃប្រឌិតនៃការរៀនសូត្ររបស់សិស្ស
- ដំណើរការនៃការរៀន និងបង្រៀនដែលល្អបំផុតគឺស្ថិតនៅក្នុងស្ថានភាពនៃការងារក្រុម
- គ្រូមិនចាប់ផ្តើមជាមួយសេចក្តីពន្យល់ទេ ប៉ុន្តែចាប់ផ្តើមជាមួយនឹងសំណួរបំផុស
- ការបង្រៀនដោយបិទសំណួរលើក្តារខៀនសម្រាប់សិស្សដើម្បីដោះស្រាយគឺជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពនៅក្នុងការបង្រៀនមុខវិជ្ជាផ្សេងៗទៀតមិនថាតែចំពោះមុខវិជ្ជាភាសាអង់គ្លេសទេ
- នេះអនុញ្ញាតឱ្យសិស្សធ្វើការស្វែងរកព័ត៌មាន និងរៀនដោយខ្លួនឯងដោយមានការណែនាំពីគ្រូ
- ប្រធានបទ ឬបញ្ហាដែលត្រូវសិក្សានិងវិធីសាស្ត្រដែលត្រូវប្រើ ដើម្បីឆ្លើយតបនឹងបញ្ហាត្រូវបានកំណត់ដោយសិស្ស
- វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកវាជំរុញឱ្យមានការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណាសម្រាប់សិស្ស
- អនុញ្ញាតឱ្យមានការចូលរួមយ៉ាងសកម្មរបស់សិស្សក្នុងការទទួលបានចំណេះដឹង និងគំនិតបង្កើតថ្មី
- សម្របសម្រួលជំនាញដោះស្រាយបញ្ហាសម្រាប់សិស្សានុសិស្ស
- ណែនាំសិស្សឱ្យបង្កើត និងបង្ហាញគំនិតតាមរយៈសំណួរជាច្រើនដែលអនុញ្ញាតឱ្យសិស្សមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលមានសារៈប្រយោជន៍ច្រើនជាងការបង្រៀន និងរៀនកាលពីមុនដោយផ្សារភ្ជាប់សិស្សទៅនឹងសហគមន៍មូលដ្ឋានក៏ដូចជាសហគមន៍ពិភពលោក។

## ២.៤. ជំហាន ឬដំណាក់កាលនៃវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក

យោងតាមឯកសាររបស់ **វិទ្យាស្ថានជាតិអប់រំ** (២០២០) បានបង្ហាញពីជំហាននៃការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)មានដូចខាងក្រោម៖

1. Ask: **សួរ៖** សិស្សបង្កើតសំណួររបស់ពួកគេផ្ទាល់ទាក់ទងទៅនឹងខ្លឹមសារមេរៀនដែលត្រូវរៀន
2. Investigate: **អង្កេត៖** សិស្សប្រមូលព័ត៌ ឬទិន្នន័យធ្វើពិសោធន៍ និងរិះរកពីធនធាននានា
3. Create: **បង្កើតថ្មី៖** សិស្សបង្កើតគំនិតថ្មី មតិយោបល់ថ្មី ឬទ្រឹស្តីថ្មីដែលមិនមែនបានមកដោយផ្ទាល់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេមានស្រាប់នោះទេ។
4. Discuss: **ពិភាក្សា៖** សិស្សចែករំលែកគំនិតរបស់ពួកគេជាមួយមិត្តរួមថ្នាក់ហើយសួរនាំអ្នកផ្សេងទៀតអំពីបទពិសោធន៍ និងការរិះរករបស់ពួកគេ
5. Reflect: **ឆ្លុះបញ្ចាំងឡើងវិញ៖** សិស្សគិតឡើងវិញពីសំណួរដំបូងពីវិធីដែលបានអនុវត្ត និងការសរុបយោបល់នានាហើយអាចធ្វើការសម្រេចចិត្តមួយចំនួនបាន។




រូបភាព២.២ : The Cycle of Inquiry- Based Learning




រូបភាព២.៣: Phase of Inquiry- Based Language Learning

លោកគ្រូ អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរកផងដែរក៏លើកទឹកចិត្តសិស្សឱ្យអនុវត្តតាមវដ្តនៃបែបរិះរកដូចខាងក្រោម៖




បើយោងទៅតាម (http://www.cii.illinois.edu/Inquiry page) បានអធិប្បាយនូវដំណាក់កាលនីមួយៗដូចខាងក្រោមគឺ៖

**ដំណាក់កាលទី១: Ask: មានន័យថាសួរ៖** ដំណាក់កាលនេះសិស្សានុសិស្សត្រូវតែរៀបចំផែនការភារកិច្ចរបស់ពួកគេ និងបង្កើតសំណួរដែលមានខ្លឹមសារទាក់ទងទៅនឹងបញ្ហា ឬប្រធានបទដែលពួកគេត្រូវពិភាក្សាក្នុងការសិក្សា។

**ដំណាក់កាលទី២ : Investigate: មានន័យថាអង្កេត៖** ដំណាក់កាលនេះ គឺជាដំណាក់កាលប្រមូលព័ត៌មានដែលសិស្សប្រមូលផ្តុំគ្នានៅក្នុងក្រុមហើយបង្រួមប្រធានបទ មានន័យថាសិស្សធ្វើការងារជាក្រុមហើយធ្វើការពិភាក្សាទៅលើចំនុចរងតូចៗនៃប្រធានបទរបស់មេរៀន។ សិស្សានុសិស្សចាប់ផ្តើម ប្រមូលព័ត៌មានធ្វើការរិះរកនូវព័ត៌មាន ធ្វើការសិក្សា សម្ភាសន៍មនុស្ស និងធ្វើការអង្កេតយ៉ាងប្រុងប្រយ័ត្នពីប្រភពផ្សេងៗ មិនតែប៉ុណ្ណោះថែមទាំងផ្លាស់ប្តូរសំណួរនៅពេលចាំបាច់។ លោកគ្រូ អ្នកគ្រូបង្រៀន ផងដែរក៏ត្រូវ

បង្រៀនសិស្សានុសិស្សពីរបៀបប្រមូលព័ត៌មានតាមបណ្ដាញប្រព័ន្ធអ៊ីនធឺណែត( Internet ) និងការជ្រើសរើសប្រភពព័ត៌មានទាំងឡាយណាដែលអាចយកជាការបានហើយទាក់ទងទៅនឹងប្រធានបទ។

**ដំណាក់កាលទី៣:** Create : **ការបង្កើតថ្មី៖** សិស្សានុសិស្សចាប់ផ្ដើមធ្វើការទំនាក់ទំនងគ្នា។ ពួកគេសំយោគអ្វីដែលពួកគេបានរៀន និងរៀបចំគំនិតព្រមទាំងទ្រឹស្ដីថ្មីៗក្រៅពីចំណេះដឹងនិងបទពិសោធន៍ដែលពួកគេមានពីមុនមក។ ដំណាក់កាលទី៣នេះ គឺជាដំណាក់កាលដែលសិស្សានុសិស្ស អនុវត្តការរៀបចំជំនាញតែងនិពន្ធ ព្រមទាំងចាប់ផ្ដើមសរសេររបាយការណ៍របស់ពួកគេហើយរៀបចំគម្រោងដើម្បីធ្វើបទបង្ហាញនៅក្នុងក្រុមតូចរបស់ពួកគេ។

**ដំណាក់កាលទី៤:** Discuss: **ការពិភាក្សា៖** សិស្សានុសិស្សធ្វើការចែករំលែកនូវរបកគំហើញថ្មីជាមួយសមាជិកក្រុមរបស់ពួកគេ។ ពួកគេផងដែរក៏ស្វែងយល់អំពីរបកគំហើញរបស់មិត្តរួមថ្នាក់ផ្សេងទៀតរបស់ពួកគេនិងចូលរួមក្នុងដំណើរការកសាងទំនាក់ទនងរវាងក្រុម និងក្រុម។ គោលបំណងនៃការស្រាវជ្រាវរបស់ពួកគេគឺកាន់តែមានភាពពាក់ព័ន្ធនៅពេលពួកគេបន្តប្រៀបធៀបខ្លឹមសារនិងពិភាក្សាការសន្និដ្ឋានជាមួយសមាជិកក្រុមរបស់ពួកគេ និងជាមួយអ្នកជំនាញមកពីក្រុមផ្សេងទៀត។

**ដំណាក់កាលទី៥:** Reflect: **ឆ្លុះបញ្ចាំង៖** សិស្សប្រមូលផ្ដុំគ្នាជាក្រុមម្ដងទៀតដើម្បីមើលទៅសំណួរ ឬបញ្ហាដែលបានស្នើឡើង។ ពួកគេវិភាគម្ដងទៀតនូវដំណើរការស្រាវជ្រាវទាំងមូលនិងការសន្និដ្ឋានរួមទាំងព័ត៌មានដែលទទួលបានដោយអ្នកសហការនៅក្នុងក្រុម។ ពួកគេផងដែរក៏រៀបចំការសរសេររបាយការណ៍នៅចុងបញ្ចាប់ និងត្រៀមធ្វើបទបង្ហាញ។ ដំណាក់កាលនីមួយៗនៃការរៀន និងបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក អាចនាំឱ្យសិស្សចេះធ្វើការងារជាក្រុម តាមបែបសហការនៅដំណាក់កាលបន្តបន្ទាប់ដើម្បីផ្ដល់ឱ្យសិស្សនូវឱកាសកាន់តែច្រើនក្នុងការស៊ើបអង្កេត និងបន្តឆ្លងកាត់នូវដំណាក់កាលនីមួយៗនៃវដ្តរបស់ការសិក្សាតាមបែបរិះរកហូតដល់ពួកគេពេញចិត្តនូវចម្លើយដែលពួកគេបានធ្វើ។

បើយោងទៅតាម (Branch, jennifer.et all, 2004) គំរូនៃការ បង្រៀន និងរៀនតាមវិធីសាស្ត្របែបរិះរកបានបង្ហាញច្បាស់អំពីតួនាទីរបស់គ្រូបង្រៀន និងអ្នកសិក្សាទាក់ទងនឹងបញ្ញត្តិ។ នៅក្នុងគំរូនេះមាន ៧ដំណាក់កាលគឺ មានការឆ្លុះបញ្ចាំង ការធ្វើផែនការ ការទាញយកការកែតម្រូវ ដំណើរការ ការ បង្កើតថ្មី ការចែករំលែក និងវាយតម្លៃ។




រូបភាព២.៤ : Reflecting on the Process

Source: adapted from http://ednet.edc.gov.ab.calk-12/curriculum/by

**ដំណើរការឆ្លុះបញ្ចាំង៖**

ដំណាក់កាលឆ្លុះបញ្ចាំងពាក់ព័ន្ធនឹងជំហាននៃការធ្វើផែនការ ការទាញយកព័ត៌មាន ដំណើរការ ការបង្កើត

ថ្មី ការចែករំលែក និងវាយតម្លៃដែលទាក់ទងទៅនឹងប្រសិទ្ធភាព និងចំណេះដឹង (Branch, jennifer.et all, 2004)។

➢ **ដំណាក់កាលការធ្វើផែនការ** (Planning Phase)៖

តាមJonassen (2000)នៅដំណាក់កាលដំបូងនេះសិស្សនឹងទទួលបានការចាប់អារម្មណ៍ ឬចង់ដឹងអំពីប្រធានបទ។ សិស្សានុសិស្ស ឬអ្នកសួរសំណួរយល់ឃើញថាគម្រោងទាំងមូលគឺជាល្បែងផ្គុំរូបដែលត្រូវការដោះស្រាយ។ សិស្សនឹងចាប់ផ្តើមដោយ៖

- រកមើលសំណួរទូទៅដែលត្រូវការដើម្បីស៊ើបអង្កេត
- ការស្វែងរកព័ត៌មាន និងសម្ភារៈទាក់ទងដែលទាក់ទងទៅនឹងប្រធានបទជាក់លាក់
- កំណត់វិធីដើម្បីបង្ហាញព័ត៌មានដល់មិត្តរួមថ្នាក់
- ស្នើឱ្យមានលក្ខណៈវិនិច្ឆ័យដែលទាក់ទងទៅនឹងលទ្ធផលស្រាវជ្រាវ និងវាយតម្លៃដំណើរការរបស់ពួកគេ ។

➢ **ដំណាក់កាលទាញយកព័ត៌មាន** (Retrieving Phase)៖

នៅដំណាក់កាលផ្តោតអារម្មណ៍អ្នកសិក្សាអាចមិនប្រាកដអំពីចំនួនធនធានដែលពួកគេត្រូវការ។ ពួកគេប្រហែលជាមិនដឹងពីរបៀបកំណត់ព័ត៌មានណាដែលមិនទាក់ទងឬមួយណាដែលទាក់ទងនឹងការរិះរករបស់ពួកគេហើយអាចធ្វើឱ្យពួកគេមិនអាចទៅដល់គោលដៅបាន។ នេះគឺជាតួនាទីរបស់គ្រូជាអ្នកសម្របសម្រួល។ ក្នុងនាមជាអ្នកសម្របសម្រួលត្រូវណែនាំពួកគេ និងផ្តល់ឱ្យពួកគេនូវជំនាញនិងយុទ្ធសាស្ត្រត្រឹមត្រូវដើម្បីកំណត់ព័ត៌មានពាក់ព័ន្ធ។

➢ **ដំណាក់កាលដំណើរការ** (Processing Phase)៖

ឥឡូវនេះអ្នករិះរកបានសម្រេចចិត្តលើការផ្តោតអារម្មណ៍របស់ពួកគេហើយពួកគេនឹងអាចសម្រេចចិត្តលើគោលបំណងជាក់លាក់របស់ពួកគេហើយអាចចេញបាននូវចំណូលបញ្ហារបស់ពួកគេ។ ទោះជាយ៉ាងណា នៅដំណាក់កាលនេះព័ត៌មានអាចនឹងមានលក្ខណៈស៊ីជម្រៅពេក ហើយក៏អាចមានភាពច្របូក

ប្រាប់ និងផ្ទុយគ្នាផងដែរ។ ដូច្នេះក្នុងនាមជាអ្នកសម្របសម្រួល ត្រូវណែនាំអ្នកសិក្សាពីរបៀបប្រៀបធៀបផ្ទុយ និងសំយោគទិន្នន័យដើម្បីទទួលបានធនធានព័ត៌មានដែលត្រឹមត្រូវ (Asselin; Branch; &Oberg, (2003)។

➢ **ដំណាក់កាលការបង្កើតថ្មី** (Creating Phase)៖

នៅដំណាក់កាលនេះអ្នករិះរក បានធ្វើការត្រៀមខ្លួនជាស្រេចហើយអាចរៀបចំព័ត៌មានក៏ដូចជាបង្កើតទម្រង់ដើម្បីធ្វើបទបង្ហាញ។ ទោះយ៉ាងណាក្តី ពួកគេមិនប្រាកដអំពីលទ្ធផលរបស់ពួកគេទេហើយត្រូវការការណែនាំពីគ្រូបង្រៀនដែលជាអ្នកសម្របសម្រួលក្នុងការផលិតព័ត៌មាន ឬដំណោះស្រាយដែលអាចទទួលយកបាន។ គ្រូបង្រៀនក៏អាចលើកទឹកចិត្តដល់សកម្មភាពសហប្រតិបត្តិការ និងសហការគ្នាក្នុងចំណោមអ្នកសិក្សាដែលពួកគេអាចត្រូវបានដាក់ជាក្រុមនៅក្នុងកិច្ចខិតខំប្រឹងប្រែងប្រកបដោយការច្នៃប្រឌិតរបស់ពួកគេហើយបង្កើតឡើងនូវធនធានដែលពាក់ព័ន្ធទៅនឹងការពិភាក្សា(McGregor,Dlm Stripling,& Hughes, 2003)។

➢ **ដំណាក់កាលនៃការចែករំលែក**(Sharing Phase)៖

នេះគឺជាដំណាក់កាលដែលអ្នករិះរកនឹងរៀនទាក់ទង និងចែករំលែកការយល់ដឹងថ្មីតាមវិធីផ្សេងៗគ្នាជាមួយមិត្តរួមថ្នាក់របស់ពួកគេដូចជាតាមរយៈបទបង្ហាញគម្រោង។ គ្រូបង្រៀនដែលជាអ្នកសួរសំណួរឱ្យសិស្សរិះរក ក៏នឹងរៀនបង្កើតនូវមតិយោបល់វិជ្ជមាន និងបច្ចេកទេសសំណួរផងដែរ។ ក្នុងន័យនេះចង់បង្ហាញថា កិច្ចខិតខំប្រឹងប្រែងរួមគ្នានឹងត្រូវបានបង្ហាញនៅពេលដែលអ្នករិះរក(សិស្ស) គាំទ្រឱ្យសមាជិកដទៃទៀតក្នុងក្រុមធ្វើការចែករំលែកនូវព័ត៌មានរបស់ពួកគេដោយការចូលរួមពីសមាជិកដទៃទៀត។ វាជារឿងមួយដែលប្រសើរដែលអ្នករិះរក ឬអ្នកស្រាវជ្រាវធ្វើការចែករំលែកនៅក្នុងក្រុមតូចៗ ប្រសើរជាជាង ឱ្យសិស្សម្នាក់ៗធ្វើការចែករំលែកការងាររបស់ពួកគេទៅថ្នាក់ទាំងមូល ពីព្រោះការធ្វើដូចនេះជាញឹកញាប់ច្រើនតែទទួលបានជោគជ័យ និងមានពេលវេលាគ្រប់គ្រាន់ (Asselin; Branch; &Oberg, 2003)។

➢ **ដំណាក់កាលវាយតម្លៃ**( Evaluating Phase)៖

ដើម្បីទទួលបានលទ្ធផលដែលជោគជ័យក្នុងការរិះរក គ្រូត្រូវផ្តល់ឱកាសដល់អ្នករិះរក(សិស្ស) ដើម្បីឆ្លុះបញ្ចាំងពីគំនិតបង្កើតថ្មី និងពិនិត្យមើលការផ្តោតទៅលើការអភិវឌ្ឍរបស់ពួកគេ។ វាចាំបាច់ណាស់ដែលអ្នករិះរក(សិស្ស)ប្រើឧបករណ៍សិក្សាដូចជាក្រាហ្វិច និងបញ្ជីត្រួតពិនិត្យដើម្បីវាយតម្លៃលទ្ធផល និងដំណើរការរបស់ពួកគេ។ អ្នករិះរកក៏ត្រូវបានលើកទឹកចិត្តឱ្យធ្វើការរួមគ្នានៅដំណាក់កាលនេះដើម្បីកែសម្រួលលទ្ធផលគ្នាទៅវិញទៅមក។ វាជារឿងសំខាន់ដែលពេលខ្លះគ្រូបង្រៀនមិនត្រូវធ្វើការវាយតម្លៃផ្តោតតែលទ្ធផលចុងក្រោយ ឬការសង្ខេបចុងក្រោយរបស់អ្នករិះរក(សិស្ស)បានទេ ព្រោះពេលខ្លះសិស្សអាចលួចចម្លងពីក្រុមដទៃទៀតបាន (Mc Gregor,Dlm Stripling,& Hughes,2003)។

## ២.៥. តួនាទីរបស់គ្រូបង្រៀនក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក

បើយោងទៅតាម (Richart & Lockhart, 2007) បាននិយាយថា នៅក្នុងដំណើរការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកគ្រូបង្រៀនមានតួនាទី៤ក្នុងការបង្រៀន និងរៀននៅក្នុងថ្នាក់គឺៈ

**១. គ្រូបង្រៀនគឺជាអ្នកត្រួតពិនិត្យ តាមដាន និងជាអ្នកពន្យល់:** គ្រូជាអ្នកពន្យល់អំឡុងពេលសកម្មភាពបង្រៀន និងរៀនដល់សិស្ស ព្រោះវាជួយឱ្យសិស្សងាយយល់ និងងាយចាប់បាននូវខ្លឹមសារព្រមទាំងពាក្យគន្លឹះ។

**២. គ្រូបង្រៀនគឺជាអ្នកគ្រប់គ្រង និងដឹកនាំ:** គ្រូជាអ្នកគ្រប់គ្រងថ្នាក់ទាំងមូលនៅក្នុងសកម្មភាព រៀន និងបង្រៀន

**៣. គ្រូបង្រៀនគឺជាអ្នកសម្របសម្រួល:** គ្រូជាអ្នកដើរតួយ៉ាងសំខាន់ដើម្បីទៅដល់វត្ថុបំណងមេរៀន និងឱ្យសិស្សចាប់អារម្មណ៍ព្រមទាំងធ្វើការស្វែងយល់នូវខ្លឹមសារមេរៀនបានយល់យ៉ាងងាយ។

**៤. គ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត:** គ្រូជាអ្នកជម្រុញលើកទឹកចិត្តសិស្ស ដើម្បីឱ្យពួកគេមានភាពរីករាយ និងបញ្ញាស្មារតី ដើម្បីរៀនសូត្រ។

ប៉ុន្តែបើយោងទៅតាមខ្លឹមសារនៃសិក្ខាសាលាដែលបានធ្វើនៅខេត្តតាកែវ កាលពីថ្ងៃទី ១៣ ដល់ទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ដែលបានរៀបចំដោយវិទ្យាស្ថានជាតិអប់រំ នាពេលថ្មីៗនេះស្តីអំពីៈ ការបង្រៀន និងរៀនភាសាបរទេសតាមវិធីសាស្ត្របែបរិះរក(Inquiry-Based Language Learning and Teaching) បានបង្ហាញថាតួនាទីរបស់គ្រូ ក្នុងការបង្រៀន និងរៀនតាមបែបរិះរកគឺ ការណែនាំឱ្យសិស្សធ្វើសកម្មភាព និងរៀនដោយខ្លួនឯងជាជាងគ្រូឈរបង្រៀនតែនៅលើឆាក(Sage on the stage)។ គ្រូត្រូវតែជួយដល់ការរៀនរបស់សិស្សនៅពេលដែលសិស្សចាប់ផ្តើមការរៀន និងបង្រៀនតាមវិធីសាស្ត្របែបរិះរកជាលើកដំបូង បន្ទាប់មកគ្រូចាប់ផ្តើមកាត់បន្ថយការជួយបន្តិចម្តងៗរហូតដល់ពួកគេមានការអភិវឌ្ឍនូវជំនាញរបស់ពួកគេបានពេញលេញ មានន័យថាពួកគេអាចរៀនបានដោយខ្លួនឯង ជាពិសេសសម្រាប់កូនសិស្សក្មេងៗដែលថ្មីសម្រាប់ពួកគេក្នុងការរៀនតាមវិធីសាស្ត្រនេះ ហើយផងដែរការទាមទារឱ្យគ្រូបង្រៀនមានការពន្យល់ និងណែនាំច្បាស់លាស់នូវដំណាក់កាលនេះ។ ទន្ទឹមនឹងនោះ ក្នុងនាមជាគ្រូបង្រៀនភាសាអង់គ្លេសម្នាក់ការយល់ដឹងពីតួនាទីរបស់ខ្លួនដើម្បីអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក វាពិតជាមានសារៈសំខាន់ណាស់នូវអ្វីដែលគ្រូត្រូវធ្វើ។ គ្រូបង្រៀនមិនគ្រាន់តែឈរនៅខាងមុខក្តារខៀនហើយពន្យល់នោះទេ ពួកគេក៏ត្រូវដើរតួនាទីជាច្រើន។ យើងកត់សំគាល់ផងដែរថាគ្រូមិនតែងតែនៅចំកណ្តាលថ្នាក់ទេ។ ពេលខ្លះគ្រូស្តាប់ និងជាអ្នកឃ្លាំមើល ជាអ្នកសម្របសម្រួលក្នុងថ្នាក់រៀនដែលផ្តោតសំខាន់ទៅលើសិស្ស។

ក្នុងនោះក៏បានបែងចែក និងនិយាយពីតួនាទីគ្រូបង្រៀន ជាច្រើនក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកដូចខាងក្រោមៈ

**១. ជាអ្នកគ្រប់គ្រង (Manager)៖** គ្រូជាអ្នកត្រួតពិនិត្យតាមក្រុម ជាអ្នកសម្រេចចិត្តទៅលើទំនាក់ទំនងអន្តរកម្មបង្ហាញពីភារៈកិច្ច និងសកម្មភាពដែលត្រូវធ្វើ។ ជាអ្នកអភិវឌ្ឍរបាយការណ៍លើកទឹកចិត្តសិស្ស ផ្តល់ការបង្រៀន ជម្រុញសិស្ស និងលើកសរសើរសិស្ស មិនតែប៉ុណ្ណោះគ្រូបង្រៀនគឺជាអ្នកគ្រប់គ្រងវិន័យក្នុងថ្នាក់ ជាអ្នកទទួលខុសត្រូវរាល់បញ្ហាដែលកើតមាននៅក្នុងថ្នាក់។

**២.ជាអ្នកសម្របសម្រួល** (Facilitator)៖ គ្រូបង្រៀនជាអ្នកអភិវឌ្ឍន៍ស្វ័យភាពអ្នកសិក្សាធ្វើឱ្យអ្នកសិក្សាបំពេញបាននូវសក្តានុពលរបស់ពួកគេព្រមទាំងជួយឱ្យអ្នកសិក្សាទទួលបានតម្លៃ ជាពិសេសផ្តល់ឱកាសដល់សិស្សក្នុងការអភិវឌ្ឍសមត្ថភាពរៀនដោយខ្លួនឯង។

**៣. ជាប្រភពភាសា** (Language Resource)៖ គ្រូបង្រៀនជាអ្នកដែលចេះបត់បែនតាមកាលៈទេសៈមានការពន្យល់និងណែនាំច្បាស់លាស់ ជាអ្នកកែតម្រូវអ្នករៀន និងជាអ្នកបញ្ចូល ព្រមទាំងផ្តល់ភាសាទៅអ្នកសិក្សា។

**៤. ជាអ្នកត្រួតពិនិត្យ តាមដាន** (Monitor)៖ គ្រូធ្វើការអង្កេត និងប្រមូលព័ត៌មានពីអ្នកសិក្សានូវសកម្មភាព ឥរិយាបទ ការរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងដើម្បីវឌ្ឍនភាពក្នុងការរក្សាបាននូវកំណត់ត្រាអំពីកិច្ចការរបស់អ្នកសិក្សា។

**៥. ជាអ្នកឆ្លុះបញ្ចាំង** (Reflector)៖ គ្រូបង្រៀនមានតួនាទីក្នុងការគិតអំពីសកម្មភាពរបស់ខ្លួនផ្ទាល់ និងពីវឌ្ឍនភាពរបស់អ្នកសិក្សា។

**៦. ជាអ្នករៀបចំផែនការ** (Planner)៖ គ្រូគិតអំពីបញ្ហា ដោយធ្វើការសម្រេចចិត្តលើវិធីសាស្ត្រសម្រាប់មេរៀន ដោយមានការរចនារៀបចំ និងកែសម្រួលទាំងអត្ថបទ និងសម្ភារៈបង្រៀន និងរៀន ទន្ទឹមនឹងនោះដែរ ក៏មានការរៀបចំនូវកិច្ចការ និងសម្ភារៈដែលពាក់ព័ន្ធទៅនឹងមេរៀនសម្រាប់បម្រើឱ្យដំណើរការបង្រៀននិងរៀន។

**៧.ជាអ្នកប្រឹក្សា** (Counselor)៖ គ្រូបង្រៀនជាអ្នកផ្តល់ដំបូន្មានដល់អ្នកសិក្សាអំពីការលំបាកដែលពួកគេប្រហែលជាមាននៅខាងក្រៅថ្នាក់ភាសារបស់ពួកគេ។ បង្ហាញការយល់ដឹងទៅលើបញ្ហាដែលអ្នកសិក្សាប្រហែលជាយកមកពីក្រៅចូលក្នុងថ្នាក់រៀន របស់ពួកគេ។

**៨. ជាអ្នកនិទានកថា** (Narrator)៖ គ្រូប្រាប់រឿងនិទាន និងប្រាប់ដល់អ្នកសិក្សាអំពីរឿងដែលបានកើតឡើង។

៩. **ជាអ្នកវាយតម្លៃ** (Assessor)៖ ធ្វើការវាយតម្លៃទៅលើសកម្មភាពរបស់អ្នកសិក្សា ឥរិយាបទ កិច្ចខិតខំប្រឹងប្រែង និងការរួមចំណែករបស់ពួកគេព្រមទាំងមានការត្រួតពិនិត្យការយល់ដឹងធ្វើតេស្តវង្វាយតម្លៃទៅលើវឌ្ឍនភាព និងកម្រិតរបស់អ្នកសិក្សា ទន្ទឹមនឹងនោះ ក៏មានការផ្តល់នូវព័ត៌មានត្រឡប់ទៅលើកិច្ចការភាពរីកចម្រើន ឥរិយាបទ និងការចូលរួមចំណែករបស់អ្នកពួកគេផងដែរ។

១០. **ជាអ្នករួមចំណែកបរិច្ចាក** (Contributor)៖ ធ្វើការដាក់បញ្ចូលគំនិត ឬដាក់ព័ត៌មានផ្សេងៗទៀតក្រៅពីការសិក្សាភាសា។

១១.**ជាអ្នកវិនិច្ឆ័យ** (Diagnostician)៖ ជាអ្នកវាយតម្លៃទៅលើតម្រូវការ និងភាពលំបាករបស់អ្នកសិក្សា។

ក្រៅពីនេះ ដើម្បីអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកគ្រូបង្រៀនមានតួនាទីជាច្រើនទៀត។




រូបភាព២.៥ : Teacher's roles of Inquiry-Based learning and teaching

## ២.៦. តួនាទីរបស់សិស្សក្នុងដំណើរការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក

ចំណែកឯសិស្សវិញ គឺជាអ្នកចូលរួមនៅក្នុងដំណើរការបង្រៀន និងរៀននៅក្នុងថ្នាក់។ សិស្សអាចបញ្ជាក់ពីគំនិតរបស់ពួកគេនូវអ្វីដែលពួកគេចង់រៀន។ ដោយផ្អែកទៅលើបកគំហើញនៃការស្រាវជ្រាវបានបង្ហាញថា សិស្សក៏មានតួនាទី៤ផងដែរ (Richarts &Rodgers, 1999)៖

**១. សិស្សគឺជាអ្នករៀបចំគម្រោង និងផែនការ:** គិតអំពីបញ្ហា ដោយធ្វើការសម្រេចចិត្តលើវិធីសាស្ត្រសម្រាប់មេរៀន។

**២. សិស្សគឺជាសមាជិកនៅក្នុងដំណើរការបង្រៀន និងរៀន:** មានន័យថា សិស្សបានរៀនពីគ្រូ អំឡុងពេលបង្រៀន និងរៀន។ ក្រៅពីនេះ សិស្សផងដែរក៏អាចរៀន ឬសួរពីសិស្សដទៃទៀតនៅក្នុងថ្នាក់(មិត្តរួមថ្នាក់) របស់ពួកគេដើម្បីទទួលបានខ្លឹមសារមេរៀន និងចំណេះដឹងបន្ថែម។ ពួកគេមិនត្រឹមតែស្តាប់ការពន្យល់របស់គ្រូប៉ុណ្ណោះទេថែមទាំងចូលរួមបង្ហាញគំនិត និងយោបល់របស់ពួកគេទៀតផង។

**៣. សិស្សជាអ្នកសំដែង**: សិស្សដែលជាអ្នកសំដែងមានន័យថាពួកគេបានអនុវត្តនិងធ្វើអ្វីមួយដែលបានណែនាំដោយគ្រូ ក្នុងអំឡុងពេលដំណើរ បង្រៀន និងរៀននៅក្នុងថ្នាក់។

**៤. សិស្សគឺជាអ្នកពិនិត្យរាយការណ៍:** សិស្សធ្វើការរាយការណ៍ពីលទ្ធផលដែលពួកគេបានរកឃើញ

## ២.៧. កម្រិតនៃការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក

- **ដែនកំណត់នៃការរិះរក** (Limited Inquiry)**៖** សិស្សានុសិស្ស ត្រូវបានផ្តល់សំណួរ និងវិធីសាស្ត្រដើម្បីឈានទៅដល់ការរកចម្លើយ។ សិស្សានុសិស្សប្រើប្រាស់ជំនាញនៃការគិតបែបស៊ីជម្រៅ និងជំនាញការអង្កេតរបស់ពួកគេក្នុងការរៀនពីការងារវិធីសាស្ត្រមួយនេះ។
- **រចនាសម្ព័ន្ធនៃការរិះរក** (Stuctured Inquiry)**៖** សិស្សានុសិស្សត្រូវបានផ្តល់សំណួរទម្រង់បើក និងវិធីសាស្ត្រស៊ើបអង្កេត។ ពួកគេប្រើប្រាស់ដើម្បីបង្កើតការសន្និដ្ឋានមួយដោយផ្អែកទៅលើភ័ស្តុតាង។

- **ការណែនាំនៃការរិះរក (Guided Inquiry)៖** សិស្សានុសិស្សធ្វើការប្រមូលផ្តុំជាក្រុម ដើម្បីរៀបចំបង្កើតវិធីសាស្ត្រស៊ើបអង្កេត និងពង្រឹងជំនាញដោះស្រាយបញ្ហាដើម្បីឈានទៅដល់ការសន្និដ្ឋានមួយចំពោះសំណួរបែបទម្រង់បើក។
- **ការរិះរកបែបបើកចំហ (Open Inquiry)៖** សិស្សានុសិស្សត្រូវបង្កើតសំនួរផ្ទាល់ខ្លួន បង្កើតវិធីសាស្ត្រស៊ើបអង្កេត បន្ទាប់មកអនុវត្តការស៊ើបអង្កេត។ ពួកគេត្រូវតែបង្ហាញលទ្ធផលរបស់ពួកគេនៅចុងបញ្ចប់នៃដំណើរការនៃការរិះរក

## ២.៨. សារៈប្រយោជន៍នៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក

- IBL អាចបត់បែនបាន និងអាចសម្របខ្លួនបានសម្រាប់គម្រោងផ្សេងៗគ្នា។
- IBL ជួយកសាងការគោរពខ្លួនឯងតាមរយៈការអនុញ្ញាតឱ្យពួកគេកាន់តែសកម្មក្នុងដំណើរការរៀនសូត្រដោយខ្លួនឯង ជាជាងអសកម្មតាមរយៈវិធីសាស្ត្របង្រៀនបែបប្រពៃណី។
- IBL ពង្រឹង និងកសាងជំនាញជាច្រើនរបស់សិស្សានុសិស្សផ្នែករាងកាយ ផ្លូវចិត្តនិងការយល់ដឹង។
- IBL ជួយសិស្សអភិវឌ្ឍន៍ជាអ្នកគិតពិចារណា ដោយខ្លួនឯង។
- IBL លើកកម្ពស់សកម្មភាពនៃបញ្ញាត្តិការសួរសំណួរ។
- IBL ជួយឱ្យសិស្សមានការចង់ដឹង ចង់ឃើញនិងស្រឡាញ់ការសិក្សារបស់សិស្ស។
- IBL បញ្ជាក់ពីសារសំខាន់នៃការសួរសំណួរល្អៗ
- IBL បណ្តុះសិស្សឱ្យចេះ គិត និងបង្កើតថ្មី
- IBL បណ្តុះសិស្សឱ្យសិស្សចេះ អង្កេត រិះរក និងដោះស្រាយបញ្ហាប្រកបដោយនវានុវត្តន៍
- IBL ជួយអភិវឌ្ឍន៍សមត្ថភាពសិស្សានុសិស្សក្នុងការគិតបែបស៊ីជម្រៅ( Critical Thinking )

- IBL ជួយពង្រឹងជំនាញក្នុងការដោះស្រាយបញ្ហាដល់សិស្ស  និងជំនាញក្នុងការរៀនពេញមួយជីវិត (problem-solving abilities and develop skills for lifelong learning).
- IBL ផ្ទេរការរៀនទៅជីវិតពិតពិសេសធ្វើឱ្យសិស្សកាន់តែសប្បាយ និងក្លាយជាអ្នកចេះច្នៃប្រឌិត

# ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត" មានគោលបំណងសិក្សាពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកនៅមធ្យមសិក្សាទុតិយភូមិ និងសិក្សាពីបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១. គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ ៣ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សុីគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅមធ្យមសិក្សាទុតិយភូមិចំនួន ៥វិទ្យាល័យ ក្នុងខេត្តកំពត និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន ៣ប្រភេទ គឺគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

## ៣.២. ការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ គ្រូបង្រៀនតាមសាលារដ្ឋ បានចាប់ផ្តើមបង្រៀន និងដឹកនាំសិស្សឲ្យរៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡាលេខ ១៩៧ វជអ.ផក ចុះថ្ងៃពុធ ១០រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃ

ទី១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យតាមប្រពន្ធអនឡាញ (ONLINE Google Form) ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

ក្រោយពីបានឆ្លងយោបល់ក្នុងក្រុបខណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំនួរ ដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ មានភាពសហការល្អអាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលារៀន ដើម្បីចែកកម្រងសំនួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបនាយកសាលានីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាត ជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរ ដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស ដោយមានកំណត់ពេលវេលាជាក់លាក់។ ការចុះប្រមូលទិន្នន័យ គឺមានភាពបត់បែនទៅតាមទីតាំងភូមិសាស្ត្ររបស់សាលារៀន និងផ្តល់អាទិភាពដល់អ្នកផ្តល់ទិន្នន័យ តាមរយៈការចុះទៅជួបផ្ទាល់ដល់គេហដ្ឋានរបស់សំណាក ដើម្បីផ្តល់ និងប្រមូលកម្រងសំណួរ ក្រៅពីចុះទៅដល់ផ្ទាល់តាមសាលាគោលដៅ ឬតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមនានាមាន Google form, តេលេក្រាម, ទូរស័ព្ទ និង Facebook ជាដើម។

ការបំពេញទិន្នន័យក្នុងកម្រងសំណួរ មានរយៈពេលមួយសប្តាហ៍ អ្នកសិក្សាស្រាវជ្រាវ បានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតប ទៅតាមពេលកំណត់ជាក់លាក់។ ក្នុងអន្តរកាល នៃការរក្សាគម្លាតសង្គម ការចុះប្រមូលទិន្នន័យបានជួបបញ្ហាមួយចំនួនផងដែរ ទាំងផ្នែកបច្ចេកទេស បណ្តាញទំនាក់ទំនងសង្គម និងកិច្ចសហការពីអ្នកឆ្លើយតប។ ក្នុងការចុះប្រមូល ទិន្នន័យបានប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ គិតចាប់ពីចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំនួរទាំងអស់ពី គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានៈ "ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត" អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរចំនួន៣ប្រភេទ ក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានា ដែលមានដូចជាៈ ការអនុវត្តកម្មវិធីសិក្សាស្តង់ដានាយកសាលារៀន សៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ កម្មវិធីសិក្សាពលរដ្ឋពេញលេញ និងការធានាគុណភាពអប់រំជាដើម ដើម្បីសិក្សាពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅមធ្យមសិក្សាទុតិយភូមិ និងសិក្សាពីបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក(IBL)ទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពត។

### ៣.៣.១. កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំនួរនីមួយៗ មានចំនួន៥កម្រិត ពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥)។ រូបមន្តនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោម៖

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ ពុំមានយោបល់

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើ ពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត-ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

| | | |
|---|---|---|
| 1.00 — 1.80 | មានន័យថា | ខ្សោយខ្លាំង |
| 1.81 — 2.60 | មានន័យថា | ខ្សោយ |
| 2.61 — 3.40 | មានន័យថា | មធ្យម |
| 3.41 — 4.20 | មានន័យថា | ល្អ |
| 4.21 — 5.00 | មានន័យថា | ល្អណាស់ |

### ៣.៣.២. កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅមធ្យមសិក្សាទុតិយភូមិ និងសិក្សាពីបញ្ហាប្រឈមនៅក្នុង

ការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក(IBL)ទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តកំពត។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់ ការងារអនុវត្តវិធីសាស្ត្របង្រៀនមុខវិជ្ជាភាសាអង់គ្លេសតាមបែបរិះរក។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះ តែប៉ុណ្ណោះ។

### ៣.៣.២.១.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាទុតិយភូមិ

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៨សំណួរ ទាក់ទងទៅនឹងកន្លែងបម្រើការងារ ឈ្មោះសាលារៀន រយៈពេលបម្រើការងារ ប្រភេទក្របខណ្ឌ ភេទ កម្រិតវប្បធម៌ អាយុ និងបទពិសោធន៍ការងារ។

ជាលទ្ធផល(**ឧបសម្ព័ន្ធ "ខ"**)បានបង្ហាញថា គណៈគ្រប់គ្រង ដែលបានបម្រើការងារជានាយកភាគច្រើនចន្លោះពី១ ដល់៥ឆ្នាំ មានចំនួន៦ នាក់ស្មើរនឹង៤៣%។ រីឯគណៈគ្រប់គ្រងដែលបម្រើការជានាយករយៈពេលចន្លោះពី៦ ដល់១០ឆ្នាំ មានតែ ៧%ប៉ុណ្ណោះ។ ទន្ទឹមនឹងនោះគណៈគ្រប់គ្រងបម្រើការងារលើសពី១៦ឆ្នាំមាន២៩% ។ ក្រៅពីនោះគឺបម្រើការងារចន្លោះពី១១ ដល់១៥ឆ្នាំ មាន២១%។

**ប្រភេទក្របខណ្ឌ៖** គណៈគ្រប់គ្រងជាគ្រូកម្រិតឧត្តមមានចំនួន៩នាក់ក្នុងចំណោម១៤នាក់ស្មើរនឹង៦៤%។ ក្រៅពីនោះគឺជាគ្រូកម្រិតមូលដ្ឋាន។

**ភេទ៖** គណៈគ្រប់គ្រងដែលចូលរួមក្នុងការឆ្លើយក្នុងកម្រងសំណួរជាបុរសមានចំនួន១១នាក់ ស្មើរនឹង៧៩% ក្នុងចំណោមគណៈគ្រប់គ្រង១៤នាក់។ ក្រៅពីនោះគណៈគ្រប់គ្រងជានារី។

កម្រិតសញ្ញាបត្រ៖ គណៈគ្រប់គ្រងដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់(អនុបណ្ឌិត) មានចំនួន១០ នាក់ស្មើរនឹង ៧១% ក្រៅពីនោះមានសញ្ញាបត្របរិញ្ញាបត្រ។

**អាយុ៖** គណៈគ្រប់គ្រងភាគច្រើន មានអាយុលើស៤០ឆ្នាំ ដែលគិតជាភាគរយស្មើនឹង៧១% ហើយគណៈគ្រប់គ្រងភាគតិច មានអាយុចន្លោះពី៣១ ដល់៣០ ឆ្នាំ និងចន្លោះពី៣៦ ដល់៤០។

**បទពិសោធន៍គណៈគ្រប់គ្រង៖** គណៈគ្រប់គ្រង ដែលមានបទពិសោធន៍ក្នុងការគ្រប់គ្រង និងដឹកនាំភាគច្រើនគឺលើសពី១៥ ឆ្នាំមានចំនួន៩នាក់ក្នុងចំណោម១៤នាក់ស្មើនឹង ៦៤%។ ចំណែកឯគណៈគ្រប់គ្រងភាគតិចគឺ មានបទពិសោធន៍ចន្លោះពី៦ ដល់១០ឆ្នាំ ស្មើនឹង៧%។ ទន្ទឹមនឹងនោះ គ្មានគណៈគ្រប់គ្រងណាមានបទពិសោធន៍ ចន្លោះពី១ ដល់៥ឆ្នាំទេ។ ក្រៅពីនោះគឺមានបទពិសោធន៍ចន្លោះពី ១១ ដល់១៥ឆ្នាំ។

**ផ្នែកទី២៖ ការពិនិត្យតាមដានស្ថានភាពលើការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) របស់គ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត**

មានសមាសភាគចំនួន៤ គឺការរៀបចំផែនការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា (៧សំណួរ) ពិនិត្យតាមដានលើការអនុវត្តវិធីសាស្ត្របង្រៀន(៧សំណួរ) ការប្រើប្រាស់សម្ភារឧបទេស(៥សំណួរ) និងលទ្ធផលសិក្សារបស់សិស្ស(៨សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃឥរិយាបថរបស់ថ្នាក់ដឹកនាំ និងគ្រប់គ្រងសាលារៀន ដែលអាចជះឥទ្ធិពលដល់ការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសតាមបែបរិះរកនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែម ពីការឆ្លើយតបរបស់គណៈគ្រប់គ្រង នៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.២. កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំនួរគ្រូ គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីគ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិ ដែលកំពុងបង្រៀនពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៧សំណួរ ទាក់ទងទៅនឹងស្ថានភាពដែលជាគ្រូបង្រៀន កំពុងបង្រៀននៅមធ្យមសិក្សាទុតិយភូមិមានដូចជា៖ កន្លែងបម្រើការងារ ឈ្មោះសាលារៀន បង្រៀនថ្នាក់ទីប៉ុន្មាន ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ។

ជាលទ្ធផល (**ឧបសម្ព័ន្ធ "ឃ"**)បានបង្ហាញថា គ្រូភាសាអង់គ្លេសភាគច្រើនគឺ បង្រៀនថ្នាក់ទី១២ ដែលក្នុងនោះមាន៧នាក់ក្នុងចំណោម១៨នាក់ ស្មើរនឹង៣៩%។ រីឯគ្រូបង្រៀនភាសាអង់គ្លេសភាគតិចគឺ បង្រៀនថ្នាក់ទី១១ មានចំនួន៥នាក់ក្នុងចំណោម១៨នាក់ ស្មើរនឹង ២៨%។ ក្រៅពីនោះជាគ្រូបង្រៀនថ្នាក់ទី១០។

**ភេទ៖** គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើន ជាគ្រូបុរសមានចំនួន១៦ នាក់ ក្នុងចំណោម១៨នាក់ ស្មើរនឹង៨៩%។ ក្រៅពីនោះជាគ្រូបង្រៀនជា នារី។

**អាយុ៖** គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើន មានអាយុ លើសពី៣៥ ឆ្នាំ មានចំនួនរហូតដល់១១ នាក់ក្នុងចំណោម១៨នាក់ គិតជាភាគរយស្មើរនឹង ៦១%។ រីឯគ្រូបង្រៀនភាគតិចមានអាយុចន្លោះពី ២៤ ដល់ ២៩ឆ្នាំ មាន៦% ខណៈដែលគ្មានគ្រូបង្រៀនណាម្នាក់មានអាយុចន្លោះពី១៨ ដល់២៣ឆ្នាំទេ។ ក្រៅពីនោះជាគ្រូបង្រៀនមានអាយុចន្លោះពី ៣០ដល់៣៥ឆ្នាំ ដែលមានតែ៦នាក់ក្នុងចំណោម១៨នាក់ស្មើរនឹង ៣៣%។

**កម្រិតសញ្ញាបត្រ៖** គ្រូបង្រៀនភាគច្រើនគឺ មានសញ្ញាបត្របរិញ្ញាបត្រដែលមានចំនួនរហូតដល់១៣ នាក់ក្នុងចំណោម១៨នាក់ ស្មើរនឹង ៧២%។ ចំណែកឯ គ្រូភាគតិចមានកម្រិតសញ្ញាបត្រត្រឹមតែ បរិញ្ញាបត្ររង និងថ្នាក់ទី១២ ប៉ុណ្ណោះខណៈដែលគ្មានគ្រូបង្រៀនណាម្នាក់មានសញ្ញាបត្របណ្ឌិត។ ក្រៅពីនោះ គ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន១៧%។

**បទបិសោធន៍បង្រៀន៖** គ្រូបង្រៀនដែលមានបទពិសោធន៍ក្នុងការបង្រៀនភាសាអង់គ្លេសភាគច្រើន ចន្លោះពី ៦ ដល់១០ឆ្នាំ មាន៧នាក់ស្មើរនឹង៣៩%។ រីឯគ្រូបង្រៀនភាគតិចដែលមានបទពិសោធន៍ចន្លោះ

ពី១ដល់៥ឆ្នាំ និងលើសពី១៥ឆ្នាំ មានត្រឹមតែ ១៧%។ ក្រៅពីនោះជាគ្រូបង្រៀនដែលមានបទពិសោធន៍ ១១ ដល់១៥ឆ្នាំ មានចំនួន៥ នាក់ក្នុងចំណោម១៨ នាក់ស្មើរនឹង ២៨%។

**ផ្នែកទី២៖ ស្ថានភាពលើការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) របស់គ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត**

មានសមាសភាគចំនួន៤ គឺការអនុវត្តកម្មវិធីសិក្សា (៨សូចនាករ) ដំណើរការបង្រៀន (៧សូចនាករ) ទំនាក់ទំនងគ្រូ-សិស្ស (៧សូចនាករ) និងការប្រើប្រាស់សម្ភារឧបទេស (៥សូចនាករ) ជាឧបករណ៍សម្រាប់វាស់ពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) របស់គ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀន នៅផ្នែកទី២ ស្តីពី "ការអនុវត្តកម្មវិធីសិក្សាទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនតាមបែបរិះរក" ដំណើរការបង្រៀនដោយអនុវត្តទៅតាមវិធីសាស្ត្របង្រៀនតាមបែបរិះរក "ទំនាក់ទំនងរវាងគ្រូ-សិស្សក្នុងពេលអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក" និង"ការរៀបចំសម្ភារឧបទេសសម្រាប់បង្រៀនតាមវិធីសាស្ត្របែបរិះរក" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងស៊ីជម្រៅ។

**ផ្នែកទី៣៖ បញ្ហាប្រឈមក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកលើមុខវិជ្ជាភាសាអង់គ្លេស**

មាន៧សំណួរទាក់ទងទៅនឹងបញ្ហាប្រឈមនានាក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក។ កម្រងសំណួរនេះជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមផ្សេងៗដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀនភាសាអង់គ្លេស នៅផ្នែកទី៣ ស្តីពី "តើលោកគ្រូ អ្នកគ្រូបានជួបប្រទះបញ្ហាអ្វីខ្លះ ក្នុងពេលអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.៣. កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរសិស្ស គឺប្រើសម្រាប់ប្រមូលទិន្នន័យពីសិស្សដែលកំពុងរៀនពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ អំពីកម្រិតពេញចិត្តបំពេញ រៀនមុខវិជ្ជាភាសាអង់គ្លេស និងឆ្លុះបញ្ចាំងពីស្ថានភាព ក៏ដូចជាបញ្ហាប្រឈមនានាក្នុងការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបវិរះកនៅវិទ្យាល័យរដ្ឋក្នុងខេត្តកំពត ដែលចែកចេញជា ២ផ្នែកគឺះ

**ផ្នែកទី១ះព័ត៌មានទូទៅ**

មាន៥សំណួរ ទាក់ទងទៅនឹងទីកន្លែងសិក្សា ឈ្មោះវិទ្យាល័យ រៀនថ្នាក់ទី ភេទ និងអាយុ។

ជាលទ្ធផល(**ឧបសម្ព័ន្ធ "ច"**) បានបង្ហាញថា សិស្សដែលបានចូលរួមឆ្លើយកម្រងសំណួរ ភាគច្រើនគឺថ្នាក់ទី១២ ដែលមានចំនួន៣៣នាក់ក្នុងចំណោម៩០នាក់ ស្មើរនឹង ៣៧% ខណៈដែលសិស្សថ្នាក់ទី១១ មានត្រឹមតែ ២៥នាក់ស្មើរនឹង ២៧%។ ក្រៅពីនោះគឺជាសិស្សថ្នាក់ទី១០ ដែលមាន៣២នាក់ស្មើរនឹង ៣៦%។

**ភេទះ** សិស្សភាគច្រើនដែលចូលរួមឆ្លើយកម្រងសំណួរ ជាភេទនារី ដែលមានរហូតដល់ ៦៦នាក់ ស្មើរនឹង ៧៣%។ ក្រៅពីនោះ ជាភេទបុរសដែលមានត្រឹមតែ ២៤នាក់ស្មើរនឹង ២៧% ប៉ុណ្ណោះ។

**អាយុះ** សិស្សភាគច្រើនមានអាយុ ចន្លោះពី១៦ដល់ ២០ ឆ្នាំដែលបានចូលរួមឆ្លើយកម្រងសំណួរ ដែលអ្នកស្រាវជ្រាវបានដាក់ឱ្យមានរហូតដល់៧២ នាក់ស្មើរនឹង៨០%។ ទន្ទឹមនឹងនោះ គ្មានសិស្សណាម្នាក់មានអាយុលើសពី២០ ឆ្នាំទេ។ ក្រៅពីនោះ សិស្សភាគតិច មានអាយុ ចន្លោះពី១០ដល់១៥ឆ្នាំដែលមានត្រឹមតែ ១៨ នាក់ក្នុងចំណោម៩០ នាក់ដែលគិតជាភាគរយស្មើរនឹង ២០%ប៉ុណ្ណោះ។

**ផ្នែកទី២ះ ការឆ្លើយតបសិស្សលើការបំពេញការងាររបស់គ្រូបង្រៀន និងស្ថានភាពការអនុវត្តវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសតាមបែបវិរះក**

មានសមាសភាគចំនួន២ គឺអំពីការបង្រៀន (៩សូចនាករ) និងអំពីសកម្មភាពរបស់សិស្សរៀននៅក្នុងថ្នាក់ (៧សូចនាករ) ជាឧបករណ៍សម្រាប់វាស់ពីពីការពេញចិត្តរបស់សិស្សទៅលើការបំពេញការងារ

របស់គ្រូបង្រៀន និងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក។ អ្នកសិក្សាស្រាវជ្រាវបាន ស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់សិស្សនៅផ្នែកទី២នេះ ទៅលើការបង្រៀន និងរៀន ព្រម ទាំងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យការចុះ ប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងស៊ីជម្រៅបន្ថែមទៀត។

## ៣.៤. ការជ្រើសរើសគំរូតំណាង

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងចំនួន៥ មធ្យមសិក្សាទុតិយភូមិ នៅខេត្តកំពត ដែល មានចំនួនសំណាកសរុប ១២២នាក់ ដែលក្នុងនោះមានគណៈគ្រប់គ្រងសាលារៀនចំនួន១៤នាក់ លោក គ្រូ-អ្នកគ្រូបង្រៀនភាសាអង់គ្លេស ចំនួន១៨នាក់ និងសិស្សានុសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ( ថ្នាក់ទី ១០ ដល់ថ្នាក់ទី១២ ) ចំនួន៩០នាក់ ។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និង ចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក គំលាតស្តង់ដា និងកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត ដោយ គណនាតាមរូបមន្តកំណត់ជាក់លាក់។

ស្ថានភាពនៅពេលចុះប្រមូលទិន្នន័យគឺ ឋិតក្នុងបរិបទនៃការរក្សាគម្លាតសង្គម ដោយសារជំងឺកូវីដ-១៩។ វិទ្យាល័យមួយចំនួននៅក្នុងខេត្តកំពត មានស្ថានភាពទីតាំងភូមិសាស្ត្រខុសគ្នា ទៅតាមស្រុក នីមួយៗ ដោយវិទ្យាល័យឋិតក្នុងក្រុងមានភាពរីកចម្រើន វិទ្យាល័យខ្លះមានកម្រិតមធ្យម ហើយក៏មាន វិទ្យាល័យខ្លះទៀតស្ថិតនៅក្នុងតំបន់ជនបទ។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសក្រុង/ស្រុកចំនួន ៤ ក្នុងខេត្តកំពត គឺ៖ ក្រុងកំពត ស្រុកទឹកឈូ ស្រុកកំពង់ត្រាច និងស្រុកបន្ទាយមាស។ ការចុះប្រមូល ទិន្នន័យ តាមរយៈកម្រងសំណួរនៅមធ្យមសិក្សាទុតិយភូមិចំនួន៦ មានសំណាកសរុបចំនួន ១០០នាក់ បែងចែកជា គណៈគ្រប់គ្រងសាលារៀនចំនួន១៤នាក់ គ្រូបង្រៀនទុតិយភូមិចំនួន១៨នាក់ និងសិស្ស ចំនួន៩០នាក់( រៀនភាសាអង់គ្លេសថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ )។

តារាង៣.១៖ ចំនួនភាគសំណាក ដើម្បីប្រមូលទិន្នន័យតាមវិទ្យាល័យនានាក្នុងខេត្តកំពត

| ភាគសំណាក (Sample) | ថ្នាក់ | តំបន់ទីប្រជុំជន | | តំបន់ដាច់ស្រយាល | | | សរុប |
|---|---|---|---|---|---|---|---|
| | | វិ.មិត្តភាពកម្ពុជា-ជប៉ុន កំពតក្រុង | វិ.ព្រះនរោត្តម រណឫទ្ធិ | វិ.ព្រះបិតាជាតិ | វិ.សម្តេចហ៊ុន សែនអង្គសុរភី | វិ.ហ៊ុនសែន បរិវាស | |
| គណៈគ្រប់គ្រងសាលា | N/A | ០៣នាក់ | ០៣នាក់ | ០៣នាក់ | ០២នាក់ | ០៣នាក់ | ១៤នាក់ |
| គ្រូបង្រៀនភាសាអង់គ្លេស | ទី១០ | ០១នាក់ | ០២នាក់ | ០១នាក់ | ០១នាក់ | ០១នាក់ | ០៦នាក់ |
| | ទី១១ | ០១នាក់ | ០១នាក់ | ០១នាក់ | ០១នាក់ | ០១នាក់ | ០៥នាក់ |
| | ទី១២ | ០២នាក់ | ០១នាក់ | ០១នាក់ | ០១នាក់ | ០២នាក់ | ០៧នាក់ |
| សិស្ស | ទី១០ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ៣០នាក់ |
| | ទី១១ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ៣០នាក់ |
| | ទី១២ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ០៦នាក់ | ៣០នាក់ |
| **ភាគសំណាកសរុប** | | | | | | | **១២២នាក់** |

## ៣.៥. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នក

សិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីភាគរយ ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដា ដើម្បីបកស្រាយទិន្នន័យតាមសូចនាករនីមួយៗ។ ការវិភាគលើមតិយោបល់បន្ថែមគឺអ្នកសិក្សាបានចាប់ក្រុមពាក្យទៅតាមទស្សនៈយល់ឃើញនីមួយៗ ពីការបំពេញកម្រងសំណួរ ព្រមទាំងធ្វើការផ្ទុះបញ្ចាំងទៅនិងមធ្យមភាគដែលទទួលបាន និងស្រង់ជាតុចូលមួយចំនួនពីអ្នកឆ្លើយតប ដាក់ក្នុងសំណូមពរ។

# ជំពូកទី៤

# លទ្ធផលការស្រាវជ្រាវ

# និង

# ការពិភាក្សា

# ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកទី៤ នេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ការបកស្រាយ និងការពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងការសម្ភាសរបស់ជាតុសំណាកដែលរួមមានលោកនាយក នាយករង នាយិកា នាយិការង លោកគ្រូ គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សថ្នាក់ទី១០ ទី១១ និងទី១២ ទៅលើប្រធានបទ "**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ**"។ ហើយរាល់ចំណុចសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងប្រធានបទត្រូវបានលើកយកមកបកស្រាយ និងពិភាក្សា។ កម្មវិធី Ms. Excel ត្រូវបានប្រើសម្រាប់បញ្ចូលទិន្នន័យ វិភាគ និងសង់តារាង បន្ទាប់មកធ្វើការបកស្រាយ។ ដោយយកទិន្នន័យចេញពីកម្មវិធី Ms. Excel ដើម្បីស្វែងយល់ពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក របស់លោកគ្រូ អ្នកគ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ បានធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួររបស់អ្នកចូលរួម។ ការវិភាគលើកម្រងសំណួរ មានគោលបំណង ស្វែងរកពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ទន្ទឹមនឹងនោះ អ្នកសិក្សាស្រាវជ្រាវក៏ធ្វើការសិក្សាស្វែងយល់ពីបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរករបស់លោកគ្រូ អ្នកគ្រូបង្រៀនដែលកំពុងបង្រៀនភាសាអង់គ្លេសផងដែរ។ ។ ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធនានាដូចជា៖ នាយក នាយករង នាយិការង លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្ស(កម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២) ត្រូវបានវិភាគ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក ហើយលទ្ធផលនៃការពិភាក្សានេះ គឺធ្វើឡើងតំណាងឱ្យទិដ្ឋភាពរួមនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀន ភាសាអង់គ្លេសនៅគ្រឹះស្ថានសិក្សាសាធារណៈនានាក្នុងខេត្តកំពត។

### ៤.១. លទ្ធផលនៃការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសក្រុមគោលដៅ និងត្រូវទៅតាមលក្ខខណ្ឌកំណត់នៅក្នុងគម្រូជ្រើសរើសដូចជា៖ ថ្នាក់ដឹកនាំសាលារៀន(នាយក/នាយិកា និងនាយករង/នាយិការង) គ្រូបង្រៀន (គ្រូបង្រៀនមុខវិជ្ជាឯកទេសភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២) និងសិស្សានុសិស្សតាមវិទ្យាល័យគោលដៅទាំងអស់(ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២) នឹងត្រូវជ្រើសរើសជាគំរូសម្រាប់ធ្វើការសិក្សាស្រាវជ្រាវនេះ។ ដូច្នេះភាគរយនៃផលធៀបភេទ និងអាយុរបស់អ្នកចូលរួមមិនត្រូវបានធ្វើការកំណត់ទុកជាមុនឡើយ។ ជាលទ្ធផល យើងទទួលបានអ្នកចូលរួមសរុបចំនួន ១២២នាក់ដែលរួមមាន៖ គណៈគ្រប់គ្រងសាលារៀនចំនួន ១៤នាក់ គ្រូបង្រៀនមុខវិជ្ជាឯកទេសភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២ ចំនួន១៨នាក់ និងសិស្សានុសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន ៩០នាក់។ ហើយកម្រងសំណួរទាំងអស់ដែលបានចែកជូនដល់អ្នកពាក់ព័ន្ធមានចំនួន ១២២ច្បាប់ បានប្រគល់ត្រឡប់មកវិញចំនួន១២២ ច្បាប់គ្រប់ចំនួនមិនមានការខកខានមិនបានចូលរួមបំពេញនោះទេ សម្រាប់វិទ្យាល័យចំនួន ០៥ ក្នុងចំណោមវិទ្យាល័យទូទាំងខេត្តកំពត។

### ៤.២. ស្ថានភាពនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) របស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិសម្រាប់គ្រូបង្រៀន

#### ៤.២.១. ការឆ្លើយតបរបស់គ្រូបង្រៀនភាសាអង់គ្លេសទៅលើស្ថានភាពនៃការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក(Inquiry Based Learning)

**តារាង៤.១៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនស្តីពីការអនុវត្តកម្មវិធីសិក្សា**

| ល.រ | បរិយាយលើការអនុវត្តកម្មវិធីសិក្សា | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មុខវិជ្ជាភាសាអង់គ្លេសបានបង្រៀនចប់ តាមកម្មវិធីសិក្សា | ៣.៣៩ | 0.៣៩ | មធ្យម |
| ២ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជាភាសាអង់គ្លេស | ៤.0៦ | 0.៣៨ | ល្អ |
| ៣ | បានរៀបចំបំណែងចែកមេរៀន តាមកាលវិភាគយ៉ាងត្រឹមត្រូវ | ៤.១៧ | 0.៤0 | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | មានបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស | ៤.១៧ | 0.៤១ | ល្អ |
| ៥ | សៀវភៅពុម្ពសិក្សាសមស្របជាមួយកម្រិតយល់ដឹងរបស់សិស្ស | ៣.00 | 0.៤២ | មធ្យម |
| ៦ | បានរៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆមាស | ៣.៩៤ | 0.0៨ | ល្អ |
| ៧ | បានស្រាវជ្រាវបន្ថែមលើចំណេះដឹង ជំនាញវិជ្ជាជីវៈរបស់ខ្លួន | ៤.00 | 0.0៨ | ល្អ |
| ៨ | កិច្ចតែងការបង្រៀនបានពិនិត្យដោយគណៈគ្រប់គ្រង | ៣.៩៤ | 0.0៨ | ល្អ |
| | **សរុប** | **៣.៨៣** | **0.២៨** | **ល្អ** |

តាមតារាងទិន្នន័យ៤.១ បានបង្ហាញពីមធ្យមភាគសរុបនៃ ការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេស គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៣)។ សូចនាករ "មានបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស" និងសូចនាករ "បានរៀបចំបំណែងចែកមេរៀន តាមកាលវិភាគយ៉ាងត្រឹមត្រូវ" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេស ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៧) និង សូចនាករ "សៀវភៅពុម្ពសិក្សា សមស្របជាមួយកម្រិតយល់ដឹងរបស់សិស្ស" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.00)។

**តារាង៤.២៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀន ស្តីពីដំណើរការបង្រៀនតាមវិធីសាស្ត្របែបរិះរក**

| ល.រ | បរិយាយពីដំណើរការបង្រៀន | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បានរៀបចំកិច្ចតែងការ តាមវិធីសាស្ត្ររិះរក | ៣.៤៤ | 0.១៧ | ល្អ |
| ២ | បានអនុវត្តតាមគ្រប់ជំហានទាំង៥ នៃវិធីសាស្ត្របង្រៀនរិះរក | ៣.៣៩ | 0.១៦ | មធ្យម |
| ៣ | បានឱ្យសិស្សសង្កេត និងប្រមូលព័ត៌មានទាក់ទងទៅនឹងសំណួរគន្លឹះ | ៣.៧២ | 0.0៨ | ល្អ |
| ៤ | បានបែងចែកក្រុមកិច្ចការ ដល់សិស្សសម្រាប់សកម្មភាពក្នុងថ្នាក់ | ៣.៧៨ | 0.0៨ | ល្អ |
| ៥ | បានអោយសិស្សឆ្លុះបញ្ចាំង ពីការរិះរកនូវអ្វីដែលរកឃើញ | ៣.៧៨ | 0.0៩ | ល្អ |
| ៦ | គ្រូ និងសិស្សបានដឹងពីតួនាទីរបស់ខ្លួន នៅពេលអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក | ៣.៧២ | 0.១២ | ល្អ |

| | | | | |
|---|---|---|---|---|
| ៧ | បានពន្យល់ និងបំណកស្រាយមេរៀនដោយអនុវត្តទៅតាមជំហាននៃវិធីសាស្ត្រតាមបែបរិះរក ជាប្រចាំ | ៣.៨៩ | 0.១៦ | ល្អ |
| | **សរុប** | **៣.៦៧** | **0.១២** | **ល្អ** |

តាមតារាងទិន្នន័យ៤.២ បានបង្ហាញពីមធ្យមភាគសរុបនៃ ដំណើរការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេស គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៦៧)។ សូចនាករទី៧ "បានពន្យល់ និងបំណកស្រាយមេរៀនដោយអនុវត្តទៅតាមជំហាននៃវិធីសាស្ត្រតាមបែបរិះរក ជាប្រចាំ" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើដំណើរការបង្រៀនដោយអនុវត្តតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ អ្នកគ្រូភាសាអង់គ្លេស ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៩) និងសូចនាករទី២"បានអនុវត្តតាមគ្រប់ជំហានទាំង៥ នៃវិធីសាស្ត្របង្រៀនបែបរិះរក" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣៩)។

**តារាង៤.៣៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀន ស្តីពីទំនាក់ទំនងរវាងគ្រូ-សិស្ស**

| ល.រ | បរិយាយពីទំនាក់ទំនងគ្រូ-សិស្ស | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស | ៤.00 | 0.0៧ | ល្អ |
| ២ | បង្កបរិយាកាសឱ្យសិស្សចេះរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុម | ៣.៨៩ | 0.0៧ | ល្អ |
| ៣ | បានជំរុញការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណារបស់សិស្ស | ៣.៨៩ | 0.0៧ | ល្អ |
| ៤ | បានជម្រុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សាតាមIBL | ៣.៧៨ | 0.0៨ | ល្អ |
| ៥ | ជម្រុញការចូលរួមយ៉ាងសកម្ម របស់សិស្សក្នុងសកម្មភាពសិក្សា | ៣.៩៤ | 0.0៥ | ល្អ |
| ៦ | បានបង្កើនភាពសហការគ្នាក្នុងដំណើរការបង្រៀន និងរៀន | ៣.៨៩ | 0.0៦ | ល្អ |
| ៧ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | ៤.00 | 0.0៦ | ល្អ |
| | **សរុប** | **៣.៩១** | **0.0៧** | **ល្អ** |

តាមតារាងទិន្នន័យ៤.៣ បានបង្ហាញពីមធ្យមភាគសរុបនៃការទំនាក់ទំនងរវាងគ្រូ-សិស្ស ក្នុងការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេស គឺយល់ស្របក្នុង

កម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩១)។ សូចនាករទី១ "បានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស" និងសូចនាករទី៧ "បានផ្ដល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើការទំនាក់ទំនងរវាងគ្រូ-សិស្ស ក្នុងការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសស្ថិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.00)។ សូចនាករទី៤ "បានជម្រុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សាតាមរិះរក(IBL)" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៧៨)។

**តារាង៤.៤៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀន ស្ដីពីការប្រើប្រាស់សម្ភារឧបទេស**

| ល.រ | បរិយាយការប្រើប្រាស់សម្ភារឧបទេស | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មានសម្ភារៈឧទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្របែបរិះរក | ២.៩៤ | 0.៣២ | មធ្យម |
| ២ | បានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក | ៣.៥៦ | 0.២២ | ល្អ |
| ៣ | សម្ភារឧបទេស បានជួយអោយការសិក្សារីកចម្រើន | ៣.៨៩ | 0.២៦ | ល្អ |
| ៤ | បានប្រើប្រាស់សម្ភារឧបទេស ក្នុងការបង្រៀនតាមវិធីសាស្ត្របែបរិះរកញឹកញាប់ | ៣.២៨ | 0.១៤ | មធ្យម |
| ៥ | បានប្រើប្រាស់រូបភាព ទាក់ទងទៅនឹងសកម្មភាពនៃខ្លឹមសារមេរៀនជាប្រចាំ | ៣.៥៦ | 0.0៨ | ល្អ |
| | **សរុប** | **៣.៤៤** | **0.២១** | **ល្អ** |

តាមតារាងទិន្នន័យ៤.៤ បានបង្ហាញពីមធ្យមភាគសរុបនៃការប្រើប្រាស់សម្ភារឧបទេស ក្នុងការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៤៤)។ សូចនាករទី៣ "សម្ភារឧបទេស បានជួយអោយការសិក្សារីកចម្រើន" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើការប្រើប្រាស់សម្ភារឧបទេស ក្នុងការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសស្ថិតក្នុងកម្រិត "ល្អ" (មធ្យម

ភាគពិន្ទុ=៣.៨៩)។ សូចនាករទី១"មានសម្ភារៈឧទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្របែបរិះរក" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=២.៩៤)។

**តារាង៤.៥៖ ទិន្នន័យឆ្លើយតបសរុបពីគ្រូបង្រៀនលើស្ថានភាពការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក**

| អ.រ | **បរិយាយ** | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ក | ការអនុវត្តកម្មវិធីសិក្សា | ៣.៨៣ | 0.១៨ | ល្អ |
| ខ | ដំណើរការបង្រៀន | ៣.៦៧ | 0.១៩ | ល្អ |
| គ | ទំនាក់ទំនងគ្រូ-សិស្ស | ៣.៩១ | 0.២៤ | ល្អ |
| ឃ | ការប្រើប្រាស់សម្ភារឧបទេស | ៣.៤៤ | 0.១៩ | ល្អ |
| | **សរុប** | **៣.៧១** | **0.២០** | **ល្អ** |

តាមតារាងទិន្នន័យ៤.៥ បានបង្ហាញថាមធ្យមភាគសរុបនៃស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧១)។ សូចនាករ"ទំនាក់ទំនងគ្រូ-សិស្ស" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេទៅលើស្ថានភាព ក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក របស់លោកគ្រូ-អ្នកគ្រូគឺស្ថិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩១)។ បន្ទាប់មកនៅ សូចនាករ"ការប្រើប្រាស់សម្ភារឧបទេស" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៤៤)។ ចំណែកឯ សូចនាករ "ការអនុវត្តកម្មវិធីសិក្សា" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៣)។ រីឯ សូចនាករ "ដំណើរការបង្រៀន" នៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀនបែបរិះរក ទទួលបានការយល់ស្របស្ថិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៦៧)។

## ៤.២.២. ការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលា ទៅលើស្ថានភាពនៃការអនុវត្ត វិធីសាស្រ្តបង្រៀនតាមបែបរិះរក(IBL)របស់គ្រូបង្រៀនភាសាអង់គ្លេស

តារាង៤.៦៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្ដីពីការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀនភាសាអង់គ្លេស

| ល.រ | បរិយាយការអនុវត្តកម្មវិធីសិក្សា | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គ្រូបង្រៀនបានធ្វើបំណែងចែកកម្មវិធីសិក្សាបានច្បាស់លាស់ដោយមានឆ្លងការចុះទិដ្ឋាការពីគណៈគ្រប់គ្រងសាលា | ៤.២១ | 0.១៨ | ល្អណាស់ |
| ២ | គ្រូបានអនុវត្តតាម និងទាន់កម្មវិធីសិក្សា និងបំណែងចែកកម្មវិធីសិក្សាបានត្រឹមត្រូវ | ៣.៧៩ | 0.១៨ | ល្អ |
| ៣ | គ្រូបានរៀបចំ និងអនុវត្តតាមកាលវិភាគបង្រៀនបានយ៉ាងត្រឹមត្រូវ | ៤.0៧ | 0.១៦ | ល្អ |
| ៤ | គ្រូបង្រៀនបានបង្រៀនមេរៀន ស្របតាមកម្មវិធីសិក្សាកំណត់ | ៤.៣៦ | 0.១៨ | ល្អ |
| ៥ | គ្រូបានរៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆមាស | ៤.0៧ | 0.0៩ | ល្អ |
| ៦ | គ្រូបង្រៀន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន | ៤.00 | 0.១0 | ល្អ |
| ៧ | ជារួម លោកគ្រូ-អ្នកគ្រូ គឺមានភាពច្បាស់លាស់ ទៅលើការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ | ៣.៨៦ | 0.១៣ | ល្អ |
| | **សរុប** | **៤.0៥** | **0.១៥** | **ល្អ** |

តាមតារាងទិន្នន័យ៤.៦ បានបង្ហាញពីមធ្យមភាគសរុបនៃការពិនិត្យតាមដានរបស់គណៈគ្រប់គ្រង ក្នុងការអនុវត្តកម្មវិធីសិក្សា ទៅលើមុខវិជ្ជាភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.0៥)។ សូចនាករទី១"គ្រូបង្រៀនបានធ្វើបំណែងចែកកម្មវិធីសិក្សាបានច្បាស់លាស់ដោយមានឆ្លងការចុះទិដ្ឋាការពីគណៈគ្រប់គ្រងសាលា" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេទៅលើ ការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូ គឺស្ថិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២១)។ សូចនាករទី២"គ្រូបានអនុវត្តតាម និងទាន់កម្មវិធីសិក្សា និងបំណែងចែកកម្មវិធីសិក្សាបានត្រឹមត្រូវ" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧៩)។

តារាង៤.៧៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្ដីពីការពិនិត្យតាមដានទៅលើការ អនុវត្តទៅលើវិធីសាស្ត្របង្រៀនតាមបែបរិះរក របស់លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស

| ល.រ | បរិយាយការអនុវត្តទៅលើវិធីសាស្ត្របង្រៀន | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គ្រូមានចំណេះដឹង និងជំនាញវិជ្ជាជីវៈ ទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL) | ៣.៦៤ | 0.២១ | ល្អ |
| ២ | គ្រូបានប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរកជាប្រចាំ | ៣.៣៦ | 0.២២ | មធ្យម |
| ៣ | គ្រូយល់ច្បាស់ពីតួនាទីរបស់ខ្លួន ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក | ៣.៤៣ | 0.១៩ | ល្អ |
| ៤ | គ្រូមានឧទាហរណ៍ ក្នុងការពន្យល់ និងបំណកស្រាយដោយអនុវត្តទៅតាមជំហាននៃវិធីសាស្ត្របង្រៀនតាមបែបរិះរក | ៣.៧១ | 0.១៤ | ល្អ |
| ៥ | គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើវិធីសាស្ត្របង្រៀន | ៣.៨៦ | 0.១៥ | ល្អ |
| ៦ | គ្រូបង្រៀនមានសមត្ថភាពសបស្រូបតាមកម្រិតវិជ្ជាជីវៈបង្រៀន | ៤.00 | 0.១៨ | ល្អ |
| ៧ | គ្រូបង្រៀនមានស្មារតីនិងភាពជឿជាក់ខ្ពស់លើវិធីសាស្ត្របង្រៀនបែបរិះរក | ៣.៧១ | 0.0៣ | ល្អ |
| | **សរុប** | **៣.៦៧** | **0.១៦** | **ល្អ** |

តាមតារាងទិន្នន័យ៤.៧ បានបង្ហាញពីមធ្យមភាគសរុបនៃការពិនិត្យតាមដានរបស់គណៈគ្រប់គ្រងក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក ទៅលើមុខវិជ្ជាភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៦៧)។ សូចនាករទី៦"គ្រូបង្រៀន មានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើ ការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក របស់លោកគ្រូ-អ្នកគ្រូ គឺស្ថិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.00) ។ សូចនាករទី២"គ្រូបានប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរកជាប្រចាំ" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.៣៦)។

**តារាង៤.៨៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្តីពីការពិនិត្យតាមដានទៅលើការ ប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនតាមបែបរិះរក របស់លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស**

| ល.រ | បរិយាយការប្រើប្រាស់សម្ភារឧបទេស | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គ្រូបានរៀបចំសម្ភារៈឧទ្ទេសដែលឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្របែបរិះរក | ៣.៣៦ | 0.២៣ | មធ្យម |
| ២ | គ្រូបានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកបានញឹកញាប់ | ៣.២១ | 0.២៥ | មធ្យម |
| ៣ | គ្រូ និងសិស្សមានសៀវភៅសិក្សាគោលភាសាអង់គ្លេស ឆ្លើយតបទៅនឹងខ្លឹមសារមេរៀន | ៣.៨៦ | 0.២១ | ល្អ |
| ៤ | គ្រូបានប្រើប្រាស់រូបភាពទាក់ទងទៅនឹងសកម្មភាពមេរៀន | ៣.៦៤ | 0.១៤ | ល្អ |
| ៥ | គ្រូបានប្រើប្រាស់Posters ផ្សេងៗទាក់ទងទៅនឹងខ្លឹមសារមេរៀន | ៣.៣៦ | 0.0៩ | មធ្យម |
| | **សរុប** | **៣.៤៩** | **0.១៩** | **ល្អ** |

តាមតារាងទិន្នន័យ៤.៨ បានបង្ហាញពីមធ្យមភាគសរុបនៃការពិនិត្យតាមដានរបស់គណៈគ្រប់គ្រងក្នុងការប្រើប្រាស់សម្ភារឧបទេស បង្រៀនតាមបែបរិះរក ទៅលើមុខវិជ្ជាភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៤៩)។ សូចនាករទី៣ "គ្រូ និងសិស្សមានសៀវភៅសិក្សាគោលភាសាអង់គ្លេស ឆ្លើយតបទៅនឹងខ្លឹមសារមេរៀន" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេទៅលើ ការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនភាសាអង់គ្លេសតាមបែបរិះរក របស់លោកគ្រូ អ្នកគ្រូ គឺស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៨៦) ។ សូចនាករទី២"គ្រូបានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកបានញឹកញាប់" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.២១)។

**តារាង៤.៩៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងស្តីពីការពិនិត្យតាមដានទៅលើ លទ្ធផលសិក្សារបស់សិស្សក្នុងការរៀនតាមវិធីសាស្ត្របែបរិះរក**

| ល.រ | បរិយាយលទ្ធផលសិក្សារបស់សិស្ស | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | លទ្ធផលសិក្សារបស់សិស្សបង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន បន្ទាប់ពីគ្រូបានអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក | ៣.៥៧ | ០.២៤ | ល្អ |
| ២ | លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | ៣.៩៣ | ០.២៦ | ល្អ |
| ៣ | សិស្សមានជំនាញដោះស្រាយបញ្ហាដោយខ្លួនឯងនៅពេលអនុវត្តការបង្រៀន និងរៀនតាមវិធីសាស្ត្របែបរិះរក | ៣.៥៧ | ០.២២ | ល្អ |
| ៤ | សិស្សមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ប្រមូលព័ត៌មាន និងស្រាវជ្រាវ | ៣.០៧ | ០.២៤ | មធ្យម |
| ៥ | ឱ្យសិស្សមានគំនិតច្នៃប្រឌិតក្នុងការរៀនសូត្រ | ៣.៧៩ | ០.១៥ | ល្អ |
| ៦ | ធ្វើឱ្យមានការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណាសម្រាប់សិស្ស | ៣.៥៧ | ០.០៧ | ល្អ |
| ៧ | សិស្សចេះ អង្កេត រិះរក និងដោះស្រាយបញ្ហប្រកបដោយនវានុវត្តន៍ | ៣.៤៣ | ០.០៦ | ល្អ |
| ៨ | អភិវឌ្ឍន៍សមត្ថភាពសិស្សានុសិស្សក្នុងការគិតបែបស៊ីជម្រៅ (Critical Thinking) | ៣.៤៣ | ០.០៨ | ល្អ |
| | **សរុប** | **៣.៥៤** | **០.១៦** | **ល្អ** |

តាមតារាងទិន្នន័យ៤.៩ បានបង្ហាញពីមធ្យមភាគសរុបនៃការពិនិត្យតាមដានរបស់គណៈគ្រប់គ្រង ស្តីពីលទ្ធផលសិក្សារបស់សិស្សក្នុងការរៀនតាមវិធីសាស្ត្រ បែបរិះរក ទៅលើមុខវិជ្ជាភាសាអង់គ្លេស គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៥៤)។ សូចនាករទី២ "លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើ លទ្ធផលសិក្សារបស់សិស្សក្នុងការរៀន ភាសាអង់គ្លេសតាមបែបរិះរក គឺស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩៣)។ សូចនាករទី៤"សិស្សមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ប្រមូលព័ត៌មាន និងស្រាវជ្រាវ" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.០៧)។

### ៤.២.៣. ការឆ្លើយតបរបស់សិស្សក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេស តាមបែបរិះរករបស់គ្រូ នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត

តារាង៤.១០៖ ទិន្នន័យឆ្លើយតបពីសិស្សលើការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរករបស់គ្រូភាសាអង់គ្លេស

| ល.រ | បរិយាយការបង្រៀន | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការដាក់ពិន្ទុរបស់គ្រូគឺប្រកបដោយតម្លាភាព និងយុត្តិធម៌ | ៤.១២ | ០.៣១ | ល្អ |
| ២ | គ្រូមានវិធីសាស្ត្របង្រៀនល្អ ធ្វើឱ្យប្អូនងាយយល់ខ្លឹមសារមេរៀន | ៣.៩៤ | ០.៣៤ | ល្អ |
| ៣ | គ្រូមានចំណេះដឹង និងជំនាញវិជ្ជាជីវៈពិតប្រាកដ | ៤.២៧ | ០.៣៦ | ល្អណាស់ |
| ៤ | គ្រូបានផ្តល់ឱកាសឱ្យសិស្សានុសិស្សបានរៀនស្មូត្រដូចៗគ្នា | ៤.៤២ | ០.៣៨ | ល្អណាស់ |
| ៥ | គ្រូបានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនភាសាអង់គ្លេស | ៣.៣៤ | ០.៣៨ | មធ្យម |
| ៦ | គ្រូបានជម្រុញសិស្ស អោយរៀនរិះរក ពីការសិក្សាភាសាអង់គ្លេស | ៤.០៣ | ០.១៤ | ល្អ |
| ៧ | គ្រូបង្រៀនតាមកាលវិភាគ និងម៉ោងកំណត់បានយ៉ាងត្រឹមត្រូវ | ៤.២៨ | ០.១១ | ល្អណាស់ |
| ៨ | គ្រូបានប្រើសៀវភៅពុម្ពសិក្សា ភាសាអង់គ្លេស | ៤.៣៧ | ០.១៣ | ល្អណាស់ |
| ៩ | ជារួម ប្អូនពេញចិត្តចំពោះការបង្រៀនរបស់គ្រូភាសាអង់គ្លេស | ៤.៣២ | ០.១៤ | ល្អណាស់ |
| | **សរុប** | **៤.១២** | **០.២៦** | **ល្អ** |

តាមតារាងទិន្នន័យ៤.១០ បានបង្ហាញពីមធ្យមភាគសរុបនៃការបង្រៀនរបស់លោកគ្រូ អ្នកគ្រូតាមវិធីសាសាស្ត្រ បែបរិះរក ទៅលើមុខវិជ្ជាភាសាអង់គ្លេស គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.១២)។ សូចនាករទី៤ "គ្រូបានផ្តល់ឱកាសឱ្យសិស្សានុសិស្សបានរៀនស្មូត្រដូចៗគ្នា" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើ ការបង្រៀនភាសាអង់គ្លេសតាមវិធីសាស្ត្របែបរិះរក គឺស្ថិតនៅក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤២) ។ សូចនាករទី៥"គ្រូបានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនភាសាអង់គ្លេស" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.៣៤)។

**តារាង៤.១១៖ ទិន្នន័យឆ្លើយតបពីសិស្សលើសកម្មភាពសិស្សរៀនភាសាអង់គ្លេសនៅក្នុងថ្នាក់**

| ល.រ | បរិយាយសកម្មភាពសិស្សរៀននៅក្នុងថ្នាក់ | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សិស្សបានចូលរួមរិះរក និងដោះស្រាយបញ្ហា ដែលគ្រូបានដាក់ឱ្យ | ៤.០២ | ០.៣៤ | ល្អ |
| ២ | សិស្សបានចូលរួមកិច្ចពិភាក្សាជាក្រុម | ៣.៨៦ | ០.៣៤ | ល្អ |
| ៣ | សិស្សបានធ្វើបទបង្ហាញនូវរបកគំហើញថ្មី ដែលក្រុមបានរកឃើញ | ៣.០៩ | ០.៣៦ | មធ្យម |
| ៤ | សិស្សអាចធ្វើការឆ្លុះបញ្ចាំងពីការវិភាគ និងសន្និដ្ឋានរួម | ៣.៣៣ | ០.២៦ | មធ្យម |
| ៥ | សិស្ស ចូលចិត្តរៀនតាមវិធីរិះរក លើមុខវិជ្ជាភាសាអង់គ្លេស | ៣.៧៧ | ០.១៣ | ល្អ |
| ៦ | សិស្ស ទទួលបានចំណេះដឹងថ្មី ក្រោយពេលប្រើការ រិះរករួច | ៣.៩៧ | ០.១៥ | ល្អ |
| ៧ | ជារួម សិស្សចូលចិត្តរៀនភាសាអង់គ្លេស | ៣.៩៨ | ០.១៨ | ល្អ |
| | **សរុប** | **៣.៧២** | **០.២៥** | **ល្អ** |

តាមតារាងទិន្នន័យ៤.១១ បានបង្ហាញពីមធ្យមភាគសរុបនៃសកម្មភាពសិស្សរៀននៅក្នុងថ្នាក់តាមវិធីសាសាស្រ្ត បែបរិះរក ទៅលើមុខវិជ្ជាភាសាអង់គ្លេស គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧២)។ សូចនាករទី១ "សិស្សបានចូលរួមរិះរក និងដោះស្រាយបញ្ហា ដែលគ្រូបានដាក់ឱ្យ" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើ សកម្មភាពសិស្សរៀននៅក្នុងថ្នាក់តាមវិធីសាស្រ្តបែបរិះរក គឺស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០២) ។ សូចនាករទី៣"សិស្សអាចធ្វើការឆ្លុះបញ្ចាំងពីការវិភាគ និងសន្និដ្ឋានរួម" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.០៩)។

## ៤.៣. ការពិភាក្សាពីស្ថានភាពការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅមធ្យមសិក្សាទុតិយភូមិ

នៅក្នុងប្រព័ន្ធអប់រំ ទន្ទឹមនឹងមានអគារសិក្សាល្អហើយនោះ នៅមិនទាន់គ្រប់គ្រាន់ដើម្បីធ្វើដំណើរឆ្ពោះទៅរកការអប់រំដ៏ប្រសើរនោះទេ ចាំបាច់ណាស់ត្រូវតែមានដំណើរការបង្រៀន និងរៀនមួយប្រកបដោយប្រសិទ្ធភាព។ ការពិភាក្សាលើស្ថានភាពការអនុវត្តវិធីសាស្រ្តបង្រៀន បានជំរុញឱ្យគរុកោសល្យរបស់

គ្រូបង្រៀន ឆ្ពោះទៅមុខ ដោយឆ្លុះបញ្ចាំងពីដំណើរការនៃភាពខុសគ្នារវាងការផ្ទេរចំណេះដឹង និងបញ្ជ្រាបចំណេះដឹងពីគ្រូទៅសិស្ស។ ធាតុសំខាន់ៗនៃការបង្រៀនគឺគ្រូបង្រៀន សិស្ស ថ្នាក់រៀន កម្មវិធីសិក្សា សម្ភារៈឧបទ្ទេស និងរដ្ឋបាលសិក្សាជាដើម។ ប្រសិនបើមានកម្មវីធីសិក្សា(curriculum)ល្អហើយ ប៉ុន្តែគ្រូបង្រៀនខ្វះខាតឬគ្មានវិធីសាស្ត្រក្នុងការផ្ទេរចំណេះដឹងទៅសិស្ស នោះដំណើរកាបង្រៀន ឬប្រព័ន្ធអប់រំនោះមិនអាចឆ្ពោះទៅរកការអប់រំដ៏មានប្រសិទ្ធភាពបានឡើយ។ វីធីសាស្រ្តបង្រៀនមានដូចជា វិធីវិទ្យាសាស្រ្ត ការបង្រៀន និងរៀនតាមបែបរិះរក(IBL) ដែលជាការបង្រៀនផ្តល់ឱ្យសិស្សរកចំណេះដឹងតាមរយៈសំណួរគន្លឹះ។ វីធីសាស្រ្តបង្រៀននេះ បានលើកទឹកចិត្តសិស្សឱ្យធ្វើការជាមួយគ្នា និងធ្វើឱ្យសិស្សចេះសង្កេត វិភាគ ដោះស្រាយបញ្ហា។

**តារាង៤.១២៖ ទិន្នន័យឆ្លើយតបសរុបពីគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្ស**

| ល.រ | **បរិយាយ** | ពិន្ទុមធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ទិន្នន័យឆ្លើយតបសរុបពីគណៈគ្រប់គ្រងសាលារៀន | **៣.៦៩** | 0.១០ | **ល្អ** |
| ២ | ទិន្នន័យឆ្លើយតបសរុបពីគ្រូបង្រៀនភាសាអង់គ្លេស | **៣.៧១** | 0.១១ | **ល្អ** |
| ៣ | ទិន្នន័យឆ្លើយតបសរុបពីសិស្ស | **៣.៩២** | 0.១១ | **ល្អ** |
| **សរុប** | | **៣.៧៧** | 0.១១ | **ល្អ** |

ឆ្លើយតបទៅនឹងទស្សនៈនៃការយល់ឃើញលើស្ថានភាពនៃការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះករបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកពត។ ការឆ្លើយតបរបស់គ្រូបង្រៀន គឺសំខាន់ណាស់ក្នុងការឆ្លុះបញ្ចាំងពីស្ថានភាពនៃប្រព័ន្ធប្រតិបត្តិការសាលារៀន និងស្ថានភាពការអនុវត្តវិធីសាស្រ្តបង្រៀនរបស់គ្រូ ពីព្រោះវិជ្ជាជីវៈជាគ្រូបង្រៀន គឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងសាលារៀន និងជាអ្នកអនុវត្តវិន័យក្នុងសាលារៀន ព្រមទាំងជាអ្នកនាំមុខក្នុងការផ្តល់សេវាបង្រៀនដល់ការសិក្សារបស់សិស្ស ការផ្ទេរចំណេះដឹង និងបទពិសោធន៍ជាមួយសិស្ស និងមិត្តភក្តិរួមការងារក្នុងអង្គភាពតែមួយ ។ ក្នុងន័យនេះ ប្រសិនបើការអនុវត្តវិធីសាស្រ្តបង្រៀនបានល្អ នោះនាំឱ្យស្ថានភាពនៃការ

បង្រៀន និងរៀនក៏ទទួលបានលទ្ធផលល្អប្រសើរដែរ ផ្ទុយមកវិញបើល្កិកណាការអនុវត្តវិធីសាស្ត្របង្រៀន មិនបានល្អ នោះនាំឱ្យស្ថានភាពបង្រៀន និងរៀនក៏មិនទទួលបានគុណភាព និងប្រសិទ្ធភាពដែរ។

ទិន្នន័យដែលបង្ហាញពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក មានចំនួនភាគសំណាកចូលរួមឆ្លើយតបពីគ្រូបង្រៀន គណៈគ្រប់គ្រងសាលា និងសិស្សានុសិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត ពេលចុះប្រមូលទិន្នន័យដើម្បីសិក្សាស្រាវជ្រាវ។

យោងតាមតារាង៤.១២ បានបង្ហាញទិន្នន័យឆ្លើយតបសរុបពីគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្ស ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧៧) លើស្ថានភាពការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL) នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត។ ក្នុងន័យនេះ បានបង្ហាញថាគ្រូបង្រៀនភាសាអង់គ្លេស បានអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក ក្នុងភាពត្រឹមត្រូវតាមនិយាមរបស់វិជ្ជាជីវៈក្នុងការផ្ទេរចំណេះដឹងភាសាអង់គ្លេសទៅដល់សិស្សានុសិស្សក្នុងដំណើរការរៀនក្នុងថ្នាក់ និងមានភាពច្បាស់លាស់សំដៅពង្រឹងដល់គុណភាពនៃការសិក្សា។ តាមលទ្ធផលសិក្សារបស់ **ស៊ុនជេត (២០១៧)** បានលើកឡើងថា វិធីសាស្ត្របង្រៀនរបស់លោកគ្រូ អ្នកគ្រូពិតមានភាពចាំបាច់ និងមានឥទ្ធិពលណាស់សម្រាប់ដំណើរការរៀន និងបង្រៀនដើម្បីឱ្យទទួលបានលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរ។ ភាពប្រសើរឡើងនៃការសិក្សារបស់សិស្ស គឺទាមទារជាចាំបាច់។

វិបត្តិពិភពលោកដែលបង្កឡើងដោយការឆ្លងរាលដាលនៃជំងឺ កូវីដ-១៩ បានធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច កម្ពុជាយ៉ាងខ្លាំងក្នុងឆ្នាំ២០២០នេះ ជំរុញឲ្យមានការធ្លាក់ចុះយ៉ាងគំហុកនៃកំណើនសេដ្ឋកិច្ចនៃត្រីមាសទី១ ឆ្នាំ២០២០នេះ រួមទាំងវិស័យអប់រំ វិស័យទេសចរណ៍ និងវិស័យផ្សេងៗទៀតផងដែរ។ ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត បានបង្ហាញពីសូចនាករចំណុចដៅថ្នាក់ខេត្ត លទ្ធផលគ្រោងទុក កញ្ចប់ថវិកា និងប្រភពថវិកាតាមសកម្មភាពនីមួយៗ អង្គភាពទទួលខុសត្រូវអនុវត្ត និងក្របខណ្ឌពេលវេលាដែលត្រូវអនុវត្តផងដែរ ដើម្បីរួមចំណែកអនុវត្តកំណែទម្រង់វិមជ្ឈការ វិ

សហមជ្ឈការ និងកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា។

ឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ខេត្តកំពត ក៏ដូចជាផែនការប្រតិបត្តិសាលារៀន សំដៅជំរុញលទ្ធផលសិក្សារបស់សិស្សទទួលបានកាន់តែល្អប្រសើរថែមមួយកម្រិតទៀតគឺ ទាមទារឱ្យគ្រូបង្រៀនចេះប្រើប្រាស់វិធីសាស្ត្រនៅក្នុងការផ្ទេរចំណេះដឹងដល់សិស្សប្រកបដោយប្រសិទ្ធភាព ព្រោះថាវិធីសាស្ត្របង្រៀន ដែលល្អសម្រាប់គ្រូបង្រៀនគឺជាវិធីសាស្ត្រដែលទាមទារឱ្យគ្រូមានភាពបត់បែន និងឆ្លុះបញ្ចាំងពីខ្លឹមសារ ភាពបត់បែនទៅតាមបរិបទថ្នាក់រៀនជាក់ស្តែង ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ឈានទៅដល់សម្រេចបាននូវវិជ្ជាទាំងបីគឺ ចំណេះដឹង ចំណេះធ្វើ និងឥរិយាបថ ក្នុងក្របខណ្ឌកម្មវិធីសិក្សាអប់រំពេលរដ្ឋពេញលេញ។ លើសពីនេះទៅទៀតនោះ វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក(IBL) មានសារៈសំខាន់ណាស់ នៅក្នុងការសិក្សារបស់សិស្សនាពេលបច្ចុប្បន្ន ព្រោះជាវិធីសាស្ត្រមួយ ដែលជួយឱ្យសិស្សមានការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណា សិស្សមានភាពសកម្មនៅក្នុងការសិក្សា ដើម្បីទទួលបានចំណេះដឹង។ វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ក៏ជួយសម្រួលដល់ជំនាញដោះស្រាយបញ្ហាដល់សិស្ស ជាពិសេសធ្វើឱ្យសិស្សចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការសិក្សាតាមរយៈការស្រាវជ្រាវរុករកនៅលើបណ្តាញអ៊ីនធើណែត និងព័ត៌មានបន្ថែមផ្សេងៗជាដើម។ បើតាមលោក Harlen (២០១៣) បានបញ្ជាក់ថា ការអប់រំសិស្សតាមវិធីសាស្ត្របែបរិះរក គឺសំដៅទៅលើការស្វែងរក ការពន្យល់ និងគិតរិះរកព័ត៌មានតាមរយៈការសួរជាសំណួរ។ ក្នុងន័យនេះ អាចបញ្ជាក់បានថា វិធីសាស្ត្របង្រៀនតាមបែបរិះរកអាចធ្វើឱ្យសិស្ស ចេះសង្កេត ចេះស្វែងរក និងដោះស្រាយបញ្ហាបានសមស្របដោយខ្លួនឯង។ វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក បានបណ្តុះការគិត និងការវិភាគដល់សិស្ស និងការបង្កើតថ្មីប្រកបដោយនវានុវត្តន៍ ជាពិសេសជួយអភិវឌ្ឍន៍សមត្ថភាពសិស្សានុសិស្សក្នុងការគិតបែបស៊ីជម្រៅទៅលើបញ្ហានីមួយៗបានច្បាស់លាស់។

តាមរយៈទិន្នន័យដែលទទួលបាន សមាសភាពដែលឋិតក្នុងកម្រិតខ្ពស់ ឆ្លើយតបជាវិជ្ជមានលើដំណើរការនៃការអនុវត្តវិធីសាស្ត្របង្រៀននិងរៀនភាសាអង់គ្លេសតាមបែបរីករក របស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត បង្ហាញថា "ទំនាក់ទនងរវាងគ្រូ-សិស្ស" គឺទទួលបានកម្រិត "ល្អ" (មធ្យមភាគពិន្ទុសរុប=៣.៩៤)។ ទំនាក់ទំនងរវាងគ្រូ-សិស្ស នៅក្នុងដំណើរការបង្រៀន និងរៀន គឺមានភាពចាំបាច់ណាស់ ក្នុងការប្រព្រឹត្តទៅនៃដំណើរការថ្នាក់រៀន ដើម្បីទទួលបានភាពល្អប្រសើរនៃលទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដោយតម្រូវឱ្យគ្រូបង្រៀន ត្រូវមានតិចនិច ឬវិធីសាស្ត្របង្រៀនឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សនៅក្នុងការបង្រៀន និងរៀនក្នុងថ្នាក់។ យោងលើទិន្នន័យដែលទទួលបានពីការសិក្សាស្រាវជ្រាវបានបង្ហាញថា កត្តាដែលនាំឱ្យមធ្យមភាគពិន្ទុលើ "ទំនាក់ទំនងរវាងគ្រូ-សិស្ស" ទទួលបានពិន្ទុខ្ពស់គឺដោយសារតែ គ្រូបង្រៀនផ្តល់តម្លាភាពក្នុងការបង្រៀន និងបានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស ធ្វើឱ្យសិស្សងាយក្នុងការសិក្សាភាសាអង់គ្លេស និងសិស្សទទួលបានលទ្ធផលសិក្សាក្នុងកម្រិតល្អ។ លើសពីនេះទៅទៀតនោះ ភាពស្និទ្ធស្នាល និងសហការគ្នាល្អរវាងគ្រូ និងសិស្សធ្វើឱ្យសិស្សរីករាយ មានទំនុកចិត្តក្នុងការសិក្សា ហ៊ានបញ្ចេញមតិយោបល់ផ្សេងៗ រីឯគ្រូបង្រៀនអាចស្វែងយល់កត្តាចិត្តសាស្ត្រ និងតម្រូវការសិក្សារបស់សិស្ស ចែករំលែកចំណេះដឹងពីគ្នាទៅវិញទៅមកជាដើម។ ព្រមជាមួយគ្នា តាមការសិក្សាស្រាវជ្រាវរបស់លោក Dol (២០១៦) បានបង្ហាញថា "ទំនាក់ទំនងរវាងគ្រូ-សិស្ស" មានសារៈសំខាន់ណាស់នៅក្នុងដំណើរការបង្រៀន និងរៀន ព្រោះវាជាវិធីសាស្ត្រ និងសកម្មភាពដ៏ចាំបាច់មួយដែលមិនអាចខ្វះបាន ក្នុងការជម្រុញនូវអន្តរកម្មនៃការសិក្សារបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានបង្ហាញពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងការលើកកម្ពស់គុណភាពអប់រំ ដែលជាអាទិភាពមួយក្នុងចំណោមអាទិភាពទាំង៧ ដែលក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញឱ្យអនុវត្តដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។ គោលនយោបាយគ្រូបង្រៀន និងផែនការសកម្មភាព

គោលនយោបាយគ្រូបង្រៀន បានកំណត់នូវចក្ខុវិស័យថ្មីសម្រាប់គុណភាពគ្រូបង្រៀននៅកម្ពុជា រួមមានការទាក់ទាញនិងរក្សាគ្រូដែលមានសមត្ថភាពនិងឆន្ទៈ ក្នុងការចាប់យកនិងបន្តអាជីពបង្រៀន ការលើកកម្ពស់គុណភាពនៃការបង្រៀនតាមរយៈការកែលម្អប្រព័ន្ធអប់រំ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការធ្វើឱ្យប្រសើរឡើងនូវឋានៈសង្គមរបស់គ្រូបង្រៀនទូទាំងប្រទេស។ គន្លងអាជីពគ្រូបង្រៀនកម្ពុជា បានកំណត់ថាគ្រូឆ្នើម គឺមានគំនិតច្នៃប្រឌិត ការសិក្សាស្រាវជ្រាវ និងបង្កើតថ្មីលើការបង្រៀន និងការរៀន ការវាយតម្លៃគុណផលសិក្សារបស់សិស្ស និងគុណផលសាលារៀន។ គ្រូឆ្នើម ផ្តួចផ្តើមគំនិតថ្មីៗ និងដឹកនាំសកម្មភាពនៅក្នុងសាលារៀន និងក្រៅសាលារៀន ដើម្បីធ្វើឱ្យសិស្សទាំងអស់ទទួលឱកាសរៀនសូត្រដូចៗគ្នា និងទទួលបានលទ្ធផលសិក្សាល្អ។ តាមទិន្នន័យក្នុងការសិក្សាស្រាវជ្រាវស្តីពីស្ថានភាពនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL) របស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិបានបង្ហាញពីចំនុចខ្វះខាតដើម្បីធ្វើការកែលម្អលើ "ដំណើរការបង្រៀន" និង "ការប្រើប្រាស់សម្ភារឧបទេស" ឆ្លើយតបទៅនឹងការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន លើកិច្ចការជានាគុណភាពអប់រំផងដែរ។

ដំណើរការបង្រៀនតាមវិធីសាស្ត្របែបរិះរក(IBL) របស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស នៅមានកម្រិតលើកត្តាចំណេះដឹង ក្នុងការអនុវត្តវិធីសាស្ត្រតាមបែបរិះរក និងភាពបត់បែនសម្របតាមបរិបទសិស្សក្នុងថ្នាក់ ដោយសារតែគ្រូបង្រៀនភាសាអង់គ្លេសមួយចំនួនក្នុងភាគសំណាក បានទទួលការបណ្តុះបណ្តាលតាមរយៈវគ្គបំប៉នវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក បានតែមួយដង បទពិសោធន៍ក្នុងការសាកល្បងក៏ពុំទាន់មានផងដែរ។ លើសពីនេះទៅទៀត ដើម្បីឱ្យការបង្រៀន និងរៀនមានដំណើរការល្អ ទទួលបានផ្លែផ្កា និងសម្រេចបានតាមវត្ថុបំណងដែលបានកំណត់ គឺទាមទារឱ្យគ្រូបង្រៀនត្រូវរៀបចំផែនការបង្រៀន(កិច្ចតែងការបង្រៀន)ព្រមទាំងប្រកាន់ភ្ជាប់នូវតួនាទី និងភារកិច្ចរបស់ខ្លួន ឱ្យបានច្បាស់លាស់។ លទ្ធផលសិក្សារបស់សិស្ស អាស្រ័យលើគ្រូបង្រៀនចេះរៀបចំកិច្ចដំណើរការបង្រៀនរបស់ខ្លួន នោះគឺការរៀបចំកិច្ចតែងការបង្រៀន សកម្មភាព ឱ្យមានរបៀបរៀបរយ ដោយមានដាក់បញ្ចូលនូវការរៀបចំលំហាត់ ឬកិច្ចការផ្ទះដល់សិស្ស ដោយគិតយ៉ាងហ្មត់ចត់ ពីកម្រិតសំណួរ (កម្រិតពុទ្ធិ) នៃចំណេះ

ដឹងរបស់សិស្ស ដោយមិនងាយពេក ឬពិបាកពេក **(សូនជាន, ២០១២)**។ ព្រមជាមួយគ្នា កិច្ចតែងការ ឬប្លង់មេរៀនដូចជាត្រីវិស័យសម្រាប់បង្ហាញផ្លូវយ៉ាងច្បាស់លាស់ នូវដំណើរការបង្រៀន ដើម្បីឱ្យសិស្សងាយយល់ និងឆាប់ចាប់បាននូវខ្លឹមសារមេរៀន ដែលឈានទៅទទួលបានចំនេះដឹង និងបំណិនប្រសប់ ដែលនៅក្នុងផ្នែកនេះគឺឱ្យស្របគ្នាតាមលក្ខណៈនៃការប្រើប្រាស់វិធីសាស្រ្តបង្រៀនដែរ **(សូនជាន, ២០១២)**។

ការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនតាមវិធីសាស្រ្តបែបរិះរក(IBL) របស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ចាំបាច់ត្រូវមានគ្រប់គ្រាន់ សំដៅឆ្លើយតបទៅនឹងមេរៀនក្នុងដំណើរការបង្រៀន ដែលជំរុញដល់កិច្ចការបង្រៀនរបស់គ្រូ មានភាពងាយស្រួល និងធ្វើឱ្យសិស្សមានចំណាប់អារម្មណ៍លើខ្លឹមសារមេរៀន ព្រមទាំងធ្វើឱ្យការបង្រៀន និងរៀនទទួលបានជោគជ័យ សម្រេចបាននូវវត្ថុបំណងមេរៀន។ មានសម្ភារឧបទេសបង្រៀនភាសាអង់គ្លេសមួយចំនួន មិនទាន់បានរៀបចំ និងផលិត ស្របតាមវិធីសាស្រ្តបែបរិះរកនៅឡើយ ដោយសារតែធនធានថវិកាពុំទាន់បានផ្តល់ឱ្យបានគ្រប់គ្រាន់ និងគ្រូបង្រៀនមិនទាន់ពេលវេលាគ្រប់គ្រាន់ ក្នុងការប្រជុំគ្នាដើម្បីច្នៃនូវសម្ភារៈ បម្រើដល់ការបង្រៀនវិធីសាស្រ្តតាមបែបរិះរកនេះ។ តាមទស្សនៈរបស់លោក Skinner (2009) បានបង្ហាញថា ពិតជាចាំបាច់ណាស់ដែលត្រូវឱ្យមានសម្ភារឧទេសឱ្យបានគ្រប់គ្រាន់ និងកិច្ចតែងការបង្រៀន គួបផ្សំនឹងវិធីសាស្រ្តបង្រៀនល្អ ដើម្បីបម្រើឱ្យដំណើរសកម្មភាពការបង្រៀន និងរៀនជានាបាននូវប្រសិទ្ធភាព និងជាពិសេសធ្វើឱ្យសិស្សកាន់តែមានចំណូលចិត្តក្នុងការសិក្សាទៀតផង។ នេះមានន័យថា ដំណើរការបង្រៀនប្រព្រឹត្តទៅបានល្អ វាអាស្រ័យលើគ្រូបង្រៀនមានវិធីសាស្រ្តបង្រៀនល្អ ចេះបត់បែនទៅតាមស្ថានភាពជាក់ស្តែង ក្នុងថ្នាក់រៀន។ ក្នុងបរិបទជាក់ស្តែង សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសក៏នៅមានភាពខ្វះខាត ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការសិស្ស ក៏ដូចជាក្របខណ្ឌកម្មវិធីសិក្សាពលរដ្ឋពេលលេញផងដែរ។ ដើម្បីបំពេញទៅនឹងការខ្វះខាតសៀវភៅសិក្សាគោលនេះ គឺទាមទារឱ្យមានការចូលរួម ពីគ្រប់ភាគីពាក់ព័ន្ធទាំងក្រសួង មន្ទីរ សាលារៀន និងដៃគូរអភិវឌ្ឍន៍ ក៏ដូចជាគ្រូបង្រៀនផងដែរ។

ជាការពិតណាស់សម្ភារឧបទេសដែលល្អ គឺជាសម្ភារឧបទេសដែលបម្រើឱ្យខ្លឹមសារមេរៀន មានសុវត្ថិភាព សម្រាប់ទាំងគ្រូ និងសិស្ស មានទំហំសមស្របដែលអាចឱ្យសិស្សទូទាំងថ្នាក់រៀនមើលឃើញ និងសង្កេតបានច្បាស់លាស់។ មិនតែប៉ុណ្ណោះ សម្ភារឧបទេសធ្វើឱ្យការបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល និងតាមវិធីសាស្ត្របែបរិះរក កាន់តែមានប្រសិទ្ធភាពដោយសិស្ស ឬក្រុមសិស្សអាចសង្កេត ពិនិត្យ វិភាគ ធ្វើពិសោធន៍ លេងល្បែង ស្វ័យសិក្សា បង្កើនសមត្ថភាពក្នុងការសិក្សា និងជាពិសេសធ្វើឱ្យសិស្សមានចំណូលចិត្តក្នុងការរៀនសូត្រ មានការចងចាំ ព្រមទាំងមានភាពជឿជាក់លើសមត្ថភាពផ្ទាល់ខ្លួន (MoEYS, 2014)។ ក្រៅពីនេះ ការប្រើប្រាស់សម្ភារឧបទេសក្នុងថ្នាក់រៀន គឺជាកត្តាធ្វើឱ្យថ្នាក់រៀនមានភាពទាក់ទាញអារម្មណ៍ និងលើកទឹកចិត្តសិស្ស ហើយក៏ជាធនធានសម្រាប់បម្រើការសិក្សានៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព **(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៤)**។ ការប្រើប្រាស់សម្ភារឧបទេស នៅក្នុងការបង្រៀន ធ្វើឱ្យគ្រូបង្រៀន អាចពិនិត្យមើលពីរបៀបប្រើសម្ភារឧបទេស ការដោះស្រាយបញ្ហា និងការវាយតម្លៃការរៀនរបស់សិស្ស ព្រមទាំងវិធីសាស្ត្រក្នុងការប្រើប្រាស់សម្ភារឧបទេសដើម្បីឱ្យការបង្រៀន និងរៀនទទួលបានលទ្ធផលល្អប្រសើរ។ ការអប់រំ និងការបង្រៀនប្រកបដោយគុណភាព គឺស្ថិតនៅក្រោយលទ្ធផលការសិក្សារបស់សិស្ស ហើយដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ ត្រូវមានកត្តារួមចំណែកមួយចំនួនដូចជា៖ ការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនដល់គ្រូបង្រៀន អគារសិក្សា សម្ភារឧបទេស និងកម្មវិធីសិក្សា។ តាមរយៈការអះអាងទាំងនេះ បានបញ្ជាក់ថាសម្ភារឧបទេសក៏ជាសមាសភាគមួយដ៏សំខាន់ដែលបានរួមចំណែកកែលម្អគុណភាព ក្នុងការដំណើរបង្រៀន និងរៀនដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សទទួលបានភាពល្អប្រសើរ។

### ៤.៤. ពិភាក្សាពីបញ្ហាប្រឈមរបស់គ្រូបង្រៀន ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកនៅលើមុខវិជ្ជាភាសាអង់គ្លេស

ការអប់រំនៅប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងការខិតខំ កែលម្អការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ទាំងនៅតាមទីជនបទ ការអភិវឌ្ឍក្មេងតូច និងការចុះឈ្មោះចូលរៀន ជាដើម។ វិស័យអប់រំ នៅតែជាបញ្ហាប្រឈមសំខាន់ និងអាទិភាពនៃការអភិវឌ្ឍសម្រាប់ប្រទេស

កម្ពុជា។ បញ្ហាប្រឈមរបស់គ្រូបង្រៀន ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេស ក៏ជាកាតាលីករមួយជំរុញឱ្យវិស័យអប់រំ និងកិច្ចការងារជានាគុណភាព ជួបនៅបញ្ហារាំងស្ទះផងដែរ។ ដំណោះស្រាយលើបញ្ហាប្រឈមរបស់គ្រូបង្រៀន ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក បានចូលរួម ដល់សកម្មភាពអនុវត្តផែនការប្រតិបត្តិរបស់សាលារៀន ឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ផងដែរ។

**តារាង៤.១៣៖ ទិន្នន័យឆ្លើយតបលើ បញ្ហាប្រឈមក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក**

| ល.រ | បរិយាយ | មធ្យមភាគ | គំលាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស មានភាពច្បាស់លាស់ | ៣.៩៤ | ០.៣៨ | ខ្លាំង |
| ២ | សៀវភៅពុម្ពសិក្សាសម្រាប់គ្រូ និងសិស្សបានគ្រប់គ្រាន់ | ២.៦១ | ០.៣៨ | មធ្យម |
| ៣ | សម្ភារឧបទេស ឆ្លើយតបទៅនឹងខ្លឹមសារមេរៀន | ៣.៣៩ | ០.២៩ | មធ្យម |
| ៤ | ពេលម៉ោងកាលវិភាគសមស្រប កម្មវិធីសិក្សា | ៣.១១ | ០.៣២ | មធ្យម |
| ៥ | បានពង្រឹងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក | ៣.៣៣ | ០.៣៤ | មធ្យម |
| ៦ | មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់គ្រូ ផលិតសម្ភារៈឧបទេស | ៣.០០ | ០.៤២ | មធ្យម |
| ៧ | គ្រូបង្រៀនទទួល បានការលើកទឹកចិត្តពីគណៈគ្រប់គ្រងសាលា | ៣.៨៣ | ០.៣៦ | ខ្លាំង |
| | **សរុប** | **៣.៣២** | **០.៣៥** | **មធ្យម** |

តាមតារាងទិន្នន័យ៤.១៣ បានបង្ហាញពីមធ្យមភាគសរុបនៃបញ្ហាប្រឈម ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូ គឺយល់ស្របក្នុងកម្រិត "មធ្យម"(មធ្យមភាគពិន្ទុ=៣.៣២)។ សូចនាករទី១ "បំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស មានភាពច្បាស់លាស់" គឺទទួលបានកម្រិតយល់ស្របខ្ពស់ជាងគេ ទៅលើ ការអនុវត្តវិធីសាស្ត្របង្រៀនភាសា

អង់គ្លេសតាមបែបរិះរក របស់លោកគ្រូ-អ្នកគ្រូ គឺស្ថិតក្នុងកម្រិត "ខ្លាំង" (មធ្យមភាគពិន្ទុ=៣.៩៤)។ សូចនាករទី២ "សៀវភៅពុម្ពសិក្សាសម្រាប់គ្រូ និងសិស្សបានគ្រប់គ្រាន់" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=២.៦១)។

ឆ្លើយតបទៅនឹងទស្សនៈនៃការយល់ឃើញលើបញ្ហាប្រឈម ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះករបស់លោកគ្រូ អ្នកគ្រូនៅមធ្យមសិក្សាទុតិយភូមិខេត្តកំពត។ ការអនុវត្តវិធីសាស្ត្របង្រៀនគឺមានភាពចាំបាច់ណាស់ ក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន ពីព្រោះគ្រូបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសាលារៀន គ្រូជាអ្នកអនុវត្តគោលការណ៍ និងវិន័យនៅក្នុងសាលារៀន លើសពីនេះទៅទៀតឥរិយាបថគ្រូបានឆ្លុះបញ្ចាំង ដល់ប្រព័ន្ធប្រតិបត្តិសាលារៀន។ នៅក្នុងន័យនេះដែរ ការចែករំលែកពីបញ្ហាប្រឈមរបស់លោកគ្រូ អ្នកគ្រូ គឺពិតជាបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការដោះស្រាយបញ្ហាដល់ការអនុវត្តវិធីសាស្ត្របង្រៀន និងដំណើរការប្រតិបត្តិសាលារៀន ក៏ដូចជាការពង្រឹងលទ្ធផលសិក្សារបស់សិស្ស ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំផងដែរ។

ទិន្នន័យដែលបានបង្ហាញពីបញ្ហាប្រឈមលើការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេសគឺទទួលបានពីលោកគ្រូ អ្នកគ្រូ បង្រៀនភាសាអង់គ្លេស និងគណៈគ្រប់គ្រងសាលាតាមសំណាកវិទ្យាល័យក្នុងខេត្តកំពតដែលបានចុះប្រមូលនៅក្នុងការសិក្សាស្រាវជ្រាវ។

ផ្អែកលើទិន្នន័យតារាង៤.១៣ ខាងលើបានបង្ហាញថាមធ្យមភាគសរុបនៃបញ្ហាប្រឈម ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាបែបរិះរកទៅលើមុខវិជ្ជាភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូគឺទទួលបានមធ្យមភាគពិន្ទុ=៣.៣២ ស្ថិតនៅកម្រិតមធ្យម។ នេះមានន័យថាលោកគ្រូ អ្នកគ្រូនៅមធ្យមសិក្សាទុតិយភូមិបាននឹងកំពុងជួបប្រទះបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកស្ថិតនៅកម្រិតមធ្យម មិនមានបញ្ហាធ្ងន់ធ្ងរណាស់ណាទេ។ តាមរយៈការសិក្សាស្រាវជ្រាវពីសំណាក់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា នៅក្នុងពេលចុះប្រមូលទិន្នន័យ ក្នុងដំណាក់កាលនៃគំលាតសង្គម ការស្នើសុំសួរផ្ទាល់ជាមួយគ្រូ ដើម្បីសុំសួរពីការសង្កេតថ្នាក់រៀន ត្រូវបានរៀបចំតាមរយៈការ

បំពេញព័ត៌មានបន្ថែមពីគ្រូបង្រៀន។ តាមរយៈទិន្នន័យដែលបានបំពេញដោយគ្រូ លើការសាកល្បងសង្កេតថ្នាក់រៀន ត្រង់ផ្នែកមតិយោបល់ បានរកឃើញថា កត្តាដែលធ្វើឱ្យគ្រូបង្រៀនជួបប្រទះនូវបញ្ហាប្រឈមដូចនេះគឺដោយសារតែការយល់ដឹងរបស់លោកគ្រូ អ្នកគ្រូ ទៅលើវិធីសាស្ត្របង្រៀនបែបរិះរក នៅមានកម្រិត មិនតែប៉ុណ្ណោះលោកគ្រូ អ្នកគ្រូមួយចំនួនធំមិនទាន់បានឆ្លងវគ្គបណ្តុះបណ្តាល ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក នេះនៅឡើយ។ ទន្ទឹមនឹងនោះសមត្ថភាពភាសាអង់គ្លេសរបស់សិស្សនៅមានកម្រិតទាក់ទងទៅនឹងការរិះរក ធ្វើឱ្យគ្រូពិបាកនៅក្នុងការបង្រៀន។ សិស្សមិនទាន់មានទម្លាប់ការគិត ការរិះរក ការដោះស្រាយបញ្ហា ព្រមទាំងមានបទពិសោធន៍ ក្នុងការស្រាវជ្រាវ និងចងក្រងឯកសារ ធ្វើរបាយការណ៍ជាភាសាអង់គ្លេសទេ។ មិនមានសម្ភារឧបទេសគ្រប់គ្រាន់ ហើយឆ្លើយតបទៅនឹងខ្លឹមសារមេរៀន។ សិស្សខ្វះឯកសារស្រាវជ្រាវ(សៀវភៅសិក្សាគោល) និងមិនមានមូលដ្ឋានគ្រឹះក្នុងការសិក្សាភាសាអង់គ្លេស ព្រមទាំងមិនមានភាពទូលំទូលាយក្នុងការប្រើប្រាស់ខាងបច្ចេកវិទ្យាទាំងគ្រូ និងសិស្ស។ មិនតែប៉ុណ្ណោះ ម៉ោងបង្រៀន និងគ្រូបង្រៀនភាសាអង់គ្លេសមិនមានគ្រប់គ្រាន់ ដែលឆ្លើយតបទៅនឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀន។

ដូចគ្នានេះដែរ យើងត្រូវរួមចំណែកដើម្បីកាត់បន្ថយនូវបញ្ហាប្រឈមដែលកើតមានចំពោះលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសដែលកំពុងជួបប្រទះនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀនបែបរិះរក(IBL) ក្នុងគោលបំណង ដើម្បីជម្រុញឱ្យការអនុវត្តកម្មវិធីសិក្សា, ដំណើរការបង្រៀនបែបរិះរក, ការទំនាក់ទំនងរវាងគ្រូ-សិស្សនៅក្នុងសកម្មភាពរៀន និងរៀនបែបរិះរក និងជាពិសេសការប្រើប្រាស់សម្ភារឧបទេសសម្រាប់គាំទ្រដល់ខ្លឹមសារមេរៀន ធ្វើឱ្យការបង្រៀន និងរៀនអាចសម្រេចបាននូវវត្ថុបំណងមេរៀន ឱ្យកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការអនុវត្តវិធីសាស្ត្របង្រៀនបែបរិះរក កាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលសិក្សាល្អប្រសើរឡើង ចាំបាច់ណាស់យើងត្រូវធ្វើការបំប៉នសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនឱ្យបានទូលំទូលាយ និងស៊ីជម្រៅ ព្រោះវិធីសាស្ត្របង្រៀនល្អពិតណាស់ អាចផ្ទេរនូវចំណេះដឹងដល់សិស្សបាន ពិសេសធ្វើឱ្យសិស្សទទួលបាននូវវិជ្ជាទាំងបី គឺវិជ្ជាស

ម្បទា បំណិនសម្បទា និងចរិយាសម្បទា។ យ៉ាងណាមិញនៅក្នុងឯកសារសៀវភៅដែលបានបោះពុម្ពរបស់ **វិទ្យាស្ថានជាតិអប់រំ (២០១៩)** បាននិយាយថាគ្រូបង្រៀនដែលល្អម្នាក់ មិនមែនគ្រាន់តែមានចំណេះដឹង ជំនាញឯកទេសរបស់ខ្លួនពូកែនោះទេ ប៉ុន្តែផងដែរក៏ត្រូវមានវិធីសាស្ត្របង្រៀនល្អ នៅក្នុងការបញ្ជ្រាប ចំណេះដឹងរបស់ខ្លួនទៅឱ្យសិស្សប្រកបដោយភាពវៃឆ្លាត។ អាស្រ័យហេតុនេះការបំប៉នសមត្ថភាព វិជ្ជាជីវៈគ្រូបង្រៀនពិតជាមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យការអនុវត្តវិធីសាស្ត្របង្រៀន នៅក្នុងដំណើរការបង្រៀន និងរៀនភាសាអង់គ្លេសកាន់តែមានគុណភាព ពិសេសធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ។

ម្យ៉ាងវិញទៀតការបំប៉នសមត្ថភាពវិជ្ជាជីវៈលើវិធីសាស្ត្រសម្រាប់គ្រូបង្រៀន គឺដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលនៃតម្រូវការសិក្សារបស់សិស្ស។ តាមការសង្កេត យើងឃើញថា បច្ចេកវិទ្យាមានការរីកចម្រើនជឿនលឿនពីមួយឆ្នាំ ទៅមួយឆ្នាំឥតឈប់ឈរ នោះការអប់រំ និងវិធីសាស្ត្របង្រៀនក៏ត្រូវមានការប្រែប្រួលទៅតាមបរិបទដែរ ។ ក្នុងន័យនេះ គ្រូបង្រៀនត្រូវមានវិធីសាស្ត្រថ្មីៗ ហើយដើម្បីទទួលបានវិធីសាស្ត្រថ្មីៗ ឱ្យឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្ស គ្រូចាំបាច់ណាស់ត្រូវមានការបំប៉នសមត្ថភាពជាប្រចាំ តាមរយៈគ្រូជួយគ្រូ តាមរយៈការផ្លាស់ប្តូរបទពិសោធន៍រវាងគ្រូនិងគ្រូ ឬប្រធានក្រុមបច្ចេកទេស និងសកម្មភាពធ្វើថ្នាក់និទស្សន៍ ក្នុងគោលបំណងបំប៉នសមត្ថភាព ឱ្យមានការរីកចម្រើនជាប្រចាំ ជាមួយនឹងបញ្ញត្តិ និងគោលការណ៍អប់រំថ្មីៗ ដើម្បីជួយដល់សិស្សឱ្យទទួលបានចំណេះដឹងគ្រប់ជ្រុងជ្រោយ **(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)**។ ដូចគ្នានេះដែរ ចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្សមានការប្រែប្រួល អាស្រ័យហេតុនេះរបៀបនៃការរៀនរបស់ពួកគេក៏មានការប្រែប្រួល នេះចង់សំដៅលើការបម្រែបម្រួលនៃការសិក្សារបស់ពួកគេ ដូចនេះទាមទារឱ្យគ្រូមានការប្រើប្រាស់វិធីសាស្ត្របង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន មានន័យថា គ្រូបង្រៀនដែលបានប្រើវិធីសាស្ត្របង្រៀនទទួលបានលទ្ធផលល្អនៅឆ្នាំចាស់ មិនប្រាកដថាទទួលបានជោគជ័យនៅឆ្នាំបន្តបន្ទាប់នោះទេ។

មួយវិញទៀត ការបំប៉នសមត្ថភាពគ្រូបង្រៀន គឺអាចជួយឱ្យមានការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនផងដែរ។ តាមការសិក្សាស្រាវជ្រាវដែលបានមកពីឯកសាររបស់ XudongZhu and Kenneth Zeichner (2013) និង Guskey (2002) បានបង្ហាញថា ការបំប៉នសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ធ្វើឱ្យគ្រូមានការរៀនសូត្រ និងចេះបង្កើតឱកាសសហការគ្នារវាងគ្រូ និងគ្រូ ដើម្បីរិះរកនូវគំនិតថ្មីៗ ក្នុងគោលបំណងទទួលបានវិធីសាស្ត្រថ្មីៗបន្ថែម សម្រាប់អនុវត្ត។ ទន្ទឹមនឹងនោះ ធ្វើឱ្យគ្រូផ្តោតតែទៅលើវិធីសាស្ត្របង្រៀន ខ្លឹមសារមេរៀន កម្មវិធីសិក្សា និងលទ្ធផលសិក្សារបស់សិស្សតែប៉ុណ្ណោះ។ តាមការសិក្សារបស់ OECD (2009) បានបង្ហាញថា ការបើវគ្គបំប៉នសមត្ថភាពគ្រូបង្រៀន ធ្វើឱ្យគ្រូ អាចប្រឹក្សា និងទទួលបានចំណេះដឹង បទពិសោធន៍បន្ថែមអំពីវិធីសាស្ត្របង្រៀនពីអ្នកជំនាញពីខាងក្រៅ។ ក្រៅពីនោះ គ្រូអាចធ្វើការសហការ សង្កេត ឬទស្សនៈកិច្ចរវាងគ្រូ និងគ្រូ ឬរវាងសាលារៀន និងសាលារៀន ដើម្បីធ្វើការចែករំលែកនូវការអនុវត្តល្អៗ ក្នុងគោលបំណងដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនទាក់ទងទៅនឹងវិធីសាស្ត្របង្រៀន។

ការបំប៉នសមត្ថភាពគ្រូ គឺជាការឆ្លើយតបទៅនឹង ផែនការប្រតិបត្តិប្រចាំឆ្នាំ(AOP)របស់សាលារៀន និងជានាគុណភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំខេត្ត ព្រមទាំងគោលនយោបាយកំណែទម្រង់របស់ក្រសួងអប់រំ ស្តីពីការពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន។ ក្រសួងអប់រំយុវជន និងកីឡា បានខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន អំពីវិធីសាស្ត្របង្រៀន ការគ្រប់គ្រងថ្នាក់រៀន និងការសហការជាមួយសិស្ស ព្រមទាំងអាណាព្យាបាលសិស្ស ដើម្បីជួយគ្រូ និងសិស្សក្នុងការបង្រៀន និងរៀនឱ្យទទួលបានលទ្ធផលល្អប្រសើរ **(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)**។ ក្រៅពីបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនដល់គ្រូ ក្រសួងអប់រំ យុវជន និងកីឡាក៏បានរៀបចំផែនការសម្រាប់បំប៉នសមត្ថភាព កម្មវិធីបំប៉នសមត្ថភាព ខ្លឹមសារបំប៉នសមត្ថភាព និងរបាយការណ៍សម្រាប់បំប៉នសមត្ថភាព ដើម្បីជួយបំពេញនិងពង្រឹងបន្ថែមនូវចំណេះដឹងដល់គ្រូបង្រៀនឱ្យមានការរីកចម្រើនជាប្រចាំ។ លើសពីនេះទៅទៀត កម្មវិធីអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន អាចជួយឱ្យគ្រូបានរៀនសូត្រជាប្រចាំ ក្នុងពេលបំពេញការងារមានការទទួលខុសត្រូវ និងមានភាពម្ចាស់ការនៅក្នុងការបង្រៀន និងរៀន។ ដូច្នេះ គោលនយោបាយស្តីពី

កម្មវិធីបណ្តុះបណ្តាល និងពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន គឺជាចលនាធនធានគ្រូ និងបុគ្គលិកអប់រំនៅក្នុងសាលាឱ្យខិតខំប្រឹងប្រែងរួមគ្នា និងរៀនសូត្រពីគ្នាទៅវិញទៅមក និងចេះសហការគ្នាជាចលនាធនធានមួយ ដើម្បីជួយឱ្យការអនុវត្តវិធីសាស្ត្របង្រៀនកាន់តែមានប្រសិទ្ធភាព ពិសេសជួយដល់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស ទៅតាមកម្រិតនៃស្តង់ដាកម្មវិធីសិក្សា របស់ក្រសួងអប់រំយុវជន និងកីឡា។

សរុបមក បន្ទាប់ពីបានធ្វើការពិភាក្សាលើបញ្ហាប្រឈមខាងលើរួចមកយើងឃើញថា បញ្ហាប្រឈមដែលកើតមាននៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពតស្ថិតនៅកម្រិតមធ្យម។ បញ្ហាប្រឈមដែលគ្រូបង្រៀនកំពង់ជួបប្រទះនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក មានដូចជាសមត្ថភាព និងចំណេះដឹងរបស់គ្រូបង្រៀនទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនមិនទាន់បានស៊ីជម្រៅ កម្រិតយល់ដឹងភាសាអង់គ្លេសរបស់សិស្សនៅមានកម្រិត ព្រមទាំងសម្ភារឧបទេសដែលបម្រើឱ្យការបង្រៀន និងរៀនពុំទាន់បានគ្រប់គ្រាន់។ ប៉ុន្តែយ៉ាងណាក៏ដោយ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមទាំងនោះបាន គឺតាមរយៈការបំប៉នសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនទាក់ទងទៅនឹងវិធីសាស្ត្របង្រៀន ដើម្បីជួយឱ្យគ្រូអនុវត្តវិធីសាស្ត្របង្រៀនពិសេសវិធីសាស្ត្របង្រៀន IBLទទួលបានលទ្ធផលល្អប្រសើរ និងកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនឹងនោះការបំប៉នសមត្ថភាពគ្រូបង្រៀន ក៏បានឆ្លើយតបទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ(AOP)របស់សាលារៀនការជានាគុណភាពនៃផែនការប្រតិបត្តិរបស់មន្ទីរអប់រំខេត្ត និងកំណែទម្រង់គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសក៏ជួយឱ្យគ្រូមានចិត្តសប្បាយរីករាយក្នុងការបំពេញការងារ(ការបង្រៀន) កាលណាគ្រូពេញចិត្តនឹងបំពេញការងារបានល្អ នាំឱ្យសិស្សានុសិស្សក៏ពេញចិត្តនៅក្នុងការសិក្សាភាសាអង់គ្លេសផងដែរ។ មិនតែប៉ុណ្ណោះសកម្មភាពទាំងនេះក៏ឆ្លុះបញ្ចាំងក្នុងការឆ្លើយតបទៅនឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនទៀតផង។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន

# និង

# ការសំណូមពរ

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

អ្នកសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរកនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តកំពត**" មានគោលបំណងសិក្សាពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេស ព្រមទាំងស្វែងរកពីបញ្ហាប្រឈមនានាដែលគ្រូបង្រៀនភាសាអង់គ្លេសកំពុងជួបប្រទះផងដែរ។

វិធីសាស្ត្រតាមបែបបរិមាណវិស័យ ត្រូវបានប្រើប្រាស់ក្នុងការទទួលបានព័ត៌មានជាក់លាក់ទាក់ទងទៅនឹងស្ថានភាពទូទៅ ក៏ដូចជាបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក នៅមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តកំពត។ ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងនៅសាលាគោលដៅចំនួន៥ ស្ថិតក្នុងស្រុក៤ នៅខេត្តកំពត ដែលមានអ្នកចូលរួមផ្តល់ឆ្លើយកម្រងសំណួរ(សំណាក)សរុបចំនួន១២២នាក់ ក្នុងនោះមានគណៈគ្រប់គ្រងសាលាចំនួន១៤នាក់ គ្រូបង្រៀន១៨នាក់ និងសិស្ស៩០នាក់។

ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះបានបង្ហាញថា ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពតស្ថិតក្នុងកម្រិតល្អ(ទទួលបានមធ្យមភាគពិន្ទុ=៣.៧៧)។ មធ្យមភាគពិន្ទុនេះបានបង្ហាញថា ទោះជាកម្រិតពិន្ទុស្ថិតនៅកម្រិតល្អក៏ដោយ ក៏ទាមទារឱ្យគ្រូបង្រៀនមានការកែលម្អនូវចំនុចខ្វះខាតមួយចំនួនដូចជា ដំណើរការបង្រៀន ដែលផ្តោតទៅលើបច្ចេកទេសប្រើប្រាស់វិធីសាស្ត្របង្រៀន និងការប្រើប្រាស់នូវសម្ភារឧបទេសក្នុងការបង្រៀន ដើម្បីឱ្យការបង្រៀន និងរៀនកាន់តែមានគុណភាព និងប្រសិទ្ធភាពបន្ថែមទៀត។ ចំណែកបញ្ហាប្រឈមនៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកវិញគឺស្ថិតនៅកម្រិតមធ្យម(មធ្យមភាគពិន្ទុ=៣.៣២) នេះបង្ហាញថាបញ្ហាប្រឈមមិនធ្ងន់ធ្ងរ ណាស់ណាទេ។ ក្នុងន័យនេះ ដើម្បីចូលរួមកាត់បន្ថយបញ្ហាប្រឈម នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះ

រក ទាមទារឱ្យគ្រូបង្រៀនមានការអភិវឌ្ឍនូវចំណេះដឹង សមត្ថភាព និងវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ ក្នុងគោលបំណងឱ្យលទ្ធផលសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ។

សរុបសេចក្តីមក យើងសង្កេតឃើញថាស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបបិរះរកនៅតាមគ្រឹះស្ថានសិក្សាសាធារណៈនៅខេត្តកំពតស្ថិតក្នុងកម្រិតល្អ ខណៈដែលមានបញ្ហាប្រឈមមួយចំនួនកំពុងកើតមានក៏ដោយ ក៏មិនបានចោទជាបញ្ហា និងភាពរាំងស្ទះដល់ការបង្រៀន និងរៀនភាសាអង់គ្លេស ព្រមទាំងលទ្ធផលសិក្សារបស់សិស្សទេ ។ ទន្ទឹមនឹងនោះ វិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបបិរះរកក៏ពិតជាមានសារៈសំខាន់សម្រាប់បម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលធ្វើឱ្យសិស្សានុសិស្សទទួលបានចំណេះដឹងផ្នែកភាសាអង់គ្លេស សម្រាប់ជាដើមទុនសម្រាប់ឱ្យពួកគេអាចបន្តការសិក្សានៅថ្នាក់មហាវិទ្យាល័យ និងប្រកួតប្រជែងឱកាសទីផ្សារការងារទាំងនៅក្នុង និងក្រៅស្រុក ក្នុងន័យនេះ ដើម្បីបន្តនិរន្តរ៍ភាព ក្នុងការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែម ទាមទារឱ្យគ្រូបង្រៀនមានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានការពង្រឹងចំណេះដឹង សមត្ថភាព ការបណ្តុះបណ្តាលគ្រូបង្រៀនលើវិធីសាស្ត្របង្រៀនឱ្យបានទូលំទូលាយ និងប្រព័ន្ធពិនិត្យតាមដានលើការអនុវត្តការងាររបស់គ្រូបង្រៀនជាប្រចាំពីសំណាក់គណៈគ្រប់គ្រងសាលា

## ៥.២. សំណូមពរ

ដើម្បីចូលរួមឆ្លើយតបទៅនឹងស្ថានភាព និងបញ្ហាប្រឈមលើការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបបិរះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត អ្នកសិក្សាស្រាវជ្រាវមានសំណូមពរដល់ភាគីពាក់ព័ន្ធដូចជា៖

### ក. ក្រសួងអប់រំ យុវជន និងកីឡា

- លើកកំពស់ការអនុវត្តយន្តការលើការប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀន ឆ្លើយតបទៅនឹងគន្លងអាជីពវិជ្ជាជីវៈគ្រូបង្រៀន

- ផ្ដល់កញ្ចប់បណ្ដុះបណ្ដាលបំប៉នសមត្ថភាពផ្នែកវិធីសាស្ត្របង្រៀនលើមុខវិជ្ជាភាសាអង់គ្លេសដល់គ្រូបង្រៀនភាសាអង់គ្លេសឆ្លើយតបក្របខណ្ឌកម្មវិធីសិក្សាអប់រំពេលវេញពេញលេញ។

**ខ. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត / ក្រុង**

- ពង្រឹងយន្តការចុះពិនិត្យតាមដាន លើសកម្មភាពការអនុវត្តគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- មានក្រុមអធិការកិច្ចតាមកាលកំណត់ ចុះជួយលើការងារបង្រៀន និងរៀនដើម្បីសិក្សាស្វែងយល់បន្ថែមនូវចំណុចខ្វះខាតលើការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេស។

**គ. គណៈគ្រប់គ្រងសាលា**

- តាមដានការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនលើមុខវិជ្ជាភាសាអង់គ្លេសតាមរយៈការធ្វើអធិការកិច្ចផ្ទៃក្នុង និងការធ្វើថ្នាក់និទស្សន៍ជាប្រចាំដើម្បីរកពីចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អ
- ជំរុញការប្រជុំក្រុមបច្ចេកទេស ក្នុងគោលបំណងស្វែងរកវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន និងការផលិតសម្ភារឧបទេសដើម្បីធ្វើឱ្យការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកាន់តែគួរឱ្យចាប់អារម្មណ៍និងទាក់ទាញ។

**ឃ. ចំពោះគ្រូបង្រៀនភាសាអង់គ្លេស**

- ពង្រឹងចំណេះដឹង និងសមត្ថភាពរបស់ខ្លួនបន្ថែមផ្នែកវិធីសាស្ត្របង្រៀនតាមបែបរិះរកឱ្យកាន់តែប្រសើរឡើង
- ត្រូវបន្តអភិវឌ្ឍន៍វិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀនឱ្យស្របទៅតាមកំណែទម្រង់ និងកម្មវិធីសិក្សាអប់រំពេលវេញពេញលេញរបស់ខ្លួន។

**ង. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត**

អ្នកសិក្សាស្រាវជ្រាវបានសិក្សាស្វែងយល់ពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះ(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត។ ការសិក្សាស្រាវជ្រាវ

នេះគឺបានផ្តោតតែលើការសិក្សាស្រាវជ្រាវតាមបែបបរិះរកប៉ុណ្ណោះ ដូច្នេះសម្រាប់អ្នកសិក្សាស្រាវជ្រាវបន្តគួរតែសិក្សាដោយផ្តោតទៅលើ៖

- ទស្សនៈយល់ឃើញរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិលើការប្រើប្រាស់វិធីសាស្ត្របង្រៀនលើមុខវិជ្ជាភាសាបរទេស។
- ការអនុវត្តដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសឆ្លើយតបទៅនឹងគន្លងអាជីពគ្រូបង្រៀន។
- ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងលើវិធីសាស្ត្របង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត។

# ឯកសារយោង

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨). សន្និបាតបូកសរុបការងារអប់រំ. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). វិធីសាស្រ្តបង្រៀន និងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងអប់រំ យុវជន និង កីឡា. (២០១៥). ចក្ខុវិស័យកំណែទម្រង់វិស័យអប់រំនៅកម្ពុជា. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា

នាយកដ្ឋានបណ្តុះបណ្តាល និង រិក្រឹតការ. (2011). ការរៀនតាមបែបរិះរក. ភ្នំពេញ: នាយកដ្ឋានបណ្តុះបណ្តាល និង រិក្រឹតការនៃព្រះរាជាណាចក្រកម្ពុជា

យូនីសេហ្វ. (2008). របាយការថ្នាក់ជាតិស្តីពីការវាយតម្លៃការអប់រំសម្រាប់ទាំងអស់គ្នា. ភ្នំពេញ: យូនីសេហ្វ និងស៊ីដា

វិទ្យាស្ថានជាតិអប់រំ. (២០២០).ការបង្រៀន និងរៀនតាមបែបរិះរក. ភ្នំពេញ: វិទ្យាស្ថានជាតិអប់រំនៃព្រះរាជាណាចក្រកម្ពុជា

វិទ្យាស្ថានជាតិអប់រំ. (២០១៩). វិធីសាស្រ្តបង្រៀន. ភ្នំពេញ : វិទ្យាស្ថានជាតិអប់រំនៃព្រះរាជាណាចក្រកម្ពុជា

សួនជាន. (២០១២). ការអនុវត្តកម្មវិធីសិក្សា. ភ្នំពេញ: សាកលវិទ្យាល័យភូមិន្ទភ្នំពេញ.

Asselin, Branch, &Oberg,(2003). Achieving Information Literacy Standards for School Literacy Program in Canada. Canadian School Literacy Association.

Best, J.W. (1981). Research in Education. Englewood Cliffs, 4th Edition ed., New York, Jersey: Prentice Hall, Inc.

Blanchard (2009) .Effects of Inquiry-based Learning on Students′ Science

Literacy Skills and Confidence. International Journal for the Scholarship of Teaching and Learning.

Branch, jennifer.et all. (2004). Focus on Inquiry. Canada: Alberta Learning.

Brew, Kahn & O´Rourke. (2006). Research and Teaching: Beyon the divide. Basingstoke: Palgrave Macmillan.

Chapman&Adams. (2002). The quality of education: Dimension and Strategies. Hong Kong: Asian Development Bank.

Crawford. (2016). Supporting Teachers in Inquiry/Science Practices, Modeling, and Complex Reasoning in Science Classrooms. Southern Africa Association of Maths, Science, and Technology Education Annual Conference.

Dol, Moen. (2016). The Implementation of a student-Centered Approach to teaching English at Upper Secondary School. Phnom Penh: Royal University of Phnom Penh.

Jonassen. (2000). Engaging Critical thinking(2nd Ed). Upper Saddle River, New jersey: Prentice Hall.

Scott. (1994). " Fidelity" mentality is no reality: A message for Developer. Paper Presenter at Astralia Association for research in Education.

Davis&Simmt. (2003). Understanding learning system. Journal for research in education.

Endang Lestari Universitas Muhammadiyah Surakarta. (2015-2016). The Implementation of Inquiry-Based Learning in teaching English at SMP Negeri 1 Gemolong.

Fauziati, Endang. (2014). Method of Teaching English as A Foreign Language (TEF):Traditional Method Communication Approach Scientific Approach . Pustaka Utama: Surakarta.

Knamille; Rosenberg. (1999; 1998). The Effectivness of teacher resource center Strategy. London: Departmant for International development. Education Research.

Grisay,& Mhalck . (1991). The quality of Education in developing Countries: A review of some research studies and policy documents. Paris: International Institute of Education planning.

Guskey. (2002). Professional Development and Teacher Change. Teacher and Teaching. Thoery and Practice.

Harlen. (2013). Assessment & Inquiry Based Science Education: Issued in policy and practice. Italy : Global Network of Science Academies.

Hamer. (2001). The Practice of English Language Teaching( 3rd Ed): describing teacher. Longman.

Jack Byrd. (2008). Guidebook for Student-Centered Classroom Discussion. United States of America.

Jamie Peter Wood University Shuffield, UK. ( 2009). Journal of learning Development in Higher Education.

Jonassen (2000). Engaging Critical thinking(2nd Ed). Upper Saddle River, New jersey: Prentice Hall.

Keselman. (2003). Supporting inquiry learning by promoting normative understanding causality. Journal of Research in Science Teaching.

Levy,P., Little, S., Mckinney, P., Nibbs,A. and Wood, J. (2010). The Sheffield Companion to Inquiry -Based Learning. Center for Inquiry-based learning in arts and Social Sciences, Sheffield: University of Sheffield.

Mc Gregor; Dlm Stripling; Hughes. (2003). Collaboration and Leadership( Curriculum Connection Through Literacy . Westport CT: Libraries Unlimited.

Ministry of Education Youth and Sport. (2013). Education Strategic Plan. Phnom Penh: Ministry of Education Youth and Sport.

Ministry of Education Youth and Sport. (2015). Policy on teachers. Phnom Penh: Ministry of Education Youth and Sport.

Ministry of Education Youth and Sport. (2011). Inquiry -Based Learning. Phnom Penh: Ministry of Education Youth and Sport.

Montages. (2001). Textbook and Learning Material. London/ Paris: Department for International Developmant: UNESCO.

National Institute of Education. (2020). Inquiry-Based Laguage Learning and Teaching. Phnom Penh. National Institute of Education

Natsir. (2014). Grammer Translation Method(GTM) Versus Communicative Language Teaching . Australia.

NGO Education Partnership. (2005). Effective Teaching Hours: A Report on Group research Project. Phnom Penh : UNICEF.

Organization for Economic Corporation Development. (2009). Professional Development of teacher. : Organization for Economic Corporation Development

Royal Government of Cambodia. (2018). National Development Strategic Plan 2019-2023. Phnom Penh: Royal Government of Cambodia

Richart & Lockhart. (2007). Reflective in Second Language Classrooms. New York: Combridge University Press.

Richarts and Rodgers. (1999). Approches and Methods in Langauge Teaching. New York: Cambridge University Press.

Skinner. (2009). Analysis of factors that explain the non completion of Curriculum. Madagascar.

Spronen. (2008). Experiencing the Process of Knowledge Creation:The Nature and Use of Inquiry-Based Learning in Higher .

UPSI Malaysia. (2006) Vol.2(1):13-24.). English Language Journal, 13-24.

Va sopheak. ( 2019 ). The effectiveness of Imlementation of Trainer's Teaching Methods. Phnom Penh: National Institute of Education.

World Bank. ( 2008 ). Teaching In Cambodia. Phnom Penh: World Bank.

Xudong Zhu, KennethZeichner( Editor ). ( 2013 ). Preparing Teacher for the 21th Century. Bijing: Bijing Normal University.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ "ក"
# កម្រងសំណួរក្នុងការប្រមូលទិន្នន័យ
# សម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត

ខ្ញុំបាទឈ្មោះ **ហង្ស សំអុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ**" ដើម្បីបញ្ចប់ការសិក្សា។ គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (IBL) របស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទៅលើមុខវិជ្ជា ភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រមទាំងសិក្សាពីបញ្ហាប្រឈមនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (IBL) ទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ។ ទិន្នន័យប្រមូលបានពីលោកគ្រូ-អ្នកគ្រូ មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅប្រធានបទខាងលើ។ ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមនាយក នាយករង និងនាយិការង មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកនាយក នាយករង និងនាយិការង ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

1. ឈ្មោះខេត្ត_______________________________________________

2. ឈ្មោះស្រុក/ក្រុង: 1. □ស្រុកបន្ទាយមាស 2.□កំពង់ត្រាច 3.□ស្រុកទឹកឈូ 4.□ក្រុងកំពត

3.ឈ្មោះសាលា: 1.□វិ.ហ៊ុនសែនបរិវាស 2.□វិ.សម្តេចហ៊ុនសែនអង្គសុរភី 3.□វិ.ព្រះបិតាជាតិ

4.□វិ.ព្រះនរោត្តមរណឫទ្ធិ 5.□វិ. មិត្តភាពកម្ពុជា-ជប៉ុន កំពតក្រុង

4. រយៈពេលបម្រើការងារជានាយក/នាយិកា:1.□ ១ដល់៥ឆ្នាំ 2.□ ៦ដល់ ១០ឆ្នាំ 3.□ ១១ ដល់១៥ឆ្នាំ

4. □ លើស១៦ឆ្នាំ

5. ប្រភេទក្របខណ្ឌ: 1. □ គ្រូកម្រិតឧត្តម 2. □ គ្រូកម្រិតមូលដ្ឋាន 3. □ផ្សេងៗ___________

6.ភេទ: 1. □ ប្រុស 2. □ ស្រី

7.កម្រិតសញ្ញាបត្រ 1. □បណ្ឌិត 2. □បរិញ្ញាបត្រជាន់ខ្ពស់ 3. □បរិញ្ញាបត្រ

4.□បរិញ្ញាបត្ររង 5. □ថ្នាក់ទី១២ 6. □ផ្សេងៗ…………

8. អាយុ : 1. □ ២៥-៣០ ឆ្នាំ 2.□ ៣១-៣៥ឆ្នាំ 3.□៣៦-៤០ឆ្នាំ 4. □ លើសពី៤០ឆ្នាំ

9.បទពិសោធន៍បង្រៀន៖1.□១ដល់៥ឆ្នាំ 2. □៦ទៅ១០ឆ្នាំ 3. □១១ទៅ១៥ ឆ្នាំ 4.□លើសពី១៥ឆ្នាំ

**ផ្នែកទី២៖ ស្ថានភាពនៅលើការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរក( IBL ) របស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត**

ការណែនាំ៖ សំនួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងការអនុវត្តការងាររបស់លោកគ្រូ-អ្នកគ្រូរបស់លោកនាយកនាពេលកន្លងមក តើលោកនាយក មានការយល់ឃើញ ទៅលើការអនុវត្តកម្មវិធីសិក្សា យ៉ាងដូចម្តេចខ្លះដែលលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសរបស់លោកនាយកកំពុងអនុវត្ត? សូមអានចំណុចនីមួយ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកនាយក ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ
២. មិនយល់ស្រប
៣. ពុំមានយោបល់
៤. យល់ស្រប
៥. យល់ស្របខ្លាំង

| ល.រ | **បរិយាយ** | **កម្រិត** | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **ក. ការអវត្តតាមកម្មវិធីសិក្សា** | | | | | | |
| ១ | គ្រូបង្រៀនបានធ្វើបំណែងចែកកម្មវិធីសិក្សាបានច្បាស់លាស់ដោយមានឆ្លងការចុះទិដ្ឋាការពីគណៈគ្រប់គ្រងសាលា | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | គ្រូបានអនុវត្តតាម និងទាន់កម្មវិធីសិក្សា និងបំណែងចែកកម្មវិធីសិក្សាបានត្រឹមត្រូវ | | | | | |
| ៣ | គ្រូបានរៀបចំ និងអនុវត្តតាមកាលវិភាគបង្រៀនបានយ៉ាងត្រឹមត្រូវ | | | | | |
| ៤ | គ្រូបង្រៀនបានបង្រៀនមេរៀន ស្របតាមកម្មវិធីសិក្សាកំណត់ | | | | | |
| ៥ | គ្រូបានរៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆមាស | | | | | |
| ៦ | គ្រូបង្រៀន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន | | | | | |
| ៧ | ជារួម លោកគ្រូ-អ្នកគ្រូ គឺមានភាពច្បាស់លាស់ ទៅលើការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសនៅមធ្យមសិក្សទុតិយភូមិ | | | | | |
| **ខ. ការអនុវត្តទៅលើវិធីសាស្ត្របង្រៀន** | | | | | | |
| ១ | គ្រូមានចំណេះដឹង និងជំនាញវិជ្ជាជីវៈ ទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនតាមបែបរិះរក( IBL ) | | | | | |
| ២ | គ្រូបានប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែបរិះរកជា | | | | | |
| ៣ | ំ គ្រូ យល់ច្បាស់ពីតួនាទីរបស់ខ្លួន ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក | | | | | |
| ៤ | គ្រូមានឧទាហរណ៍ ក្នុងការពន្យល់ និងបំណកស្រាយដោយអនុវត្តទៅតាមជំហាននៃវិធីសាស្ត្របង្រៀនតាមបែបរិះរក | | | | | |
| ៥ | គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើវិធីសាស្ត្របង្រៀន | | | | | |
| ៦ | គ្រូបង្រៀន មានសមត្ថភាពសបស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន | | | | | |
| ៧ | គ្រូបង្រៀនមានស្មារតី និងភាពជឿជាក់ខ្ពស់លើវិធីសាស្ត្របង្រៀនបែបរិះរក | | | | | |
| **គ.ការប្រើប្រាស់សម្ភារឧបទេស** | | | | | | |
| ១ | គ្រូបានរៀបចំសម្ភារៈឧទ្ទេសដែលឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្របែបរិះរក | | | | | |
| ២ | គ្រូបានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរកបានញឹកញាប់ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | គ្រូ និងសិស្សមានសៀវភៅសិក្សាគោលភាសាអង់គ្លេស ឆ្លើយតបទៅនឹងខ្លឹមសារមេរៀន | | | | | |
| ៤ | គ្រូបានប្រើប្រាស់រូបភាពទាក់ទងទៅនឹងសកម្មភាពមេរៀន | | | | | |
| ៥ | គ្រូបានប្រើប្រាស់Posters ផ្សេងៗទាក់ទងទៅនឹងខ្លឹមសារមេរៀន | | | | | |
| **ឃ. លទ្ធផលសិក្សារបស់សិស្ស** | | | | | | |
| ១ | លទ្ធផលសិក្សារបស់សិស្សបង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន បន្ទាប់ពីគ្រូបានអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក | | | | | |
| ២ | លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | | | | | |
| ៣ | សិស្សមានជំនាញដោះស្រាយបញ្ហាដោយខ្លួនឯងនៅពេលអនុវត្តការបង្រៀន និងរៀនតាមវិធីសាស្ត្របែបរិះរក | | | | | |
| ៤ | សិស្សមានសមត្ថភាពការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ប្រមូលព័ត៌មាន និងស្រាវជ្រាវ | | | | | |
| ៥ | ឱ្យសិស្សមានគំនិតច្នៃប្រឌិតក្នុងការរៀនសូត្រ | | | | | |
| ៦ | ធ្វើឱ្យមានការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណាសម្រាប់សិស្ស | | | | | |
| ៧ | សិស្សចេះ អង្កេត រិះរក និងដោះស្រាយបញ្ហាប្រកបដោយនវានុវត្តន៍ | | | | | |
| ៨ | អភិវឌ្ឍន៍សមត្ថភាពសិស្សានុសិស្សក្នុងការគិតបែបស៊ីជម្រៅ( Critical Thinking ) | | | | | |

**មតិយោបល់បន្ថែម៖**

១. តើលោកនាយក បានដឹងថាលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសរបស់លោកនាយក បានជួបប្រទះការលំបាកអ្វីខ្លះ ក្នុងការអនុវត្តកម្មវិធីសិក្សា ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

២.តើលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសរបស់លោកនាយក មានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តវិធីសាស្រ្តបង្រៀនតាមបែបរិះរក( IBL ) ?

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………..

សូមអរគុណ!

**ឧបសម្ព័ន្ធ "ខ"**

**ទិន្នន័យស្តីពី៖ ព័ត៌មានទូទៅរបស់ គណៈគ្រប់គ្រងសាលា**

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | រយៈពេលបម្រើការងារជានាយក/នាយិកា/នាយករង/ នាយិការង | ១ដល់៥ឆ្នាំ | 6 | 43% |
| | | ៦ ដល់១០ឆ្នាំ | 1 | 7% |
| | | ១១ដល់១៥ឆ្នាំ | 3 | 21% |
| | | លើស១៦ឆ្នាំ | 4 | 29% |
| | | **សរុប** | **14** | **100%** |
| ២ | ប្រភេទក្របខណ្ឌ | កម្រិតឧត្តម | 9 | 64% |
| | | កម្រិតមូលដ្ឋាន | 5 | 36% |
| | | **សរុប** | **14** | **100%** |
| ៣ | ភេទ | ប្រុស | 11 | 79% |
| | | ស្រី | 3 | 21% |
| | | **សរុប** | **14** | **100%** |
| ៤ | កម្រិតសញ្ញាបត្រ | បណ្ឌិត | 0 | 0% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 4 | 29% |
| | | បរិញ្ញាបត្រ | 10 | 71% |
| | | បរិញ្ញាបត្ររង | 0 | 0% |
| | | ថ្នាក់ទី១២ | 0 | 0% |
| | | **សរុប** | **14** | **100%** |
| ៥ | អាយុ | ២៥ ដល់ ៣០ | 0 | 0% |
| | | ៣១ ដល់ ៣៥ | 2 | 14% |
| | | ៣៦ ដល់៤០ | 2 | 14% |
| | | លើស ៤០ | 10 | 71% |
| | | **សរុប** | **14** | **100%** |
| ៦ | បទពិសោធន៍ជាអ្នកគ្រប់គ្រង | ១ ដល់៥ ឆ្នាំ | 0 | 0% |
| | | ៦ ដល់១០ឆ្នាំ | 1 | 7% |
| | | ១១ដល់១៥ឆ្នាំ | 4 | 29% |
| | | លើស១៥ឆ្នាំ | 9 | 64% |
| | | **សរុប** | **14** | **100%** |

## ឧបសម្ព័ន្ធ "គ"
## កម្រងសំណួរក្នុងការប្រមូលទិន្នន័យ
## សម្រាប់លោកគ្រូ អ្នកគ្រូ មធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពត

ខ្ញុំបាទឈ្មោះ **ហង្ស សំអុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "**ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ**" ដើម្បីបញ្ចប់ការសិក្សា។ គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាពីស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (IBL) របស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទៅលើមុខវិជ្ជា ភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ(ដោយផ្តោតទៅលើ សារៈសំខាន់នៃការអនុវត្តIBL និង លទ្ធផលសិក្សាបន្ទាប់ពីបានអនុវត្ត ព្រមទាំងសិក្សាពីបញ្ហាប្រឈមនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (Inquiry Base Learning) ទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ។ ទិន្នន័យប្រមូលបានពីលោកគ្រូ-អ្នកគ្រូ មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅប្រធានបទខាងលើ។ ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកគ្រូ-អ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកគ្រូ-អ្នកគ្រូ។

### ផ្នែកទី១៖ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

1. ឈ្មោះខេត្ត:_______________________________________________
2. ឈ្មោះស្រុក/ក្រុង: 1. □ស្រុកបន្ទាយមាស 2.□កំពង់ត្រាច 3.□ស្រុកទឹកឈូ 4.□ក្រុងកំពត
3. ឈ្មោះសាលា: 1.□វិ.ហ៊ុនសែនបរិវាស 2.□វិ.សម្តេចហ៊ុនសែនអង្គសុរភី 3.□វិ.ព្រះបិតាជាតិ 4.□វិ.ព្រះនរោត្តមរណឫទ្ធិ 5.□វិ .មិត្តភាពកម្ពុជា-ជប៉ុន កំពតក្រុង

4.បង្រៀនថ្នាក់ទី: 1. □ ថ្នាក់ទី១០ 2. □ ថ្នាក់ទី១១ 3. □ ថ្នាក់ទី១២

5. ភេទ: 1. □ ប្រុស 2. □ ស្រី
6. អាយុ: 1.□១៨-២៣ ឆ្នាំ 2. □២៤-២៩ឆ្នាំ 3. □៣០-៣៥ឆ្នាំ 4. □លើសពី៣៥ឆ្នាំ
7. កម្រិតសញ្ញាបត្រ: 1. □បណ្ឌិត 2. □បរិញ្ញាបត្រជាន់ខ្ពស់ 3. □បរិញ្ញាបត្រ

4. □បរិញ្ញាបត្ររង 5. □ថ្នាក់ទី១២ 6. □ផ្សេងៗ………………..

8.បទពិសោធន៍បង្រៀន៖ 1.□១ដល់៥ឆ្នាំ 2.□៦ទៅ១០ឆ្នាំ 3.□១១ទៅ១៥ ឆ្នាំ 4. □ លើសពី១៥ឆ្នាំ

## ផ្នែកទី២៖ ស្ថានភាពនៅលើការអនុវត្តវិធីសាស្ត្របង្រៀនបែបរិះរក(IBL) របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត

ការណែនាំ៖ នៅក្នុងបទពិសោធន៍នៃការបង្រៀនរបស់លោកគ្រូ អ្នកគ្រូកន្លងមក តើលោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពត មានការយល់ឃើញ ទៅលើការអនុវត្តវិធីសាស្ត្របង្រៀនបែបរិះរកយ៉ាងដូចម្តេចខ្លះ? សូមអានចំណុចនីមួយ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ-អ្នកគ្រូ ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. ពុំមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | **ក.ការអនុវត្តកម្មវិធីសិក្សា** | ១ | ២ | ៣ | ៤ | ៥ |
| ១ | មុខវិជ្ជាភាសាអង់គ្លេសបានបង្រៀនចប់ តាមកម្មវិធីសិក្សា | | | | | |
| ២ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជាភាសាអង់គ្លេស | | | | | |
| ៣ | បានរៀបចំបំណែងចែកមេរៀន តាមកាលវិភាគយ៉ាងត្រឹមត្រូវ | | | | | |
| ៤ | មានបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស | | | | | |
| ៥ | សៀវភៅពុម្ពសិក្សា សមស្របជាមួយកម្រិតយល់ដឹងរបស់សិស្ស | | | | | |
| ៦ | បានរៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆមាស | | | | | |
| ៧ | បានស្រាវជ្រាវបន្ថែមលើចំណេះដឹង ជំនាញវិជ្ជាជីវៈរបស់ខ្លួន | | | | | |
| ៨ | កិច្ចតែងការបង្រៀនបានពិនិត្យដោយគណៈគ្រប់គ្រង | | | | | |
| | **ខ. ដំណើរការបង្រៀន** | | | | | |
| ១ | បានរៀបចំកិច្ចតែងការ តាមវិធីសាស្ត្ររិះរក | | | | | |
| ២ | បានអនុវត្តតាមគ្រប់ជំហានទាំង៥ នៃវិធីសាស្ត្របង្រៀនរិះរក | | | | | |
| ៣ | បានឱ្យសិស្សសង្កេត និងប្រមូលព័ត៌មានទាក់ទងទៅនឹងសំណួរគន្លិះ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | បានបែងចែកក្រុមកិច្ចការ ដល់សិស្សសម្រាប់សកម្មភាពក្នុងថ្នាក់ | | | | | |
| ៥ | បានអោយសិស្សឆ្លុះបញ្ចាំង ពីការរិះរកនូវអ្វីដែលរកឃើញ | | | | | |
| ៦ | គ្រូ និងសិស្សបានដឹងពីតួនាទីរបស់ខ្លួន នៅពេលអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនតាមបែបរិះរក | | | | | |
| ៧ | បានពន្យល់ និងបំណកស្រាយមេរៀនដោយអនុវត្តទៅតាមជំហាននៃវិធីសាស្រ្តតាមបែបរិះរក  ជាប្រចាំ | | | | | |
| | **គ. ទំនាក់ទំនងគ្រូ-សិស្ស** | | | | | |
| ១ | បានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស | | | | | |
| ២ | បង្កបរិយាកាសឱ្យសិស្សចេះរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុម | | | | | |
| ៣ | បានជំរុញការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណារបស់សិស្ស | | | | | |
| ៤ | បានជម្រុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សាតាមIBL | | | | | |
| ៥ | ជម្រុញការចូលរួមយ៉ាងសកម្ម របស់សិស្សក្នុងសកម្មភាពសិក្សា | | | | | |
| ៦ | បានបង្កើនភាពសហការគ្នាក្នុងដំណើរការបង្រៀន និងរៀន | | | | | |
| ៧ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | | | | | |
| | **ឃ. ការប្រើប្រាស់សម្ភារឧបទេស** | | | | | |
| ១ | មានសម្ភារៈឧទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្រ្តបែបរិះរក | | | | | |
| ២ | បានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក | | | | | |
| ៣ | សម្ភារឧបទេស បានជួយអោយការសិក្សារីកចម្រើន | | | | | |
| ៤ | បានប្រើប្រាស់សម្ភារឧបទេស ក្នុងការបង្រៀនតាមវិធីសាស្រ្តបែបរិះរកញឹកញាប់ | | | | | |
| ៥ | បានប្រើប្រាស់រូបភាព ទាក់ទងទៅនឹងសកម្មភាពនៃខ្លឹមសារមេរៀនជាប្រចាំ | | | | | |

**មតិយោបល់បន្ថែម៖**

ក. អំពីការអនុវត្តកម្មវិធីសិក្សាទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនតាមបែបរិះរក

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

ខ. ដំណើរការបង្រៀនដោយអនុវត្តទៅតាមវិធីសាស្ត្របង្រៀនតាមបែបរិះរក

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

គ. ទំនាក់ទំនងរវាងគ្រូ-សិស្សក្នុងពេលអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

ឃ. ការរៀបចំសម្ភារៈឧបទ្ទេសសម្រាប់បង្រៀនតាមវិធីសាស្ត្របែបរិះរក

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

## ផ្នែកទី៣៖ បញ្ហាប្រឈម ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកនៅលើមុខវិជ្ជាភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូ នៅមធ្យមសិក្សាទុតិយភូមិខេត្តកំពត

ការណែនាំ៖ នៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក របស់លោកគ្រូ-អ្នកគ្រូ នៅមធ្យមសិក្សាទុតិយភូមិ នាពេលកន្លងមក បានជួបបញ្ហាប្រឈមដូចម្ដេចខ្លះ? សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការយល់ស្របរបស់លោកគ្រូ-អ្នកគ្រូ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយលបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | បំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស មានភាពច្បាស់លាស់ | | | | | |
| ២ | សៀវភៅពុម្ពសិក្សាសម្រាប់គ្រូ និងសិស្សបានគ្រប់គ្រាន់ | | | | | |
| ៣ | សម្ភារឧបទេស ឆ្លើយតបទៅនឹងខ្លឹមសារមេរៀន | | | | | |
| ៤ | ពេលម៉ោងកាលវិភាគសមស្រប កម្មវិធីសិក្សា | | | | | |
| ៥ | បានពង្រឹងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក | | | | | |
| ៦ | មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់គ្រូ ផលិតសម្ភារៈឧបទេស | | | | | |
| ៧ | គ្រូបង្រៀនទទួល បានការលើកទឹកចិត្តពីគណៈគ្រប់គ្រងសាលា | | | | | |

**មតិយោបល់បន្ថែម៖**

១. តើលោកគ្រូ អ្នកគ្រូបានជួបប្រទះបញ្ហាអ្វីខ្លះក្នុងពេលអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរក?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………..

សូមអរគុណ!

# ឧបសម្ព័ន្ធ "ឃ"
# ទិន្នន័យស្ដីពីៈ ព័ត៌មានទូទៅរបស់ គ្រូបង្រៀន

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | គ្រូបង្រៀនថ្នាក់ទី | ថ្នាក់ទី១០ | 6 | 33% |
| | | ថ្នាក់ទី១១ | 5 | 28% |
| | | ថ្នាក់ទី១២ | 7 | 39% |
| | | **សរុប** | **18** | **100%** |
| ២ | ភេទ | ប្រុស | 16 | 89% |
| | | ស្រី | 2 | 11% |
| | | **សរុប** | **18** | **100%** |
| ៣ | អាយុ | ១៨-២៣ ឆ្នាំ | 0 | 0% |
| | | ២៤-២៩ឆ្នាំ | 1 | 6% |
| | | ៣០-៣៥ឆ្នាំ | 6 | 33% |
| | | លើសពី៣៥ឆ្នាំ | 11 | 61% |
| | | **សរុប** | **18** | **100%** |
| ៤ | កម្រិតសញ្ញាបត្រ | បណ្ឌិត | 0 | 0% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 3 | 17% |
| | | បរិញ្ញាបត្រ | 13 | 72% |
| | | បរិញ្ញាបត្ររង | 1 | 6% |
| | | ថ្នាក់ទី១២ | 1 | 6% |
| | | **សរុប** | **18** | **100%** |
| ៦ | បទពិសោធន៍បង្រៀន | ១ដល់៥ឆ្នាំ | 3 | 17% |
| | | ៦ទៅ១០ឆ្នាំ | 7 | 39% |
| | | ១១ទៅ១៥ ឆ្នាំ | 5 | 28% |
| | | លើសពី១៥ឆ្នាំ | 3 | 17% |
| | | **សរុប** | **18** | **100%** |

## ឧបសម្ព័ន្ធ "ខ"

## គម្រូសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់សិស្ស មធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត

ខ្ញុំបាទឈ្មោះ **ហង្ស សំអុល** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ **«ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក(IBL)នៅកម្រិតមធ្យមសិក្សាទុតិយភូមិ»ករណីសិក្សានៅខេត្តកំពត** ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ ចម្លើយរបស់ប្អូនគ្មានខុសឡើយ គ្រាន់តែប្អូនឆ្លើយឱ្យបានច្បាស់លាស់តាមតែអាចធ្វើទៅបាន។ សូមអានប្រយោគខាងក្រោមឱ្យបានច្បាស់លាស់ រួចឆ្លើយ និងជ្រើសរើសជម្រើសដែលប្អូនគិតថាត្រឹមត្រូវចំពោះប្អូន។ អាស្រ័យហេតុនេះ សូមប្អូនផ្តល់ចម្លើយចំពោះសំណួរខាងក្រោមដោយយកចិត្តទុកដាក់។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់ប្អូនៗ ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

**1.**ឈ្មោះខេត្ត:_______________________________________________

2.ឈ្មោះស្រុក/ក្រុង: 1. □ស្រុកបន្ទាយមាស 2.□ស្រុកកំពង់ត្រាច 3.□ស្រុកទឹកឈូ 4.□ក្រុងកំពត

3.ឈ្មោះសាលា: : 1.□វិ.ហ៊ុនសែនបរិវាស 2.□វិ.សម្តេចហ៊ុនសែនអង្គសុរភី 3.□វិ.ព្រះបិតាជាតិ

4.□វិ.ព្រះនរោត្តមរណឫទ្ធិ 5.□វិ. មិត្តភាពកម្ពុជា-ជប៉ុន កំពតក្រុង

4.រៀនថ្នាក់ទី: 1. □ ថ្នាក់ទី១០ 2. □ ថ្នាក់ទី១១ 3. □ ថ្នាក់ទី១២

5.ភេទ: 1. □ ប្រុស 2. □ ស្រី

6.អាយុ: 1.□១០-១៥ ឆ្នាំ 2. □១៦-២០ឆ្នាំ 3. □លើសពី២១ឆ្នាំ

**ផ្នែកទី២ ៖ ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀនភាសាអង់គ្លេសតាមបែប រិះរករបស់លោកគ្រូ-អ្នកគ្រូរបស់ប្អូននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត**

ការណែនាំ៖ សំនួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងការអនុវត្តការងាររបស់លោកគ្រូ-អ្នកគ្រូរបស់ប្អូន នាពេលកន្លងមក តើប្អូន មានការយល់ឃើញទៅលើការអនុវត្តវិធីសាស្ត្របង្រៀន យ៉ាងដូចម្តេចខ្លះដែលលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសរបស់ប្អូន កំពុងអនុវត្ត? សូមអានចំណុចនីមួយ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់ប្អូន ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. ពុំមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | **បរិយាយ** | **កម្រិត** | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| | **ក. ការបង្រៀន** | | | | | |
| ១ | ការដាក់ពិន្ទុរបស់គ្រូគឺប្រកបដោយតម្លាភាព និងយុត្តិធម៌ | | | | | |
| ២ | គ្រូមានវិធីសាស្ត្របង្រៀនល្អ ធ្វើឱ្យប្អូនងាយយល់ខ្លឹមសារមេរៀន | | | | | |
| ៣ | គ្រូមានចំណេះដឹង និងជំនាញវិជ្ជាជីវៈពិតប្រាកដ | | | | | |
| ៤ | គ្រូបានផ្តល់ឱកាសឱ្យសិស្សានុសិស្សបានរៀនសូត្រដូចៗគ្នា | | | | | |
| ៥ | គ្រូបានប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនភាសាអង់គ្លេស | | | | | |
| ៦ | គ្រូបានជម្រុញសិស្ស អោយរៀនរិះរក ពីការសិក្សាភាសាអង់គ្លេស | | | | | |
| ៧ | គ្រូបង្រៀនតាមកាលវិភាគ និងម៉ោងកំណត់បានយ៉ាងត្រឹមត្រូវ | | | | | |
| ៨ | គ្រូបានប្រើសៀវភៅពុម្ពសិក្សា ភាសាអង់គ្លេស | | | | | |
| ៩ | ជារួម ប្អូនពេញចិត្តចំពោះការបង្រៀនរបស់គ្រូភាសាអង់គ្លេស | | | | | |
| | **ខ. សកម្មភាពរៀនរបស់សិស្សនៅក្នុងថ្នាក់** | | | | | |
| ១ | សិស្សបានចូលរួមរិះរក ការដោះស្រាយបញ្ហា ដែលគ្រូបានដាក់ឱ្យ | | | | | |
| ២ | សិស្សបានចូលរួមកិច្ចពិភាក្សាជាក្រុម | | | | | |
| ៣ | សិស្សបានធ្វើបទបង្ហាញនូវរបកគំហើញថ្មី ដែលក្រុមបានរកឃើញ | | | | | |
| ៤ | សិស្សអាចធ្វើការឆ្លុះបញ្ចាំងពីការវិភាគ និងសន្និដ្ឋានរួម | | | | | |
| ៥ | សិស្ស ចូលចិត្តរៀនតាមវិធីរិះរក លើមុខវិជ្ជាភាសាអង់គ្លេស | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | សិស្ស ទទួលបានចំណេះដឹងថ្មី ក្រោយពេលប្រើការ រិះរករួច | | | | | |
| ៧ | ជារួម សិស្សចូលចិត្តរៀនភាសាអង់គ្លេស | | | | | |

**សំណើរ ឬមតិយោបល់បន្ថែមៈ**

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

អរគុណ!

# ឧបសម្ព័ន្ធ "ច"

## លទ្ធផលព័ត៌មានទូទៅពីកម្រងសំណួរសម្រាប់សិស្ស

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ថ្នាក់ទី | ថ្នាក់ទី១០ | 32 | 36% |
| | | ថ្នាក់ទី១១ | 25 | 27% |
| | | ថ្នាក់ទី១២ | 33 | 37% |
| | | **សរុប** | **90** | **100%** |
| ២ | ភេទ | ប្រុស | 24 | 27% |
| | | ស្រី | 66 | 73% |
| | | **សរុប** | **90** | **100%** |
| ៣ | អាយុ | ១០-១៥ ឆ្នាំ | 18 | 20% |
| | | ១៦-២០ឆ្នាំ | 72 | 80% |
| | | លើស២០ឆ្នាំ | 0 | 0% |
| | | **សរុប** | **90** | **100%** |

# ឧបសម្ព័ន្ធ " ឆ "
# លិខិតឧទេសនាម និងឯកសារពាក់ព័ន្ធ
# លិខិតបង្គាប់ការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**
លេខ : ០៥៣ វជអ.

**លិខិតបង្គាប់ការ**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត **ហង្ស សំអុល** ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

លោកបណ្ឌិត នូវ វីរ៉ា

២-គ្រូដឹកនាំរង

លោក ចាប រតនា

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
**ជ.នាយកវិទ្យាស្ថានជាតិអប់រំ**
**នាយករង**

បណ្ឌិត.នួន_វីរ៉ា

**កន្លែងទទួល៖**
- -ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៨៥៤ គេហទំព័រ៖ www.nie.edu.kh

# លិខិតអនុញ្ញាតការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
# ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខៈ ២៩៥៥ អយក.វ៉ក

ថ្ងៃអង្គារ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបមក**
**ឯកឧត្តមនាយក វិទ្យាស្ថានជាតិអប់រំ**

**កម្មវត្ថុ ៖** ការប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២៥ អធិការអប់រំ ជំនាន់ទី៥ ការបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ និងទី៣ និងការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧។

**យោង ៖**
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២៥
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ និង ជំនាន់ទី៣
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលអធិការអប់រំ ជំនាន់ទី៥
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧
- លិខិតលេខ១៦៨ វជអ.ផក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ស្តីពីការពន្យារពេលប្រឡងបញ្ចប់ការបណ្តុះបណ្តាល។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមនាយកវិទ្យាស្ថានជាតិអប់រំ** ជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំការប្រឡងបញ្ចប់ការបណ្តុះបណ្តាល៖ (១) គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី២៥ នៅទី០៨ ខែតុលា ឆ្នាំ២០២០ (២)ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ជំនាន់ទី៣ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ (៣) អធិការអប់រំ ជំនាន់ទី៥ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ និង(៤)ការរៀបចំការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ ។

ដើម្បីរៀបចំដំណើរការប្រឡងបញ្ចប់ និងការការពារនិក្ខេបបទខាងលើ ឱ្យទទួលបានលទ្ធផលល្អ និងមានសុវត្ថិភាព វិទ្យាស្ថានជាតិអប់រំត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម៖

- វិញ្ញាសាប្រឡងរក្សាស្តង់ដាដូចឆ្នាំកន្លងទៅ
- លទ្ធផលនៃការប្រឡងបញ្ចប់៖
  - •គ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២៥ ត្រូវយកពិន្ទុប្រឡងបញ្ចប់+ពិន្ទុប្រចាំឆ្នាំ +ពិន្ទុប្រតិបត្តិប្រចាំឆ្នាំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

•ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ និងជំនាន់ទី៣ ត្រូវយក ពិន្ទុប្រឡងបញ្ចប់+ពិន្ទុប្រចាំឆ្នាំ+ពិន្ទុនិក្ខេបបទ

•អធិការអប់រំ ជំនាន់ទី៥ ត្រូវយកពិន្ទុប្រឡងបញ្ចប់+ពិន្ទុប្រចាំឆ្នាំ

•បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ត្រូវយកពិន្ទុការពារនិក្ខេបបទ+ពិន្ទុប្រចាំឆ្នាំ

- ត្រូវប្រើប្រាស់ថវិកាមិនឱ្យលើសពីថវិកាដែលបានគ្រោង
- បន្ទប់ប្រឡងនីមួយៗត្រូវដាក់បេក្ខជនពី១៥នាក់(ដប់ប្រាំនាក់)ទៅ២០នាក់(ម្ភៃនាក់)
- គ្រប់គណៈកម្មការប្រឡង និងបេក្ខជន ទាំងអស់គ្នាត្រូវចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយលាងដៃនឹងអាល់កុល ឬចែល ឬសាប៊ូ ពាក់ម៉ាស និងគម្លាតសុវត្ថិភាពផ្ទាល់ខ្លួនជាប្រចាំក្នុងពេលដំណើរការប្រឡង តាមការណែនាំរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក(WHO)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមនាយក** អនុវត្តការងារនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់និស្សិត និងគរុនិស្សិត តាមការគួរ។

សូម **ឯកឧត្តមនាយក** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-វិទ្យាស្ថានជាតិអប់រំ "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :..១៩៦..ខជអ.**

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **ហង្ស សំអុល** នៅវិទ្យាល័យនានាខេត្តកំពត។

**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា លោក **ហង្ស សំអុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំមានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី **«ស្ថានភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេសតាមបែបរិះរក (IBL) នៅកម្រិតមធ្យមសិក្សាទុតិយភូមិ»ករណីសិក្សាក្នុង ខេត្តកំពត** ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។ លោក **ហង្ស សំអុល** នឹងសម្ភាសន៍តាមប្រព័ន្ធ ONLINE ដល់លោកនាយក នាយករង ឬនាយិការង លោកគ្រូ អ្នកគ្រូ និងសិស្ស នៅវិទ្យាល័យហ៊ុនសែនបរិវាស វិទ្យាល័យហ៊ុនសែនអង្គរសុភី វិទ្យាល័យព្រះបិតាជាតិ វិទ្យាល័យព្រះនរោត្តមរណឫទ្ធិ និងវិទ្យាល័យមិត្តភាពកម្ពុជា-ជប៉ុន កំពតក្រុងនៅខេត្តកំពត ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។**

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុទណ្ណារ៉ា**